# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

INSTITUT BOUDDHIQUE

ឆ្នាំទី ២៧ ខែ ធ្នូ លេខ ១២

ព.ស.២៤៩៨–គ.ស.១៩៥៥

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

## បញ្ជីរឿង

### ផ្នែកសាសនា

ទំព័រ

— មច្ឆរិយៈគឺអ៊ី . . . . . . . . . . . ព្រះទេពសត្ថា កិម-តូ . . . . . . ៨៨៣
— ចិត្តកថា . . . . . . . . . ព្រះបាឡាត់ឧត្តមលិខិត សុង-ស៊ីវ ៨៩០
— បញ្ញាសជាតក ភាគទី ៤ (តមក) . . បណ្ឌិតមហា ឈឹម-ស៊ុម . . . ៩០៥

### ផ្នែកអក្សរសាស្ត្រ

— សង្គ្រាមកំបាំង . . . . . . . . . ឃុនបណ្ណានុរ័ក្ស ប៊ូ-ប៉ូ . . . . . ៩១៣
— សាលារៀននៅប្រទេសជប៉ុន . . . . អ្នកស្រី សារិះយ៉ាន . . . . . ៩២០
— រឿងសាមកុក (តមក) . . . . . . ឧកញ៉ា នូ-កន . . . . . . . ៩៣១
— ដំណឹងតាមខ្យល់ក្នុងកន្តារៈ (តះក) . លោក ផេង-ជ្រីវ . . . . . . ៩៣៩
— រឿងបល្ល័ង្កទិព្យ (តមក) . . . . . លោក រ៉ាយ-ប៊ុក . . . . . . ៩៤៧

### កំណត់និងប្រវត្តិការណ៍

— ពិធីបំបួសកុលបុត្រជាតិបារាំងសែសម្នាក់
នៅវត្តឧណ្ណាលោម . . . . . . . . . ពុទ្ធសាសនបណ្ឌិត្យ . . . . . . ៩៥៤

មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃជាវ ២១០រ,០០

# KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique

## TABLE DES MATIÈRES

### PARTIE RELIGIEUSE:


| | | Page |
|---|---|---|
| — Macchariya ou l'Avarice . . . | *Vén.* KEM-TO . . . . . . | 883 |
| — Cittakatha . . . . . . . . . | *Brah Balat* SONC-SIV . . | 890 |
| — Pannasajataka-vol. 4 (suite.) . | M. CHHIM-SOUM . . . . | 905 |


### PARTIE LITTERAIRE:


| | | |
|---|---|---|
| — La lutte psychologique . . . | M. BOU-PO . . . . . . . | 913 |
| — L'éducation au Japon . . . . | Mme SRIN-SARIS-YANN . | 920 |
| — Histoire de SAMKOK (suite) . . | Okhna NOU-KAN. . . . . | 931 |
| — Le souffle du désert (suite) . | M. PHENG-CHRIV . . . | 939 |
| — Les trente deux récits du TRONE (suite) . . . . . . . | M. RAY-BUC . . . . . . | 947 |


### NOTES ET CHRONIQUES:


| | | |
|---|---|---|
| — Cérémonie d'ordination d'un bonzé français à la pagode d'Unnalom . . . . . . . | *Institut Bouddhique* . . . . | 954 |


Prix d'abonnement annuel (comprenant 12 numéros) 210$00

## ផ្នែកសាសនា

### មច្ឆរិយៈ គឺអ្វី?

ព្រះទេពសត្ថា **កិម-គួ** បន្ទមង្គលោ

ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ

*រៀបរៀង*

---

មច្ឆរិយៈ គឺ សេចក្ដីកំណាញ់ ៗ សេចក្ដីកំណាញ់នេះ មានដំណើរដែលគួរឲ្យសង្កេតដឹង ៣ យ៉ាង គឺ មានការលាក់លៀមទុកនូវសម្បត្តិរបស់ខ្លួនជាលក្ខណៈ ១ មានការមិនចេះអត់ធន់ចំពោះសម្បត្តិរបស់ខ្លួនដែលសាធារណៈដល់ជនដទៃជាកិច្ច ១ មានការជួរមុខ ឬ ស្ញួញមុខ ចំពោះសម្បត្តិរបស់ខ្លួនដែលជាប់បង់ទៅជាផល ឬ គ្រឿងប្រាកដ១ ៗ មច្ឆរិយៈនេះមានប្រភេទចែកចេញជា ៥ យ៉ាង គឺ:

១ – អាវាសមច្ឆរិយ សេចក្ដីកំណាញ់អាវាស

២ – កុលមច្ឆរិយ សេចក្ដីកំណាញ់ត្រកូល

៣ – លាភមច្ឆរិយ សេចក្ដីកំណាញ់លាភ

៤ – វណ្ណមច្ឆរិយ សេចក្ដីកំណាញ់ការសរសើរ

៥ – ធម្មមច្ឆរិយ សេចក្ដីកំណាញ់ធម៌

មច្ឆរិយៈ ទាំង ៥ យ៉ាងនេះ ពិតមែនតែព្រះសម្មាសម្ពុទ្ធទ្រង់សំដែងចំពោះបព្វជិត (អ្នកបួស) ក្នុងព្រះពុទ្ធសាសនា ប៉ុន្តែគ្រហស្ថ (អ្នកគ្រប់គ្រងផ្ទះ) អាចផ្ទេរសេចក្តីនោះមកជាវត្តសម្រាប់ប្រតិបត្តិចំពោះខ្លួនផងដែរ ដូចសេចក្តីអធិប្បាយជាលំដាប់តទៅនេះ :

អាវាសមច្ឆរិយ = សេចក្តីកំណាញ់អាវាស, អាវាស (វត្ត) ជាទីនៅរបស់សង្ឃទាំងមូលក្តី ទីបរិវេណ (ថែវ) ក្តី បន្ទប់មួយ ៗ ក្តី ទីផ្សេង ៗ ក្តី មានកុដិសាលាសម្រាប់សម្រាកនៅក្នុងវេលាយប់ជាដើមក្តី ទីទាំងអស់នេះហៅថា អាវាស ។ មួយទៀត ភិក្ខុទាំងឡាយនៅជាសុខ ទាំងបានទទួលបច្ច័យទាំងឡាយក្នុងទីណា ទីនោះក៏ហៅថា អាវាស ដែរ ។ ភិក្ខុដទៃឯណាដែលជាអ្នកប្រាជ្ញបេះដឹងក្តី ជាអ្នកកាន់សីលជាទីស្រឡាញ់ និងបរិបូណ៌ដោយវត្តប្រតិបត្តិល្អក្តី ភិក្ខុណាមួយហួងហែងអាវាសមិនចង់ឲ្យភិក្ខុនោះចូលមកកាន់អាវាសរបស់ខ្លួនឡើយ ឬមានគំនិតគិតថា "ភិក្ខុដែលមកហើយ ចូរត្រឡប់ចេញទៅវិញឆាប់ៗ" យ៉ាងនេះជាដើម ភិក្ខុនោះឈ្មោះថា ជាអ្នកកំណាញ់អាវាស ។ ប៉ុន្តែបើបែរជាមិនចង់ឲ្យពួកភិក្ខុអលជ្ជី (អ្នកមិនមានសេចក្តីអៀនខ្មាស) ដែលមានមារយាទអាក្រក់ ជាអ្នកហែបង្កហេតុមានជំលោះជាដើម ចូលមកនៅក្នុងអាវាសនោះទេ មិនហៅថាអ្នកកំណាញ់អាវាសឡើយ ។

កុលមច្ឆរិយ = សេចក្តីកំណាញ់ត្រកូល, ត្រកូលនៃជនជាឧបដ្ឋាកក្តី ត្រកូលនៃជនជាញាតិ ឬជាសាលោហិតក្តី ហៅថា ត្រកូល

កន្ទីនេះ ។ ភិក្ខុមិនចង់ឲ្យបុគ្គលដទៃចូលទៅកាន់ត្រកូលនោះៗ ទេ ហៅថាជាអ្នកកំណាញ់ត្រកូល ប៉ុន្តែបើមិនចង់ឲ្យបុគ្គលអាក្រក់មានគំនិតវេញវេញចូលទៅកាន់ត្រកូលនោះ ក៏មិនហៅថាជាអ្នកកំណាញ់ត្រកូលឡើយ ព្រោះបុគ្គលអាក្រក់នោះ កាលបើចូលទៅហើយរមែងធ្វើត្រកូលនោះឲ្យខូចសទ្ធានិងសេចក្ដីជ្រះថ្លា ។ តែបើបុគ្គលណាចូលទៅហើយ អាចរក្សាសទ្ធានិងសេចក្ដីជ្រះថ្លារបស់ត្រកូលនោះឲ្យនៅគង់វង្សដដែល ឬ អាចញ៉ាំងត្រកូលនោះឲ្យចំរើនដោយគុណមានសីលគុណជាដើម ហើយមិនចង់ឲ្យបុគ្គលនោះចូលទៅកាន់ត្រកូលនោះទេ ឈ្មោះថាជាអ្នកកំណាញ់ត្រកូល ។

លាភមច្ឆរិយ=សេចក្ដីកំណាញ់លាភ,បច្ច័យគឺរបស់សម្រាប់បរិភោគប្រើប្រាស់ទាំង ៤ យ៉ាងមានចីវរនិងបិណ្ឌបាតជាដើម ហៅថាលាភ កន្ទីនេះ ។ កាលបើភិក្ខុដទៃជាអ្នកមានសីល ឬជាអ្នកមានវត្តប្រតិបត្តិល្អ ដែលត្រូវបានទទួលលាភនោះ ភិក្ខុណាមានគំនិតគិតថា សូមកុំឲ្យលោកនោះបានទទួលលាភនោះឡើយ ភិក្ខុនោះឈ្មោះថាជាអ្នកកំណាញ់លាភ ។ ប៉ុន្តែបើភិក្ខុណាធ្វើសទ្ធារបស់ទាយកឲ្យថយចុះ ឬ ឲ្យខូចដោយអំណាចដែលបានរបស់ផ្សេងៗ មានគ្រឿងឧបភោគនិងគ្រឿងបរិភោគជាដើម មកទុកដាក់ហួងហែងមិនបរិភោគប្រើប្រាស់ដោយខ្លួនឯង ទាំងមិនចែករំលែកឲ្យអ្នកដទៃផងទៀត របស់ទាំងនោះក៏ពុកផុយស្អុយរលួយអស់ទៅ ភិក្ខុឯទៀតឃើញភិក្ខុនោះប្រព្រឹត្តដូច្នេះ ក៏គិតថា

ភិក្ខុនេះមិនគប្បីបាននូវវត្ថុនេះឡើយ, ភិក្ខុដទៃជាអ្នកមានសីលគប្បីបាននូវវត្ថុនេះបរិភោគប្រើប្រាស់ចុះ ដូច្នេះជាដើមវិញ ភិក្ខុនោះឈ្មោះថាជាអ្នកមិនកំណាញ់លាភទេ ។

វណ្ណមច្ឆរិយ = សេចក្តីកំណាញ់ការសរសើរ, ការនិយាយសរសើរសរីរៈក្តី ការនិយាយសរសើរគុណក្តី ហៅថា ការសរសើរក្នុងទីនេះ ។ ភិក្ខុអ្នកកំណាញ់ការនិយាយសរសើរសរីរៈនោះ កាលបើមានអ្នកណាមួយនិយាយសរសើរជនដទៃថា អ្នកឯណោះគេមានរូបរាងល្អសមរម្យទាំងសម្បុរសាច់ឈាមក៏ស្អាតបាត គួរជាទីជ្រះថ្លាណាស់ យ៉ាងនេះជាដើម ភិក្ខុនោះក៏អាក់អន់ចិត្ត មិនចង់និយាយចូលជាមួយនឹងជននោះតទៅទៀត នេះហៅថា អ្នកកំណាញ់ការនិយាយសរសើរសរីរៈ ។ ឯភិក្ខុអ្នកកំណាញ់ការនិយាយសរសើរគុណនោះ គឺមិនចង់ឲ្យឮអំពីអ្នកណាមួយនិយាយសរសើរគុណសម្បត្តិរបស់អ្នកដទៃ ឬកាលបើមានគេនិយាយសរសើរជនដទៃចំពោះមុខខ្លួនថា ភិក្ខុឯណោះ ឬឧបាសកឯណោះ មានសីលបរិសុទ្ធល្អ, ប្រព្រឹត្តកាន់ធុតង្គតឹងរឹងល្អ, មានសេចក្តីប្រតិបត្តិល្អ មានចរិយាឫកពាសណ្តាប់ធ្នាប់ល្អ មានការចេះដឹងច្រើន យ៉ាងនេះជាដើម ភិក្ខុនោះមិនចង់ឲ្យគេនិយាយសរសើរអំពីគុណសម្បត្តិរបស់អ្នកដទៃ ទាំងខ្លួនឯងក៏មិនចង់និយាយសរសើរដូច្នោះដែរ លោកហៅថា អ្នកកំណាញ់ការនិយាយសរសើរគុណ ។

ធម្មមច្ឆរិយ=សេចក្ដីកំណាញ់ធម៌, ពាក្យថា ធម៌ ក្នុងទីនេះ សំដៅយកបរិយត្តិធម៌ និងបដិវេធធម៌ ។ អរិយសាវកទាំងឡាយ មិនកំណាញ់នូវបដិវេធធម៌ទេ លោកចង់ឲ្យមនុស្សលោកព្រមទាំងទេវលោក បានត្រាស់ដឹងធម៌ ដែលខ្លួនលោកបានត្រាស់ដឹងហើយនោះដែរ មិនតែប៉ុណ្ណោះលោកចង់ឲ្យអ្នកដទៃចេះយល់នូវបដិវេធធម៌នោះផងទៀត និងមិនបាច់និយាយថ្វីដល់ទៅបរិយត្តិធម៌នោះ ។ ភិក្ខុណា ចេះដឹងធម៌អាថ៌ហើយ មិនចង់សំដែងប្រាប់ដល់បុគ្គលដទៃ ដោយគិតខ្លាចក្រែងគេចេះដឹងលើសខ្លួន ឬស្មើនឹងខ្លួនក្ដី កាលបើមានគេត្រូវការរកខ្ចីក្បួនច្បាប់គម្ពីរដីកាអ្វីយកទៅមើលរៀនសូត្រ ហើយមិនចង់ឲ្យគេខ្ចី ឬលាក់ទុក ដោយគិតខ្លាចគេរៀនសូត្រទៅមានការចេះដឹងលើសខ្លួន ឬស្មើនឹងខ្លួនក្ដី ភិក្ខុនោះឈ្មោះថាជាអ្នកកំណាញ់ធម៌ ។ ប៉ុន្តែបើមិនចង់សំដែងប្រាប់ ឬ មិនចង់ឲ្យខ្ចីគម្ពីរដីកា ដោយយល់ឃើញច្បាស់ថា មនុស្សនោះជាអ្នកបិញរបុញមានចិត្តសាវ៉ា មិនចេះថែទាំទុកដាក់បើទុកជាអាត្មាអញសំដែងប្រាប់ ឬឲ្យខ្ចីទៅ ក៏មិនយកចិត្តទុកដាក់រក្សាគោរពប្រតិបត្តិតាមធម៌នោះដែរ ភិក្ខុនោះមិនឈ្មោះថាជាអ្នកកំណាញ់ធម៌ឡើយ ។ មួយទៀត ភិក្ខុណាមិនសំដែងប្រាប់ ព្រោះពិចារណាឃើញនូវបុគ្គល ហើយអនុគ្រោះដល់ធម៌ ឬ មិនសំដែងប្រាប់ ព្រោះពិចារណាឃើញនូវធម៌ហើយអនុគ្រោះដល់បុគ្គល ភិក្ខុនេះមិនឈ្មោះថាជាអ្នកកំណាញ់ធម៌ទេ, បានសេចក្ដីថា បុគ្គលខ្លះជាអ្នកបិញរបុញមានចិត្តសាវ៉ា ដូនកាលធ្វើជាសមណៈ

ជូនកាលធ្វើជាព្រាហ្មណ៍ ជូនកាលធ្វើជានិគ្រន្ថ ភិក្ខុណាមិនសំដែងប្រាប់ដោយដឹងថា បុគ្គលនេះ កាលបើអាត្មាអញសំដែងធម៌ប្រាប់ទៅ មុខជានឹងបំបែកបំផ្លាញនូវធម៌ដ៏ល្អិតសុខុម ជាធម៌មានបែបផែនល្អជាប់ជាបវេណីមកឲ្យល្អក់កករខូចពុំខាន ហើយមិនសំដែងប្រាប់ព្រោះពិចារណាឃើញនូវបុគ្គលហើយអនុគ្រោះដល់ធម៌ ភិក្ខុនេះឈ្មោះថាជាអ្នកមិនកំណាញ់ធម៌ឡើយ ។ ភិក្ខុណាមិនសំដែងប្រាប់ដោយដឹងថា ធម៌នេះល្អិតសុខុមល្អណាស់ ប្រសិនបើបុគ្គលនេះរៀនទៅ មុខជានឹងព្យាករគឺពោលអួតមគ្គផល ហើយលើកតំកើងខ្លួនឯងថាជាបុគ្គលវិសេសនឹងដល់នូវសេចក្ដីវិនាសខ្លួនពុំខាន ហើយមិនសំដែងប្រាប់ព្រោះពិចារណាឃើញច្បាស់នូវធម៌ហើយអនុគ្រោះដល់បុគ្គល ភិក្ខុនេះឈ្មោះថាជាអ្នកមិនកំណាញ់ធម៌ឡើយ ។ មួយទៀត បុគ្គលណា ជាអ្នកមានចិត្តស្មោះត្រង់ប្រាថ្នាចង់ចេះចង់ដឹង ដើម្បីនឹងយកធ្វើជាវត្តប្រតិបត្តិរបស់ខ្លួនដោយពិត ភិក្ខុមិនសំដែងប្រាប់ឬមិនឲ្យដោយគិតខ្លាចថា បុគ្គលនេះបើនឹងឲ្យរៀនធម៌នេះទៅ មុខជានឹងបានចេះដឹងហើយនឹងថ្កោលទោសឬបំបែកនូវលទ្ធិរបស់អាត្មាអញវិញពុំខាន ភិក្ខុនេះទើបឈ្មោះថាជាអ្នកកំណាញ់ធម៌ ។

## ទោសនៃសេចក្ដីកំណាញ់

បណ្ដាសេចក្ដីកំណាញ់ទាំង៥យ៉ាង ដូចដែលបានពោលមកហើយនោះ សេចក្ដីកំណាញ់អាវាស ជាទោសនាំបុគ្គលអ្នកកំណាញ់នោះឲ្យទៅកើតជាយក្សឬជាប្រេតទូលទៅសំរាមក្នុងអាវាសដែលខ្លួនធ្លាប់នៅនោះ ។

សេចក្ដីកំណាញ់ត្រកូល ជាទោសនាំបុគ្គលអ្នកកំណាញ់នោះឲ្យរងទុក្ខ, បុគ្គលនោះកាលបើឃើញជនដទៃគេកំពុងឲ្យទាន ឬគេរាប់អានគ្នាជាដើម ក្នុងត្រកូលនោះ ក៏ប៉ះជាគិតថាត្រកូលរបស់អាត្មាអញនេះបែកបាក់គ្នាហើយតើ! ក៏ក្អួតឈាមចេញអំពីមាត់ខ្លះ ឈឺពោះចុះរាកខ្លះ ពោះវៀនដាច់ជាកំណាត់តូចកំណាត់ធំលៀនចេញមកខាងក្រៅខ្លះ ។ សេចក្ដីកំណាញ់លាភ ជាទោសនាំបុគ្គលអ្នកកំណាញ់នោះឲ្យទៅកើតជាយក្សឬជាប្រេត ឬជាពស់ថ្លាន់ បរិភោគតែរបស់ជាដែលនៃជនដទៃ ។ ការកំណាញ់សេចក្ដីសរសើរសរីរៈ នឹងការកំណាញ់សេចក្ដីសរសើរគុណ ជាទោសនាំបុគ្គលអ្នកកំណាញ់នោះ ឲ្យទៅកើតជាមនុស្សមានសម្បុរអាក្រក់ផង ជាមនុស្សល្ងីល្ងើផង ។ សេចក្ដីកំណាញ់ធម៌ ជាទោសនាំបុគ្គលអ្នកកំណាញ់នោះឲ្យទៅកើតជាមនុស្សមានសម្បុរអាក្រក់ឬជាមនុស្សល្ងីល្ងើ ។

ន័យមួយទៀត សេចក្ដីកំណាញ់អាវាស ជាទោសនាំបុគ្គលអ្នកកំណាញ់នោះឲ្យទៅឆេះនៅក្នុងលោហនរក ។ សេចក្ដីកំណាញ់ត្រកូលជាទោសនាំបុគ្គលអ្នកកំណាញ់នោះឲ្យទៅកើតជាមនុស្សខ្សត់ខ្សោយលាភ ។ សេចក្ដីកំណាញ់លាភ ជាទោសនាំបុគ្គលអ្នកកំណាញ់នោះឲ្យទៅកើតក្នុងគូថនរក ។ ការកំណាញ់សេចក្ដីសរសើរ ជាទោសនាំបុគ្គលអ្នកកំណាញ់នោះឲ្យទៅកើតជាមនុស្សមានសម្បុរអាក្រក់ ។ –សេចក្ដីកំណាញ់ធម៌ ជាទោសនាំបុគ្គលអ្នកកំណាញ់នោះឲ្យកើតក្នុងនរក ។

# ចិត្តកថា

ព្រះបាឡាត់ឧត្តមលិខិត ស៊ុង-ស៊ីវ វត្តលង្កា ភ្នំពេញ

រៀបរៀង

---

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

សូមនមស្សការ ចំពោះព្រះភគវន្តមុនី អរហំ សម្មាសម្ពុទ្ធ ព្រះអង្គនោះ (ព្រមទាំងព្រះធម៌នឹងព្រះអរិយសង្ឃដោយសេចក្ដីគោរព) ។

វេលានេះ អាត្មាភាព សូមសំដែងនូវពុទ្ធភាសិតមួយកន្លែង ដែលព្រះបរមគ្រូសម្ពុទ្ធ ទ្រង់សំដែងចំពោះព្រះចក្ខុបាលត្ថេរ មាននៅក្នុងសុត្តន្តបិដក គម្ពីរខុទ្ទកនិកាយ. ជាធម្មស្សវនាការដូចតទៅនេះ ។

ពុទ្ធភាសិតនោះថា:

មនោបុព្វង្គមា ធម្មា មនោសេដ្ឋា មនោមយា
មនសា ចេ បទុដ្ឋេន ភាសតិ វា ករោតិ វា
តតោ នំ ទុក្ខមន្វេតិ ចក្កំវ វហតោ បទំ ។

សេចក្ដីថា: ធម៌ទាំងឡាយ មានចិត្តជាប្រធាន មានចិត្តប្រសើរដោយវិសេស សម្រេចហើយដោយចិត្ត បើបុគ្គលណា មានចិត្តដែលទោសប្រទូស្តហើយ ទោះពោលក្ដី ធ្វើក្ដី (គិតក្ដី) នូវទុច្ចរិតទាំងបីប្រការ, ផលជាទុក្ខតែងជាប់តាមបុគ្គលនោះ ព្រោះអំពើទុច្ចរិតទាំងបីប្រការនោះឯង ដូចជាកង់រទេះ ដែលវិលទៅតាមជើងគោ កាលកំពុងនាំទៅនូវនឹម ។

ពុទ្ធភាសិតនេះ ជាគូនឹងពុទ្ធភាសិតមួយកន្លងទៀត ដែលព្រះបរមគ្រូទ្រង់សំដែងចំពោះមដ្ឋកុណ្ឌលីទេវបុត្រ មាននៅក្នុងគម្ពីរខុទ្ទក-និកាយនោះដែរ ។ ពុទ្ធភាសិតនោះថា:

មនោបុព្វង្គមា ធម្មា មនោសេដ្ឋា មនោមយា
មនសា ចេ បសន្នេន ភាសតិ វា ករោតិ វា
តតោ នំ សុខមន្វេតិ ឆាយាវ អនុបាយិនី ។

សេចក្តីថា ធម៌ទាំងឡាយមានចិត្តជាប្រធាន មានចិត្តប្រសើរដោយវិសេស សម្រេចហើយដោយចិត្ត បើបុគ្គលណាមានចិត្តជ្រះថ្លាហើយ ទោះពោលក្តី ធ្វើក្តី ( នឹកក្តី ) នូវអំពើសុចរិតទាំងបីប្រការ, ផលជាសុខតែងជាប់តាមបុគ្គលនោះ ព្រោះអំពើសុចរិតទាំងបីប្រការនោះឯង ដូចស្រមោលតែងអន្ទោលតាមអង្គភាព ។

រួបរួមសេចក្តីក្នុងនៃពុទ្ធភាសិតទាំងពីរនេះ ឲ្យឃើញមកនៅត្រឹមតែពីរយ៉ាងគឺ: បានទុក្ខក៏ព្រោះចិត្ត បានសុខក៏ព្រោះចិត្ត ។

សូមអធិប្បាយអំពីពាក្យថា ចិត្ត នេះជាមុន ។

ចិត្ត – សព្ទនេះប្រែថា ''ធម្មជាតសម្រាប់សន្សំអារម្មណ៍, សម្រាប់គិត, សម្រាប់ជ្រើសរើសនូវអារម្មណ៍'' គឺធម្មជាតល្អិតប្រកបដោយបរមាណុភាពល្អិតយ៉ាងក្រៃលែង ឥតមានរូបរាងសណ្ឋានទ្រង់ទ្រាយឡើយ, គ្រាន់តែជានាមធម៌ម្យ៉ាង, បើនិយាយខាងបញ្ញត្តក៏គឺវិញ្ញាណនោះឯង, ជារបស់ប្រែប្រួលឃ្លេងឃ្លោង, ក្រឡាប់ក្រឡកទៅមក

ដោយឆាប់រហ័សចួន កាលយ៉ាងនេះ ចួនកាលយ៉ាងនោះ បានជាលោកសំដែងអំពីប្រភេទរបស់ចិត្ត ក្នុងគម្ពីរព្រះអភិធម្ម ដោយពិស្ដារថា មាន ១២១ ចិត្ត, ដោយសង្ខេប មាន ៨៩ ចិត្ត ។ ប៉ុន្តែចិត្តនេះជាធម្មជាតតែមួយទេ, ដែលបានជាច្រើនដូច្នោះ ព្រោះបែកតាមប្រភេទនៃការប្រព្រឹត្តទៅ, កាលបើប្រព្រឹត្តទៅយ៉ាងណា ក៏ឲ្យឈ្មោះតាមអាការៈដែលប្រព្រឹត្តទៅយ៉ាងនោះ ។

ចិត្តនេះជាធម្មជាតមិនរើសអារម្មណ៍; ក៏ក្នុងអារម្មណ៍ទាំង ៦ នោះ តាមតែអារម្មណ៍ណាក៏ដោយ ចិត្តតែងត្រូវការគិត, ត្រូវការដឹង, ត្រូវការសន្សំទាំងអស់; បើរូបារម្មណ៍មកកាន់រង្វង់ភ្នែកហើយ ចិត្តក៏កើតឡើងភ្លាមទទួលឃើញ, ទទួលដឹងថានេះរូប; បើសទ្ទារម្មណ៍, គន្ធារម្មណ៍, ផោដ្ឋព្វារម្មណ៍, ធម្មារម្មណ៍, ចូលមកកាន់រង្វង់ត្រចៀក, ច្រមុះ, អណ្ដាត, កាយ, ចិត្តហើយ វិថីចិត្ត ក៏កើតឡើងភ្លាម ទទួលឮ, ទទួលហិត, ជញ្ជក់ជញ្ជាប, គិត, ដឹងថា នេះសំឡេង, នេះក្លិន, នេះរស, នេះសម្ផស្ស, នេះធម៌ ដោយពិតឥតមានអាក់ខានឡើយ ។

ត្រង់ពាក្យថា "បានទុក្ខ ក៏ព្រោះចិត្ត បានសុខក៏ព្រោះចិត្ត" នោះ អធិប្បាយថា: បុគ្គលនឹងធ្វើកិច្ចការអ្វី ៗ ដោយកាយក្ដី ដោយវាចាក្ដី ក៏ព្រោះចិត្តរិះគិតផ្ដើមឡើងជាមុនទើបធ្វើបាន, កាលបើចិត្តគិតខុសហើយ កិច្ចការនោះ ៗ ក៏មិនល្អ, ថែមទាំងមានសេចក្ដីទុក្ខកើតឡើងផង; បើចិត្តរិះគិតត្រូវ ទើបមានផលល្អ ជាគុណឲ្យបានសេចក្ដីសុខចំរើនដល់ខ្លួន ។ ព្រោះកម្មគឺអំពើដែលសត្វធ្វើគ្រប់យ៉ាង ដែលនឹងមានផលក្សៀវ

គ្នា ក៏អាស្រ័យទីវេទនា, ឯចេតនាគឺជាតួកម្ម, បានជាព្រះមានព្រះភាគទ្រង់សំដែងថា ចេតនាហំ ភិក្ខវេ កម្មំ វទាមិ ម្នាលភិក្ខុទាំងឡាយ តថាគតតែងថា ចេតនា ជាតួកម្ម ។

កាលបើសត្វទាំងឡាយធ្វើអំពើណាមួយប្រកបដោយសេចក្តីលោភ, សេចក្តីក្រោធ, សេចក្តីវង្វេង អំពើនោះចាត់ជាអកុសលកម្ម ។ កម្មទាំងពីរនេះឲ្យផលផ្សេងគ្នា គឺកុសលកម្មឲ្យផលជាសុខ, អកុសលកម្មឲ្យផលជាទុក្ខ ។ បានជាមានភាសិតមួយកន្លែង លោកសំដែងប្រៀបកម្មធៀបគ្នានឹងការបណ្តុះពូជវត្ថុទាំងពូងថា :

យាទិសំ វប្បតេ ពីជំ តាទិសំ លភតេ ផលំ
កល្យាណការី កល្យាណំ បាបការី ច បាបកំ ។

សេចក្តីថា: មនុស្សក្នុងលោក គេសាបព្រោះបណ្តុះពូជបែបណា, តែងដុះកើតបានជាដើមបញ្ចេញផ្លែមកជាបែបនោះវិញ មានឧបមាដូចម្តេចមិញ; កល្យាណជនអ្នកធ្វើអំពើល្អតែងបានល្អ, បាបជនអ្នកធ្វើអំពើអាក្រក់តែងបានអាក្រក់ មានឧបមេយ្យដូច្នោះដែរ ។

ភាសិតនេះសំដែងចុចបំផុតសេចក្តីឲ្យឃើញថា: បើសត្វណាបានធ្វើអំពើល្អ ឬអាក្រក់, អំពើនោះឯង ក៏បែងចែករំលែកឲ្យសត្វនោះៗបានល្អ ឬអាក្រក់តាមបែបដែលធ្វើ; អំពើអាក្រក់នាំសត្វទៅកាន់ទុគ្គតិ, អំពើល្អនាំសត្វទៅកាន់សុគតិ ។ ទាំងនេះក៏សម្រេចមកតែអំពីចិត្តជាប្រធានាំភាពជាមុនទាំងអស់ ។

សូមលើកឧទាហរណ៍ ជាបុគ្គលាធិដ្ឋានមកសំដែងឲ្យឃើញផល របស់អំពើល្អនិងអំពើអាក្រក់ ដូចតទៅនេះ ។

អំពើល្អឲ្យផលជាសុខ, ដូចរឿងធម្មិកឧបាសកៈ, ធម្មិកឧបាសក នោះ ជាអ្នកបរិបូណ៌ដោយកល្យាណធម៌ច្រើនយ៉ាង, វេលាមានជម្ងឺ ទៀបនឹងដល់មរណៈ ឲ្យកូនទៅនិមន្តភិក្ខុទាំងឡាយមកស្វាធ្យាយសតិ-បដ្ឋានសូត្រ; កំពុងតែស្តាប់ធម៌, បានឃើញទេវតាក្នុងឆកាមាវចរសួគ៌ ទាំង ៦ ជាន់ យកនូវរថ ៦ មកអញ្ជើញ ឲ្យទៅកើតក្នុងពិភពរបស់ ខ្លួន ៗ ។ ធម្មិកឧបាសកលុះច្យុតពីមនុស្សលោកនេះទៅ បានទៅ កើតក្នុងតុសិតសួគ៌ ។ នេះក៏មកតែពីចិត្តដែលយល់ត្រូវ ហើយបានធ្វើ អំពើល្អៈទើបបានផលជាសុខយ៉ាងនេះ ។

អំពើអាក្រក់ឲ្យផលជាទុក្ខ, ដូចរឿងប្រេតទាំង ១០ នាក់ ដែលរង ទុក្ខវេទនា នៅក្បែរភ្នំគិជ្ឈកូដ, រឿងនេះមានសំដែង នៅក្នុងគម្ពីរសំយុត្ត-និកាយ ត្រង់លក្ខណសំយុត្ត អដ្ឋិសង្ខលិកវគ្គ; ក្នុងសូត្រនោះសំដែងថាៈ

សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅវត្តវេឡុវន ជិតក្រុង រាជគ្រឹះ ។ សម័យនោះឯង, ព្រះមោគ្គល្លានត្ថេរ និងព្រះលក្ខណត្ថេរ គង់នៅលើភ្នំគិជ្ឈកូដ ។

ថ្ងៃមួយ ព្រះថេរៈទាំងពីរអង្គ នាំគ្នាចុះពីភ្នំគិជ្ឈកូដ ក្នុងបុព្វណ្ហ-សម័យ ដើម្បីទៅបិណ្ឌបាតឯក្រុងរាជគ្រឹះ ។ កាលដែលកំពុងចុះពីភ្នំ នោះ, ព្រះមោគ្គល្លានបានឃើញប្រេតទាំង ១០ នាក់កំពុងរងទុក្ខវេទនា; លោកក៏បានធ្វើនូវការញញឹម ។ ព្រះលក្ខណត្ថេរ ឃើញព្រះមោគ្គល្លាន

ញញឹមដូច្នោះ ក៏សួរថា ម្នាលអាវុសោ, ហេតុដូចម្តេចបានជាលោក ញញឹម? ព្រះមោគ្គល្លានតបថា: ម្នាលអាវុសោ, កាលនេះខ្ញុំគួរប្រាប់លោកទេ, លោកចាំសួរខ្ញុំក្នុងទីចំពោះព្រះភ័ក្ត្រព្រះសាស្តាចុះ ។

លុះត្រឡប់មកពីបិណ្ឌបាតវិញ, ក្នុងវេលាក្រោយភត្ត, ព្រះថេរទាំងពីរអង្គ ក៏ចូលទៅគាល់ព្រះមានព្រះភាគ, ថ្វាយបង្គំហើយអង្គុយក្នុងទីដ៏សមគួរ ។ ព្រះលក្ខណត្ថេរ ក៏សួរព្រះមោគ្គល្លានថា: ហេតុដូចម្តេចបានជាលោកញញឹមក្នុងកាលនោះ? ព្រះមោគ្គល្លានប្រាប់ថា ក្នុងកាលនោះខ្ញុំបានឃើញប្រេត ១០ នាក់មានអាការប្លែកៗ គ្នា គឺ:

ទី ១ – ខ្ញុំឃើញអដ្ឋិសង្ខលិក គឺរាងឆ្អឹងកំពុងអណ្តែតទៅតាមអាកាស, ពួកត្មាត ក្អែក រអាតដេញតាមចាប, ចោមចិកចោះ, កើចដញ្ញែងនូវរាងឆ្អឹងទាំងនោះ; រាងឆ្អឹងនោះចេះតែស្រែកថ្ងូរ; ម្នាលអាវុសោ ទើបខ្ញុំគិតថា អើ! ហ្ន៎! អស្ចារ្យណាស់, យីអើ! មិនធ្លាប់ឃើញសោះ យីអើ! ការបានអត្តភាពបែបនេះមានដែរតើ; ដោយហេតុនេះបានជាខ្ញុំញញឹម ។

គ្រានោះឯង ព្រះមានព្រះភាគត្រាស់ហៅភិក្ខុទាំងឡាយថា: ម្នាលភិក្ខុទាំងឡាយ, សត្វនោះ តថាគត ធ្លាប់ឃើញមកអំពីមុនដែរ, ប៉ុន្តែតថាគត មិនទាន់សំដែង ព្រោះថាបើតថាគតសំដែងរឿងសត្វនុ៎ះទៅជនទាំងឡាយណាដែលមិនជឿពាក្យតថាគត, សេចក្តីមិនជឿរបស់ជនទាំងនោះនឹងនាំឲ្យខានបានប្រយោជន៍, នាំឲ្យបានតែសេចក្តីទុក្ខអស់កាលជាយូរអង្វែង; ប៉ុន្តែវេលានេះ សាវ័ករបស់តថាគតមានចក្ខុបានឃើញដែរហើយ ។

លំដាប់នោះ ព្រះមានព្រះភាគទ្រង់សំដែងប្រាប់ផលកម្មរបស់សត្វនោះថា ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះ, កាលពីដើមជាគោឃាដក: គឺអ្នកសម្លាប់គោ នៅក្នុងក្រុងរាជគ្រឹះនេះឯង; ដោយវិបាករបស់កម្មនោះ ក៏ទៅឆេះក្នុងនរកអស់សែននៃឆ្នាំជាច្រើន, សេសសល់ពីវិបាកនៃកម្មនោះ, ក៏ត្រឡប់មកបានអត្តភាពបែបនេះឯង ។

ព្រះមោគ្គល្លានប្រាប់ព្រះលក្ខណត្ថេរតទៅទៀតថា:

ទី ២ – ខ្ញុំបានឃើញ មំសបេសិ គឺចំរៀកសាច់ កំពុងអណ្តែតទៅតាមអាកាស, ពួកត្មាត ក្អែក ស្រាត ដេញតាមឆាប, ចោមចិកចោះហើយដណ្តើមនូវចំរៀកសាច់នោះ ចំរៀកសាច់នោះក៏ចេះតែស្រែកថ្ងូរ ។

លំដាប់នោះ ព្រះមានព្រះភាគទ្រង់សំដែងប្រាប់បុព្វកម្មរបស់សត្វនោះទៀតថា: ម្នាលភិក្ខុទាំងឡាយ, សត្វនុ៎ះ កាលពីដើមជាគោឃាដក: គឺអ្នកសម្លាប់គោ នៅក្នុងក្រុងរាជគ្រឹះនេះឯង ។

ព្រះមោគ្គល្លានប្រាប់ព្រះលក្ខណត្ថេរតទៅទៀតថា:

ទី ៣ – ខ្ញុំបានឃើញ មំសបិណ្ឌ: គឺដុំសាច់កំពុងអណ្តែត ទៅតាមអាកាស, ពួកត្មាត ក្អែក ស្រាត ដេញតាមឆាប, ចោមចិកចោះហើយដណ្តើមនូវដុំសាច់នោះ ដុំសាច់នោះក៏ចេះតែស្រែកថ្ងូរ ។

លំដាប់នោះព្រះមានព្រះភាគ ទ្រង់សំដែងប្រាប់បុព្វកម្មរបស់សត្វនោះទៀតថា: ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះកាលពីដើមជាព្រានបក្សី នៅក្នុងក្រុងរាជគ្រឹះនេះឯង ។ ដោយវិបាករបស់កម្មនោះ ក៏ទៅឆេះក្នុង

នរកអស់សែនឆ្នាំជាច្រើន, សេសសល់វិបាករបស់កម្មនោះ ក៏ត្រឡប់មកបានអត្តភាពបែបនេះឯង ។

ព្រះមោគ្គល្លានប្រាប់ព្រះលក្ខណត្ថេរតទៅទៀតថា:

ទី ៤ – ខ្ញុំបានឃើញនិច្ឆវិបុរស គឺបុរសមិនមានស្បែកខាងក្រៅ កំពុងអណ្តែតទៅតាមអាកាស ពួកត្មាត - ក្អែក រអាត ដេញតាមចាប ៗចោមចឹកចោះ រើបដណ្តើមនូវបុរសគ្មានស្បែកនោះៗ ក៏ចេះតែស្រែកថ្ងូរ ។

លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់សំដែងប្រាប់បុព្វកម្មរបស់សត្វនោះទៀតថា: ម្នាលភិក្ខុទាំងឡាយ សត្វនុះកាលពីដើមជាអ្នកសម្លាប់ចៀមនៅក្នុងក្រុងរាជគ្រឹះនេះឯង ។ ដោយវិបាករបស់កម្មនោះ ក៏ទៅឆេះក្នុងនរកអស់សែនឆ្នាំជាច្រើន, សេសសល់វិបាករបស់កម្មនោះក៏ត្រឡប់មកបានអត្តភាពបែបនេះឯង ។

ព្រះមោគ្គល្លានប្រាប់ព្រះលក្ខណត្ថេរ តទៅទៀតថា

ទី ៥ – ខ្ញុំបានឃើញ អសិលោមបុរស គឺបុរសមានរោមដូចដាវ កំពុងអណ្តែតទៅតាមអាកាស, ដាវទាំងនោះក៏អណ្តែតធ្លាក់ៗ មកត្រូវកាយបុរសនោះៗ ក៏ចេះតែស្រែកថ្ងូរ ។

លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់សំដែងប្រាប់បុព្វកម្មរបស់សត្វនោះទៀតថា: ម្នាលភិក្ខុទាំងឡាយ សត្វនុះកាលពីដើមជាអ្នកសម្លាប់ជ្រូកនៅក្នុងក្រុងរាជគ្រឹះនេះឯង ។ ដោយវិបាករបស់កម្មនោះ ក៏ទៅឆេះក្នុងនរកអស់សែនឆ្នាំជាច្រើន, សេសសល់វិបាកនៃកម្មនោះ ក៏ត្រឡប់មកបានអត្តភាពបែបនេះឯង ។

ព្រះមោគ្គល្លានប្រាប់ព្រះលក្ខណត្ថេរតទៅទៀតថា:

ទី ៦ - ខ្ញុំបានឃើញ សត្តិលោមបុរស គឺបុរសមានរោមដូចលំពែងកំពុងអណ្តែតទៅតាមអាកាស, លំពែងទាំងនោះក៏អណ្តែតធ្លាក់ៗ មកត្រូវកាយបុរសនោះៗ ក៏បេះតែស្រែកថ្ងូរ ៗ

លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់សំដែងប្រាប់បុព្វកម្មរបស់សត្វនោះទៀតថា: ម្នាលភិក្ខុទាំងឡាយ, សត្វនុះ កាលពីដើមជាព្រានម្រឹគនៅក្នុងក្រុងរាជគ្រឹះនេះឯង ៗ ដោយវិបាករបស់កម្មនោះក៏ទៅឆេះក្នុងនរកអស់សែននៃឆ្នាំជាច្រើន សេសសល់វិបាកនៃកម្មនោះ ក៏ត្រឡប់មកបានអត្តភាពបែបនេះឯង ៗ

ព្រះមោគ្គល្លានប្រាប់ព្រះលក្ខណត្ថេរតទៅទៀតថា:

ទី ៧ - ខ្ញុំបានឃើញ ឧសុលោមបុរស គឺបុរសមានរោមដូចព្រួញកំពុងអណ្តែតទៅតាមអាកាស, ព្រួញទាំងនោះក៏អណ្តែតធ្លាក់ៗ មកត្រូវកាយបុរសនោះ ៗ ក៏បេះតែស្រែកថ្ងូរ ៗ

លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់សំដែងប្រាប់បុព្វកម្មរបស់សត្វនោះទៀត ថា: ម្នាលភិក្ខុទាំងឡាយ សត្វនុះ កាលពីដើមជាពេជ្ឈឃាដនៅក្នុងក្រុងរាជគ្រឹះនេះឯង ៗ ដោយវិបាករបស់កម្មនោះ ក៏ទៅឆេះក្នុងនរកអស់សែននៃឆ្នាំជាច្រើន សេសសល់វិបាកនៃកម្មនោះ ក៏ត្រឡប់មកបានអត្តភាពបែបនេះឯង ៗ

ព្រះមោគ្គល្លានប្រាប់ព្រះលក្ខណត្ថេរតទៅទៀតថា:

ទី ៨ - ខ្ញុំបានឃើញ សូចិលោមបុរស គឺបុរសមានរោមដូចដែក

ស្រួច កំពុងអណ្តែតតាមអាកាស, ដែកស្រួចទាំងនោះ ក៏អណ្តែតធ្លាក់ៗ មកត្រូវកាយបុរសនោះៗ ក៏ចេះតែស្រែកថ្ងូរ ។

លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់សំដែងប្រាប់បុព្វកម្មរបស់សត្វនោះទៀតថា ម្នាលភិក្ខុទាំងឡាយ, សត្វនុ៎ះ កាលពីដើមជាអ្នកបរ (បំបោល) គោ នៅក្នុងក្រុងរាជគ្រឹះនេះឯង ។ ដោយវិបាករបស់កម្មនោះ ក៏ទៅឆេះក្នុងនរកអស់សែននៃឆ្នាំជាច្រើន សេសសល់វិបាករបស់កម្មនោះ ក៏ត្រឡប់មកបានអត្តភាពបែបនេះឯង ។

ព្រះមោគ្គល្លានប្រាប់ព្រះលក្ខណត្ថេរតទៅទៀតថា:

ទី ៩ – ខ្ញុំបានឃើញ សូចិលោមបុរស គឺបុរសមានរោមដូចដែកស្រួច កំពុងអណ្តែតតាមអាកាស, ដែកស្រួចទាំងនោះ ក៏ដោតចូលទៅក្នុងក្បាល ធ្លាយចេញមកតាមមាត់, ដោតចូលទៅក្នុងមាត់ធ្លាយចេញមកតាមទ្រូង, ដោតចូលទៅក្នុងទ្រូង ធ្លាយចេញមកតាមពោះ, ដោតចូលទៅក្នុងពោះ ធ្លាយចេញមកតាមភ្លៅ, ដោតចូលទៅក្នុងភ្លៅ ធ្លាយចេញមកតាមស្មង, ដោតចូលទៅក្នុងស្មង ធ្លាយចេញមកតាមបាតជើង; បុរសនោះក៏ចេះតែស្រែកថ្ងូរ ។

លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់សំដែងប្រាប់បុព្វកម្មរបស់សត្វនោះទៀតថា: ម្នាលភិក្ខុទាំងឡាយសត្វនុ៎ះ កាលពីដើមជាអ្នកបាក់ដោត គឺញុះញង់គេ នៅក្នុងក្រុងរាជគ្រឹះនេះឯង ។ ដោយវិបាករបស់កម្មនោះ ក៏ទៅឆេះក្នុងនរកអស់សែននៃឆ្នាំជាច្រើន, សេសសល់វិបាករបស់កម្មនោះ ក៏មកបានអត្តភាពបែបនេះឯង ។

ព្រះមោគ្គល្លានប្រាប់ព្រះលក្ខណត្ថេរតទៅទៀតថា:

ទី ១០ – ខ្ញុំបានឃើញ កុម្ភណ្ឌបុរស គឺ បុរសមានអណ្ឌៈប៉ុនក្អម កំពុងអណ្តែតតាមអាកាស, កាលបុរសនោះដើរទៅ លុះតែលើកអណ្ឌៈដាក់លើកលើទើបដើរទៅបាន, កាលអង្គុយក៏អង្គុយសង្កត់លើអណ្ឌៈនោះឯង, ត្មាត ក្អែក អាក ដេញតាមឆាប, ចោមចោះចឹក, គេចជញ្ជូនបុរសនោះ ៗ ក៏ចេះតែស្រែកថ្ងូរ ៗ

លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់សំដែងប្រាប់បុព្វកម្មរបស់សត្វនោះទៀតថា: ម្នាលភិក្ខុទាំងឡាយ, សត្វនុះ កាលពីដើមជាអ្នកកាន់អំពើវៀចក្នុងស្រុក, ជាអ្នកវិនិច្ឆ័យក្តីដោយទុច្ចរិត នៅក្នុងភពត្រៃនេះឯង ៗ ដោយវិបាករបស់កម្មនោះក៏ធ្លាក់ក្នុងនរក អស់សែនឆ្នាំជាច្រើន, សេសសល់វិបាកនៃកម្មនោះ ក៏មកបានអត្តភាពបែបនេះឯង ៗ

សាធុ បពិត្រសប្បុរសទាំងឡាយ នេះក៏មកតែពីចិត្តដែលយល់ខុសហើយធ្វើអំពើអាក្រក់ ទើបបានផលជាទុក្ខមានអាការៈផ្សេងៗយ៉ាងនេះ ៗ

កាលបើចិត្តជាធម្មជាតសំខាន់បំផុតដូច្នេះហើយ, សាធុជនដែលមានប្រាថ្នាសេចក្តីសុខសេចក្តីចំរើន, គួរតែរក្សាចិត្តតាមពុទ្ធភាសិតដែលទ្រង់ត្រាស់តឿនរំលឹកថា:

សុទុទ្ទសំ សុនិបុណំ យត្ថកាមនិបាតិនំ
ចិត្តំ រក្ខេថ មេធាវី ចិត្តំ គុត្តំ សុខាវហំ ។

សេចក្តីថា: បុគ្គលជាបណ្ឌិតមានប្រាជ្ញា គួរខំបីបាច់រក្សាចិត្តដែល

ឃើញបានដោយកម្រ, ដែលល្អិតពន់ពេក ដែលលន់ទៅក្នុងអារម្មណ៍ ឯណាៈហើយ មិនងាយនឹងទាញឲ្យងាកចេញមកវិញបាន; ចិត្តដែលអ្នកមានប្រាជ្ញាបានរក្សាហើយ តែងនាំសុខមកឲ្យជាអនេក ។

ឯការរក្សាចិត្តនោះ ក៏គឺ ប្រយ័ត្នចិត្តមិនឲ្យប្រឡាក់ដោយគ្រឿងសៅហ្មង, ឲ្យផូរផង់នៅជាប្រក្រតីនោះឯង ។

ចិត្តនេះ ព្រះមានព្រះភាគទ្រង់សំដែងថា: បភស្សរមិទំ ភិក្ខវេ ចិត្តំ តញ្ច ខោ អាគន្តុកេហិ ឧបក្កិលេសេហិ ឧបក្កិលិដ្ឋំ ។ ម្នាលភិក្ខុទាំងឡាយ ចិត្តនេះជាធម្មជាតស្អាតផូរផង់ ប៉ុន្តែរមែងសៅហ្មងដោយឧបក្កិលេសទាំងឡាយដែលចូលមកថ្មី ។ គួរនាដូចវត្ថុគ្រឿងប្រើប្រាស់ទាំងពួង មានសំពត់ជាដើមដែលនៅថ្មី សុទ្ធតែជារបស់ស្អាតទាំងអស់, ប៉ុន្តែវត្ថុទាំងនោះរមែងសៅហ្មង ដោយគ្រឿងពុំស្អាតទាំងឡាយមានធូលីជាដើម ដែលចូលមកប៉ះពាល់ខាងក្រោយ ។ ឯឧបក្កិលេសនោះសោត ក៏ជាអកុសលជាតដែលកើតមកអំពីចិត្ត ហើយត្រឡប់ប្រទូស្តចិត្តឲ្យសៅហ្មងវិញ ដូចច្រែះដែលកើតអំពីដែក ហើយត្រឡប់ស៊ីដែកឲ្យខូចដូច្នោះឯង ។

ឧបក្កិលេស: គ្រឿងសៅហ្មងចិត្តនោះ ព្រះមានព្រះភាគសំដែងថាមាន ១៦ យ៉ាង គឺ: ១ – អភិជ្ឈាវិសមលោភ: "លោភរំពេចង់បានទ្រព្យគេ", ២ – ទោស: "ប្រទូស្ត", ៣ – កោធ: "ក្រោធ", ៤ – ឧបនាហ: "ចងក្រោធទុក", ៥ – មក្ខ: "លុបគុណគេ",

៦- បលាស "វាយឫកអែបអប", ៧- ឥស្សា "ច្រណែន", ៨- មច្ឆរិយៈ "កំណាញ់", ៩- មាយា "លាក់ពុត", ១០- សាឋេយ្យៈ "អួតអាង", ១១- ថម្ភៈ "រឹងត្អឹង", ១២- សារម្ភៈ "ប្រជែងវាសនា", ១៣- មានៈ "ប្រកាន់ខ្លួន" ១៤ អតិមានៈ "មើលងាយគេ", ១៥- មទៈ "ស្រវឹង", ១៦- បមាទៈ "ធ្វេសប្រហែស" ។ អកុសលធម៌ទាំង ១៦ ប្រការនេះ សូម្បីណាមួយ កាលបើបណ្ដោយឲ្យរុករានចូលមកក្នុងចិត្តហើយ សុទ្ធតែធ្វើចិត្តឲ្យសៅហ្មងពុំថាស្អាតទាំងអស់; ព្រោះហេតុដូច្នោះ បានជាលោកហៅថាឧបក្កិលេស ។ ឧបក្កិលេសនោះ ទោះបីច្រើនដល់ទៅ ១៦ ក៏ពិតហើយ ប៉ុន្តែពុំកើតក្នុងវេលាមួយជាមួយគ្នាទេ រមែងផ្លាស់ប្ដូរគ្នាកើត ។

ម្យ៉ាងទៀត ចិត្តតែមួយទេ តែកាលបើមានកុសលធម៌ណាមួយមកសណ្ឋិតនៅដូចជាម្ចាស់ផ្ទះហើយ, ឧបក្កិលេសដែលជាអកុសលធម៌ ក៏ពុំអាចលុកលុយចូលមកបាន, កាលបើមានអកុសលធម៌ណាមួយចូលមកសណ្ឋិតនៅដូចជាម្ចាស់ផ្ទះហើយ, កុសលធម៌ ក៏រកឱកាសចូលមកពុំបាន ។ ព្រោះហេតុនោះ សាធុជនដែលមានបំណងនឹងធ្វើចិត្តរបស់ខ្លួនឲ្យជ្រះថ្លាប្រាថ្នាសុខ, គួរតែខំញុំាងកុសលធម៌ឲ្យកើតមានឡើងជាប់នៅក្នុងចិត្តជានិច្ចកាល ។

ឯកុសលធម៌នោះ កាលបើលើកយកតែកុសលដែលគួរឲ្យកើតបានក្នុងចិត្តខានពុំបាន, ហើយមានឧបការៈច្រើនផងមកសំដែង, ក៏គឺសតិសម្បជញ្ញៈ ព្រោះលោកសសើរថា៖ ធម៌ពីរប្រការគឺសតិនឹងសម្បជញ្ញៈ

ជាធម៌មានឧបការៈច្រើន ។ សតិគឺសេចក្ដីរលឹក, សម្បជញ្ញៈគឺសេចក្ដីដឹងខ្លួន; គុណធម៌ទាំងពីរនេះប្រព្រឹត្តទៅកនឹកិច្ចជាមួយគ្នា ផ្សេងតែអាការៈ គឺសតិជាក្អាក់ផារខាងការនឹកឃើញកងវេលាដែលធ្វើហើយ, និយាយហើយ, គិតហើយ, សូម្បីកន្លងទៅយូរហើយ ក៏នឹកឃើញបាន; សម្បជញ្ញៈ ជាក្អាក់ផារខាងការដឹងខ្លួនកងវេលាដែលកំពុងធ្វើ, កំពុងនិយាយ, កំពុងគិត ។ ឯចិត្តបើឥតសម្បជញ្ញៈគ្រប់គ្រងហើយ តែងស្ទុះបម្រះនមៀលទៅរកវិសកាគារម្មណ៍ផ្សេង ៗ តាមតែប្រទះ, ស្រេចតែនឹងប្រាថ្នាមិនរើសថាដូចម្ដេចគួរ ពុំគួរឡើយ ។

ចំណែកចិត្តដែលមានសតិសម្បជញ្ញៈគ្រប់គ្រង រមែងរេះរើសរកតែចំណែកដែលល្អ ៗ ។ ធម្មតារថទឹមសេះដែលគ្មានសារថីបរ, សេះតែងនាំបោលទៅតាមទំនើងចិត្តរបស់វា រមែងស្ទុះទៅផ្ដេសផ្ដាស, ដល់នេះ ដល់នោះវៀងទៅតាមផ្លូវ ធ្វើឲ្យកើតសេចក្ដីអន្តរាយតាមតែប៉ះដល់ទង្គិចអ្វីក៏ដោយ ពុំបានស្រួលឡើយ ។

ចំណែករថដែលមានទាយសារថីអ្នកឈ្លាសវៃនៅគ្រប់គ្រងរក្សា រមែងលឿនទៅត្រង់តាមរបៀបនៃមាគ៌ា, ពុំធ្វើឲ្យកើតសេចក្ដីអន្តរាយដល់នរណា ឬអ្វីមួយឡើយ, ញុំាងប្រយោជន៍នៃការប្រើរថឲ្យសម្រេចដោយល្អ សេចក្ដីនេះមានឧបមាយ៉ាងណាមិញ, ឯការប្រព្រឹត្តទៅរបស់មនុស្សក៏យ៉ាងនោះដែរ, គឺបុគ្គលអ្នកមិនមានសតិសម្បជញ្ញៈ រមែងមានកាយវាចា ប្រព្រឹត្តខុស ៗ ក្អាត់ ៗ ធ្វើឲ្យកើតសេចក្ដីអន្តរាយដល់ខ្លួននឹងអ្នកដទៃ ។ ចំណែកបុគ្គលអ្នកមានសតិសម្បជញ្ញៈ រមែងមានកាយ, វាចា

ប្រព្រឹត្តទៅត្រង់តាមផ្លូវ ដែលល្អ ៗ ជាហេតុឲ្យបានសេចក្ដីសុខដល់ខ្លួន និងអ្នកដទៃ ។ ហេតុនេះសប្បុរសទាំងឡាយគួរឲ្យមានសតិសម្បជញ្ញៈ តាំងនៅក្នុងគ្រប់ៗកាល ។

ធម្មទេសនាដែលសំដែងមកក្នុងវេលានេះ សន្មត់ថាចប់ដោយសង្ខេបតាមកាលវេលា ។

ធម្មទេសនានុភាវេន សុខិតា ហោន្តុ បាណិនោ
ទ្វីសុ អត្ថេសុ តិដ្ឋន្តុ សហ សព្វេហិ ញាតិភិ ។

ដោយអានុភាព នៃធម្មទេសនានេះ សូមឲ្យសត្វនិករទាំងឡាយ បានប្រកបដោយសេចក្ដីសុខ ហើយស្ថិតនៅក្នុងប្រយោជន៍ទាំងពីរ គឺ ប្រយោជន៍ក្នុងលោកនេះ និងលោកខាងមុខ ព្រមទាំងញាតិទាំងឡាយ គ្រប់គ្នា ។

## មានទ្រព្យរាប់ថាប្រសើរ

៧– អ្នកមានទ្រព្យកាលពីក្រ គេមិនគោរពបូជា ក៏ត្រឡប់គោរពបូជា, គេមិនសេពគប់ ក៏ត្រឡប់សេពគប់, គេមិនថ្វាយបង្គំ ក៏ត្រឡប់ថ្វាយបង្គំ នេះជាអានុភាពនៃទ្រព្យសម្បត្តិ ។

ការងារទាំងអស់ ដែលលុះដល់ក្ដីសម្រេចទៅបាន មកពីទ្រព្យសម្បត្តិ ព្រោះហេតុនោះទ្រព្យសម្បត្តិជាផ្លូវនាំឲ្យធ្វើអ្វីសម្រេចបានទាំងអស់ ។

— បញ្ចតន្ត្រៈ —

# បញ្ញាសជាតក

## ភាគទី ៤

បណ្ឌិតមហា ឈឹម-ស៊ុម សាស្ត្រាចារ្យ

នៅសាលាបាលីជាន់ខ្ពស់ បានឲ្យប្រែហើយពិនិត្យផ្ទៀងផ្ទាត់ដោយខ្លួនឯង

កាលដែលនៅជាភេទបព្វជិតពី ព.ស. ២៤៨៦, គ.ស. ១៩៤៣

(តមក)

---

## សុទស្សនមហារាជជាតក(១) ទី ១៩

លោកអាចារ្យ ឈឹម-ស៊ុម ប្រែពីបាលី

---

អតីតេ ពារាណសីនគរេ ឯកោ សេដ្ឋី បដិវសតិ ។

*ក្នុងកាលដ៏កន្លងរំលងទៅហើយ មានសេដ្ឋីម្នាក់ នៅនគរពារាណសី ។ គ្រានោះព្រះពោធិសត្វ បានអន្ទោលមកចាប់កំណើត កើតក្នុងត្រកូលគហបតីសេដ្ឋីនោះ ។ កាលដែលព្រះពុទ្ធកស្សប ទ្រង់គង់ធរមាយុទៅឡើយ, មានព្រះថេរៈមួយព្រះអង្គចង់ធ្វើវិវេកនៅក្នុងព្រៃ ដើម្បីឲ្យកើតសេចក្ដីស្ងប់ស្ងាត់; ដួនជាព្រះពោធិសត្វ ចូលទៅក្នុងព្រៃ រំពៃមើលនាយមើលអាយ ក៏ស្រាប់តែប្រទះឃើញព្រះថេរៈនោះ មានឥន្ទ្រិយស្រគត់ស្រគំសមជាអ្នកប្រព្រឹត្តធម៌, ពោធិសត្វមានសេចក្ដីត្រេកអរក៏ចរចូលសំដៅទៅក្រាបថ្វាយបង្គំ អង្គុយនៅទីសមគួរហើយសួរព្រះថេរៈថា លោកម្ចាស់គង់នៅទីនេះឬ? ព្រះថេរៈឆ្លើយថា ចំរើនពរ ៗ*

---

១ ជាតកនេះ តែងតាមទំនង មហាសុទស្សនសូត្រ ក្នុងគម្ពីរទីឃនិកាយមហាវគ្គ និងចក្កវត្តិសូត្រ ក្នុងគម្ពីរទីឃនិកាយ បាដិកវគ្គ ដោយអន្លើ ៗ ។

ពោធិសត្វគិតថា ''កាលនេះ ជាកាលគួរនឹងធ្វើបុណ្យ'' ហើយក៏បោះបង់ការងាររបស់ខ្លួន បែរទៅធ្វើបណ្ណសាលា ធ្វើទីចង្ក្រម ជីកអណ្តូង រាយដីខ្សាច់ជុំវិញ បូជាដោយវត្ថុទាំងឡាយ មានទានធូបគ្រឿងក្រអូប កម្រងផ្កាជាដើម ហើយវេរនូវវិហារទាន មានទាំងគ្រឿងបរិក្ខារសព្វគ្រប់ប្រការរួចស្រេច ទើបថ្វាយបង្គំលាព្រះថេរៈចូលទៅស្រុកវិញ ។ ចាប់ដើមអំពីថ្ងៃនោះមក ពោធិសត្វនោះ តែងផ្គត់ផ្គង់ទំនុកបំរុងព្រះថេរៈ ប្រគេនត្រៃចីវរ ប្រគេនបង្ហាន់បិណ្ឌបាត ប្រគេនបង្អែមគ្រប់មុខ ប្រគេនទំនាប់ព្រះបាទ ឈើច្រត់ ពាងទឹក គោម ចង្កៀង គ្រែតាំង គ្រឿងកម្រាល ទឹកបញ្ចគោរសទាំង ៥ ប្រការ ។ ព្រះថេរៈកាលធ្វើអនុមោទនា បានសំដែងធម៌ទេសនាថា

អន្នទោ ពលទោ ហោតិ វត្ថទោ ហោតិ វណ្ណទោ
យានទោ សុខទោ ហោតិ ទីបទោ ហោតិ ចក្ខុទោ[១] ។

បុគ្គលអ្នកឲ្យនូវបិណ្ឌបាតបច្ច័យ មានបាយជាដើម ឈ្មោះថាឲ្យកម្លាំង, បុគ្គលអ្នកឲ្យនូវគ្រឿងសំលៀកបំពាក់ មានសំពត់ជាដើម ឈ្មោះថាឲ្យពណ៌សម្បុរ, បុគ្គលអ្នកឲ្យនូវយានជំនិះ ឈ្មោះថាឲ្យសេចក្តីសុខ, បុគ្គលអ្នកឲ្យប្រទីបជ្វាលា ឈ្មោះថាឲ្យភ្នែក ។

ពោធិសត្វនោះប្រគេនគ្រឿងបរិក្ខារសព្វគ្រប់ប្រការ ហើយដាំគុម្ពបន្លាជារបងព័ទ្ធពីក្រៅ, ខាងក្នុងរបងនោះ ដាំដើមត្នោត មានរបៀប

១ គាថានេះ ស្រង់មកពីគម្ពីរសំយុត្តនិកាយ សគាថវគ្គ ។

ជាដូរវៀនកាយ ជាទីរហោស្ថានក្សេមក្សាន្តសប្បាយ សមជាទីលំនៅនៃបព្វជិតអ្នកស្វែងរកវិវេក ៗ ពោធិសត្វ និមន្តព្រះថេរៈឲ្យគង់ចាំវស្សានៅក្នុងទីនោះ, ដល់ថ្ងៃចាតុទ្ទសីនិងថ្ងៃបណ្ណរសី ក៏តែងនៅរក្សាឧបោសថក្នុងទីនោះដោយខ្លួនឯងផង ៗ ដល់វេលាចេញវស្សា ពោធិសត្វនិមន្តព្រះថេរៈឲ្យភោជន៍ ឲ្យព្រះថេរៈគង់លើបញ្ញាសនៈ, បានស្តាប់ធម៌កថារបស់ព្រះថេរៈហើយ ប្រគេនចង្ហាន់បិណ្ឌបាតនឹងសំពត់មួយគូទៀត ៗ ពោធិសត្វនោះទំនុកបំរុងព្រះថេរៈ នឹងធ្វើបុណ្យមានសភាពដូច្នេះអស់កាលមួយជីវិត, លុះអស់ជន្មាយុច្យុតិអំពីអត្តភាពនោះទៅ បានទៅកើតក្នុងទេវលោក សោយសម្បត្តិក្នុងស្ថានសួគ៌ ប្រកបដោយអាយុទិព្វ យសទិព្វ សុខទិព្វ សម្ផស្សទិព្វ ឧឡារសទិព្វ គោជនទិព្វ តូរ្យតន្ត្រីប្រកបដោយអង្គ ៥ ប្រការក៏ជាទិព្វ ទ្រព្យក៏ជាទិព្វ បរិវារក៏ជាទិព្វសព្វប្រការ, ទ្រង់កំសាន្តនៅក្នុងទេវលោកនោះ អស់កាលជាយូរអង្វែង; កាលព្រះអង្គអស់ព្រះទិព្វជន្មាយុ ច្យុតអំពីទេវលោកនោះមក ទ្រង់បានមកសម្ភពចាប់កំណើតកើតក្នុងកុសាវតីមហានគរ ជាបរមក្សត្រដ៏បវរ ទ្រង់ព្រះនាមព្រះបាទសុទស្សនៈ បានឡើងឋានន្តរៈជាសម្តេចព្រះបរមចក្រពត្រាធិរាជ ប្រកបព្រមដោយកែវ ៧ ប្រការ គឺចក្ករតន៍ ហត្ថីរតន៍ អស្សរតន៍ ឥត្ថីរតន៍ មណីរតន៍ គហបតិរតន៍ បរិនាយករតន៍ ៗ ចក្ករតន៍ មកអំពីសមុទ្រ, ហត្ថីរតន៍ មកអំពីត្រកូលឆទ្ទន្ត, អស្សរតន៍ មកអំពីត្រកូលសេះពលាហកៈ, ឥត្ថីរតន៍ មកអំពីឧត្តរកុរុទ្វីប, មណីរតន៍

មកអំពីភ្នំវេបុល្លបព៌ត, គហបតីរតន៍ កើតក្នុងកុសាវតីមហានគរ, បរិនាយករតន៍ មកអំពីជម្ពូទ្វីប ។

មានពាក្យបុច្ឆាទោទដណ្ដឹងសួរថា សម្បត្តិនេះ កើតឡើងដោយផលអ្វី? វិសជ្ជនាថា កើតឡើងដោយផលនៃកុសលកម្ម ។ មិនត្រឹមតែរតន៍ ៧ ប្រការប៉ុណ្ណោះឡើយ, មានសម្បត្តិឯទៀត ៗ កើតឡើងជាច្រើន គឺឃ្លាំង ៨ ម៉ឺន ៤ ពាន់ កើតឡើងដោយផលនៃបណ្ណសាលាតូចមួយ ។ មានកែវមណីជោតិ ៨ ម៉ឺន ៤ ពាន់ កើតឡើងដោយផលនៃប្រទីបមួយ ។ មានព្រះរាជបុត្រ ៨ ម៉ឺន ៤ ពាន់ កើតឡើងដោយផលនៃឈើច្រត់មួយ, ព្រះរាជបុត្រមួយព្រះអង្គ ៗ សុទ្ធតែជាវីរបុរស អាចញាំញីនូវសេនានៃស្តេចដទៃបាន មានជ័យជំនះឈ្នះក្រៀបក្នុងមណ្ឌលសកលជម្ពូទ្វីប ។ មានដំរី ៨ ម៉ឺន ៤ ពាន់ កើតឡើងដោយផលនៃត្រៃមួយ ។ មានសេះ ៨ ម៉ឺន ៤ ពាន់ កើតឡើងដោយផលនៃជើងកាំងមួយ ។ មានរាជរថ ៨ ម៉ឺន ៤ ពាន់ កើតឡើងដោយផលនៃទ្រនាប់ព្រះបាទ ១ សម្រាប់ ។ មានកែវ ៧ ប្រការ ៨ ម៉ឺន ៤ ពាន់ កើតឡើងដោយផលនៃកម្រាលមួយ ។ មានឃ្លាំងសំពត់ ៨ ម៉ឺន ៤ ពាន់ កើតឡើងដោយផលនៃត្រៃចីវរ, សំពត់ទាំងនោះមានសាច់ល្អ ៗ គឺជាសំពត់កោសេយ្យពស្ត្រ កប្បាសិកពស្ត្រ និងសំពត់ទិលកម្ពល រត្តកម្ពល ដែលកើតឡើងក្នុងមណ្ឌលកុសាវតីមហានគរ ។ មានកំណាប់ ៨ ម៉ឺន ៤ ពាន់កន្ទួង កើតឡើងដោយផលនៃពានទឹកធំមួយ ។ មានជង្រុកស្រូវ ៨ ម៉ឺន ៤ ពាន់ កើតឡើងដោយផលនៃចង្ហាន់បិណ្ឌបាត ។ មានបញ្ចគោរសជាតិផ្អែម ៨ ម៉ឺន ៤ ពាន់

កើតឡើងដោយផលនៃបញ្ចគោរស ។ មានស្រះ ៨ ម៉ឺន ៤ ពាន់ ពេញ ដោយកែវ ៧ ប្រការ កើតឡើងដោយផលនៃអណ្តូងទឹកមួយ ។ មាន ឧទ្យានព្រមទាំងស្រះបោក្ខរណី ៨ ម៉ឺន ៤ ពាន់ កើតឡើងដោយផលនៃ ឧទ្យាន ។ មានទិព្វភោជនប្រកបដោយឧជារស ៨ ម៉ឺន ៤ ពាន់ កើត ឡើងដោយផលនៃបង្ហាន់ ។ មានកំពែង ៧ ជាន់ កើតឡើងដោយផល នៃការដាំបន្ទាបងទាំងក្រៅ កំពែង ១ ជាន់សុទ្ធសឹងមាស, កំពែង ១ ជាន់ សុទ្ធសឹងប្រាក់, កំពែង ១ ជាន់សុទ្ធសឹងទង់ដែង, កំពែង ១ ជាន់សុទ្ធ សឹងកែវប្រពាឡ, កំពែង ១ ជាន់សុទ្ធសឹងកែវមណី, កំពែង ១ ជាន់ សុទ្ធសឹងកែវទទឹម កំពែង ១ ជាន់សុទ្ធសឹងកែវ ៧ ប្រការ, ។ មាន កំពែងដើមត្នោត ៧ ជាន់ កើតឡើងដោយផលនៃការដាំដើមត្នោត, កំពែងដើមត្នោត ១ ជាន់ សុទ្ធសឹងមាស, ដើមត្នោតមួយជាន់សុទ្ធសឹង ប្រាក់, ដើមត្នោត ១ ជាន់សុទ្ធសឹងទង់ដែង, ដើមត្នោត ១ ជាន់សុទ្ធសឹង កែវទទឹម, ដើមត្នោត ១ ជាន់ សុទ្ធសឹងកែវប្រពាឡ, ដើមត្នោត ១ ជាន់សុទ្ធសឹងកែវផលិក ដើមត្នោត ១ ជាន់ សុទ្ធសឹងកែវ ៧ ប្រការ; ត្នោតទាំងនោះ មានស្លឹក ១ ធាងជាមាស, ស្លឹក ១ ធាងជាប្រាក់ ស្លឹក ១ ធាងជាទង់ដែង, ស្លឹក ១ ធាងជាកែវប្រពាឡ, ស្លឹក ១ ធាងជាកែវ មណី, ស្លឹក ១ ធាងជាកែវទទឹម, ស្លឹក ១ ធាងជាកែវ ៧ ប្រការ; គង ត្នោត ១ ដើមៗ មានផ្លែ ៧ ធ្លាយ, ផ្លែ ១ ធ្លាយជាមាស, ផ្លែ ១ ធ្លាយ ជាប្រាក់, ផ្លែ ១ ធ្លាយជាទង់ដែង, ផ្លែ ១ ធ្លាយជាកែវប្រពាឡ, ផ្លែ ១ ធ្លាយជាកែវផលិក, ផ្លែ ១ ធ្លាយជាកែវទទឹម, ផ្លែ ១ ធ្លាយជាកែវ

៧ ប្រការ ។ ស្លឹកត្នោតនឹងផ្លែត្នោតទាំងអស់នោះសឹងជុំរុងរឿងក្លី ផ្លេករន្ទោលព្រាលផ្លោ, កាលបើត្រូវខ្យល់បក់មកត្រសៀក ៗ រំភើយ ៗ កំពុស្សូរល្ហែងល្ហើយ ស័ព្ទសាន់នរទំ ដូចគេប្រគំបញ្ចង្គតូរ្យតន្ត្រី ពួកមនុស្សម្នាមហាជនទាំងប្រុសទាំងស្រី ទាំងរាស្ត្រទាំងនាម៉ឺនសព្វមុខមន្ត្រី បានសេចក្តីសុខក្សេមក្សាន្ត ឥតមានសេចក្តីទុក្ខរំខានព្រួយភ័យភិត គិតតែស៊ីផឹកលេងសប្បាយពល់ខែពល់ឆ្នាំ ខ្លះរាំខ្លះច្រៀង ខ្លះទះដៃបន្ទរ ខ្លះមានចិត្តរីករាយសប្បាយត្រេកអរ កៀកកកាន់ដៃគ្នាដើរជាពួក ៗ ។ ក្រុងកុសាវតីមហានគរ ឮតែសូរទ្រហឹងខ្ទរខ្ទរ ស្ទើរតែនឹងបែកទ្រុឌស្រុតផែនប្រថពី ដោយសន្ធឹកដំរី សន្ធឹកសេះ សន្ធឹករទេះ នឹងសូរគង សូរគាំង សូរស្គរ ។ ក្រុងកុសាវតីមហានគរជាឧត្តមរាជធានីជាទីមាំទាំស្តុកស្តម្ភ បរិបូណ៌ដោយរតន៍ ៧ ប្រការ ព្រះរាជាមហាសុទស្សនៈ ទ្រង់គង់សោយរាជសម្បត្តិនៅនានគរនោះ ទ្រង់មានមហិទ្ធិរិទ្ធិក្រៀវក្រា បរិបូណ៌ដោយឃ្លាំងមាសឃ្លាំងប្រាក់ ឃ្លាំងរបស់ច្រើនប្រការ ពប្ចូធខ្ញៀវខ្ញារដោយពួកចម្រៀង ពួករបាំពួកតូរ្យតន្ត្រី ប្រគំថ្វាយសព្វទិវារាត្រី ឥតលោះថ្ងៃមួយឡើយ ។ តេន វុត្តំ ព្រោះហេតុនោះបានជាព្រះដ៏មានព្រះភាគទ្រង់ត្រាស់សំដែងថា បុរសស្ត្រីឯណា បានឲ្យបាយក្តី ទឹកក្តី សំពត់ក្តី យានជំនិះក្តី ផ្កាកម្រងក្តី គ្រឿងលាបក្តី ទីដេកក្តី ទីសំណាក់អាស្រ័យក្តី ប្រទីបផ្កាលាក្តី, បុរសស្ត្រីនោះរមែងបានទទួលសម្បត្តិមានសភាពដូច្នេះក្នុងលោកនេះ ។

បុច្ឆាសួរថា ព្រះបាទមហាសុទស្សនៈនោះ មានព្រះជន្មប៉ុន្មានឆ្នាំ?

វិសជ្ជនាថា ព្រះអង្គជារាជកុមារ ក្រសាលល្បែងកីឡាអស់ ៨ ម៉ឺន ៤ ពាន់ឆ្នាំ, បានសោយសម្បត្តិជាស្តេចឧបរាជ ៨ ម៉ឺន ៤ ពាន់ឆ្នាំ បានសោយរាជ្យជាចក្រពត្រាធិរាជ ៨ ម៉ឺន ៤ ពាន់ឆ្នាំ, ទ្រង់ប្រព្រឹត្តព្រហ្មចរិយធម៌ ៨ ម៉ឺន ៤ ពាន់ឆ្នាំ រួមទាំង ៤ កាល ត្រូវជា ៣ សែន ៣ ម៉ឺន ៦ ពាន់ឆ្នាំ ។ ព្រះជន្មាយុប៉ុន្មានប៉ុណ្ណោះ មិនមែនព្រះវររាជមាតាបិតាទ្រង់ព្រះរាជទានមកឡើយ គឺជាផលនៃបណ្ណសាលាមួយ នាំព្រះជន្មាយុនេះមកថ្វាយព្រះអង្គ ។ តេនាហ កគក់ ព្រោះហេតុនោះបានជាអង្គសម្តេចព្រះកគវន្តាចារ្យ ទ្រង់ត្រាស់ព្រះពុទ្ធដីកាថា

សទ្ធាបុព្វង្គមំ ទានំ អប្បំ កិញ្ចិ បិយេ កតំ
បសន្នា តីសុ កាលេសុ លភតិ តិវិធំ សុខំ
សុខមានុស្សយំ ទេតិ សគ្គេសុ ច បរមំ សុខំ
តតោ ច និព្វានសុខំ សព្វទានេន លភតិ

ការឲ្យទានមានសទ្ធាជាប្រធាន, ទានវត្ថុសូម្បីបន្តិចបន្តួច ដែលបុគ្គលឲ្យចំពោះបដិគ្គាហកជាទីស្រឡាញ់ ហើយបុគ្គលនោះមានសេចក្តីជ្រះថ្លាក្នុងកាលទាំង ៣ គង់តែងបាននូវសេចក្តីសុខទាំង ៣ ប្រការ គឺ សេចក្តីសុខក្នុងមនុស្សលោក និងសេចក្តីសុខក្នុងឋានសួគ៌ទេវលោកនិងសេចក្តីសុខក្នុងព្រះនិព្វាន; សេចក្តីសុខទាំងនេះ បុគ្គលតែងបានដោយការឲ្យទានគ្រប់ជំពូក ។

ព្រះពោធិសត្វធ្វើនូវការកុសលគ្រប់ជំពូក ដរាបដល់ទីបំផុតព្រះ

ផន្ទាយុ ទ្រង់ច្យុតអំពីអត្តភាពនោះ ទ្រង់បានទៅចាប់បដិសន្ធិកំណើត កើតក្នុងពិមានមាស ឰដ៏ពិភពតាវតឹង្សទេវលោកសួគ៌នាយ មានពពួកស្រីទេពអប្សរទាំងឡាយ ចោមរោមគាល់បំរើជាច្រើនសព្វកាលវេលា ។ ចំណែកខាងពួកមហាជន អ្នកខេត្តទាំងអស់គ្នាបានធ្វើការកុសលគ្រប់ប្រការ ដល់ទីបំផុតអាយុ ក៏បានទៅកើតក្នុងទេវលោកដែរ ។ តេនាហ ភគវា ព្រោះហេតុនោះបានជាអង្គសម្តេចព្រះភគវន្តាចារ្យទ្រង់ត្រាស់ព្រះធម៌ទេសនាថា

សាធវោ សុខកាមា យេ បដ្ឋិត្វា សគ្គមោក្ខមគ្គំ
ទានំ ទត្វា សាមគ្គិយា បុតា គច្ឆន្តិ តេ សគ្គតិ

ម្នាលសប្បុរសអ្នកចង់បាននូវសេចក្តីសុខទាំងឡាយ, ជនទាំងឡាយឯណា ប្រាថ្នានូវផ្លូវនៃឋានសួគ៌និងព្រះនិព្វាន បានឲ្យទានដោយសាមគ្គី ជនទាំងឡាយនោះ លុះច្យុតអំពីលោកនេះរមែងដល់នូវឋានសួគ៌និងព្រះនិព្វានដោយពិត ។

ចប់ សុខស្សូនះមហាភិជាតក ទី ១៩

# ផ្នែកអក្សរសាស្ត្រ

## សង្គ្រាមកាំបាំង

យុនបណ្ណានុរ័ក្ស ប៊ូ-ប៊ូ រៀបរៀង

---

ការច្បាំងគ្នាដណ្ដើមយកជ័យជំនះ ហៅថា សង្គ្រាមៗ នេះមាន ២ ប្រភេទ គឺ សង្គ្រាមដែលអ្នកផងទាំងពួងមើលឃើញច្បាស់នឹងភ្នែក ដូចយ៉ាងប្រទេសមួយលើករេហ៍ពលសកលយោធាជាកងទ័ព មាន គ្រឿងសស្ត្រាវុធយុទ្ធភ័ណ្ឌសព្វគ្រប់ ទៅច្បាំងដណ្ដើមយកជ័យជំនះក្នុង ប្រទេសដទៃ ហៅថា សង្គ្រាមមិនកំបាំង (អប្បដិច្ឆន្នសង្គាមោ); សង្គ្រាមមួយប្រភេទទៀត ដែលឥតជនណាម្នាក់មើលឃើញច្បាស់នឹង ភ្នែកខ្លួនសោះ ទាំងចិត្តគំនិតរបស់អ្នកនោះសោតទៀត ក៏សំគាល់ថាខ្លួន បានសុខសាន្តត្រាណណាស់ កើតមកជាតិនេះមានភ័ព្វព័សនាល្អ មិន ដែលទៅចូលច្បាំងក្នុងសមរភូមិម្ដងទេ ប៉ុន្តែ គំនិតរបស់អ្នកនេះបែរជាខុស ផ្ទុយគ្នាស្រឡះទៅវិញ ព្រោះថាតាមការណ៍ពិត ខ្លួនអ្នកមិនដែលឃើញ សង្គ្រាមសោះនោះ តែងស្ថិតនៅក្នុងយុទ្ធភូមិជានិច្ច តតាំងច្បាំងនឹងសឹក សត្រូវរាល់វេលា តែភ្នែកអ្នកនោះមិនឃើញ ក៏សំគាល់ថាខ្លួនបានសុខ ណាស់ មិនដែលធ្វើចម្បាំងទេ ។ សង្គ្រាមដែលគ្មានអ្នកណាមើល ឃើញនឹងភ្នែកយ៉ាងនេះ ហៅថា សង្គ្រាមកំបាំង (បដិច្ឆន្នសង្គាមោ) ។

សង្គ្រាមមិនកំបាំង មិនបាច់សរសេរក្នុងទីនេះទេ ព្រោះអស់លោក

ធ្លាប់ប្រាប់ហើយ ។ សូមសរសេរចំពោះតែសង្គ្រាមកំបាំងដូចតទៅនេះ ៖

សង្គ្រាមកំបាំង កើតមានឡើងដំណាលគ្នានឹងកំណើតរបស់មនុស្ស, មានមនុស្សកើតឡើងកាលណា សង្គ្រាមកំបាំងក៏មានកាលនោះដែរ ។ មានមនុស្សនៅក្នុងទឹកដីណា ទោះម្នាក់ឯងក្តី ច្រើននាក់ក្តី សង្គ្រាមកំបាំងក៏មាននៅទឹកដីនោះដែរ ។

ចុះអាងហេតុអ្វី បានជាហ៊ានសរសេរយ៉ាងនេះ?

អាងហេតុថា សង្គ្រាមកំបាំងកើតមាននៅក្នុងខ្លួនមនុស្សគ្រប់រូប ទាំងប្រុសទាំងស្រី មិនមែនកើតមាននៅទីកន្លែងណាមួយដោយឡែក ក្រៅពីរូបមនុស្សទេ ។ ព្រោះហេតុនេះ ត្រូវសន្និដ្ឋានថា រូបមនុស្សម្នាក់ៗ ឈ្មោះថាជាទីយុទ្ធភូមិមួយៗ ។ គ្រប់មនុស្សក្នុងលោកនេះទោះបីប្រុសឬស្រី ក្មេងឬចាស់ សុទ្ធតែតាំងច្បាំងនឹងសឹកសត្រូវ (កិលេស) ក្នុងខ្លួនទាំងអស់គ្នា គ្មានអ្នកណាខានច្បាំងបានឡើយ ហើយច្បាំងជានិច្ចរាល់ថ្ងៃខែឆ្នាំទៀត ច្បាំងតាំងពីកើតមករហូតដល់ស្លាប់ទៅវិញទើបឈប់ ។ សូមប្រាប់រឿងសង្គ្រាមកំបាំងតាមឧទាហរណ៍តទៅនេះ ៖

ទារកកើតមកភ្លាម ស្រែកយំភ្លាម ទារកខ្វះសន្ទប់បាត់មាត់យូរបន្តិចទៅទើបស្រែកយំ ។ ម្តាយឮសូរកូនយំ ក៏បញ្ចុកដោះទៅក្នុងមាត់វា ។ ជញ្ជក់ទឹកដោះលេបចូលទៅក្នុងពោះវាទាល់តែឆ្អែតហើយ វាលែងប៉ៅទៀត ។ អាការដែលទារកស្រែកយំដោយស្រេកឃ្លានយ៉ាងនេះ ឈ្មោះថាមានសឹកសត្រូវ គឺសេចក្តីស្រេកឃ្លានកើតឡើងដល់វា លុះវា

បៅដោះឆ្អែតហើយ ក៏ឈប់យំ ក៏ដេកស្ងៀម នេះឈ្មោះថាការច្បាំងនឹងសេចក្ដីស្រេកឃ្លាន (បិបាសសង្គាមោ) ។

លុះទារកនោះចំរើនវ័យធំឡើង រហូតអាយុ ៦ ឬ ៧ ឆ្នាំ ដឹងក្ដីហើយ ក៏តាំងចាប់ផ្ដើមចូលសាលារៀនសូត្របំណេះវិជ្ជាផ្សេងៗ, លោកអ្នកធ្លាប់រៀនសូត្រពីក្មេងគង់តែនៅចាំមិនភ្លេចថា ក្នុងគ្រាកំពុងរៀននោះតើមានសេចក្ដីទុក្ខលំបាកយ៉ាងណាខ្លះ? នឿយហត់ដូចម្ដេចខ្លះ? ទើសទាក់នឹងរបស់គួរបែបណាខ្លះ? ខ្ញុំមិនបាច់សរសេរក្នុងទីនេះទេ ។ សូមគ្រាន់ថាកុមារ-កុមារី ដែលរៀនសូត្របានដល់ត្រើយនៃវិជ្ជាតាមប្រាថ្នានោះ មិនមែនជាអ្នកធ្វើចម្បាំងតិចតួចទេ ជាអ្នកចូលប្រយុទ្ធយ៉ាងខ្លាំងគ្រប់កាលវេលាលែងតែដេកលក់ គឺប្រយុទ្ធនឹងចិត្តខ្ជិល, ចិត្តចង់ឆ្ងាញ់ពិសា, ចិត្តចង់លេងសើចសប្បាយ ។ល។ ទាល់តែច្បាំងឈ្នះសត្រូវទាំងនេះ ទើបរៀនបានចេះដឹងដូចបំណង នេះឈ្មោះថាធ្វើសង្គ្រាមក្នុងគ្រារៀនសូត្រ (សិក្ខាសង្គាមោ) ។

លុះកុមារ-កុមារី អ្នករៀនសូត្របានចេះដឹងហើយទាំងនោះមានអាយុច្រើនឡើង រាប់ពីត្រឹមអាយុ ១៨ ឆ្នាំ ឡើងទៅ តាមច្បាប់សម្រាប់ស្រុកទេសបញ្ញត្តថាជាមនុស្សគ្រប់ការ ឬពេញការ, បានការ ។ ពួកមនុស្សគ្រប់ការទាំងនេះ បើសម្រេចចិត្តថាឈប់រៀនសូត្រហើយ ក៏នៅស្ងៀមស្ងាត់តែឯកឯងពុំបានដែរ ត្រូវតែរកផ្ទះសម្បែង គឺត្រូវមានប្រពន្ធប្ដី ។ បើបានប្រពន្ធប្ដីហើយ ត្រូវធ្វើការងារផ្សេងៗ តាមសមត្ថភាពរបស់ខ្លួន ដើម្បីនឹងចិញ្ចឹមខ្លួនព្រមទាំងគ្រួសារឲ្យបានសុខ

ស្រួល ។ ឯកិច្ចការគ្រប់ចំពូក ដែលស្វាមីឬភរិយាត្រូវធ្វើនោះ ជាការធ្ងន់ស្រាលក្រខ្វាយយ៉ាងណាខ្លះ? ខ្ញុំមិនបាច់រៀបរាប់ទេ ព្រោះជឿថា លោកអ្នកសុទ្ធតែធ្លាប់បានចូលប្រយុទ្ធផ្ទាល់ខ្លួនក្នុងការនេះរួចមកហើយផង កំពុងតែប្រយុទ្ធសព្វថ្ងៃនេះផង ។ លោកអ្នកដែលតាំងខ្លួនឱ្យកើតជាមនុស្សពេញលក្ខណៈច្បាប់បាន ដូចពាក្យចាស់ហៅថា "មនុស្សមានមុខមាត់ ឬមនុស្សស្តុកស្តម្ភ" នោះ សុទ្ធតែជាអ្នកច្បាំងឈ្នះសឹកសត្រូវគ្រប់ចំពូក មានការក្លួតកុហកបោកប្រាស់គេជាដើម ដែលជាសត្រូវនៅចាំប្រទូសរ៉ាយខ្លួនគ្រប់ខ្យល់ដង្ហើម ។ ការធ្វើចម្បាំងតយុទ្ធនឹងរបរចិញ្ចឹមជីវិតគ្រប់ចំពូកនោះ ជាចម្បាំងយ៉ាងធំសម្បើមអស្ចារ្យណាស់ ជាចម្បាំងដ៏ស្វិតស្វាញលើសសង្គ្រាមកំពុងរៀនសូត្រទៅទៀត មនុស្សគ្រប់រូបមិនមែនបេះតែច្បាំងឈ្នះគ្រប់គ្នាទេ ។ ប្រសិនបើច្បាំងឈ្នះទាំងអស់គ្នានោះ ប្រហែលជាក្នុងប្រទេសមួយៗ គ្មានចោរលួចទេ គ្មានមនុស្សត្រូវទោសជាប់គុកទេ ។ ពួកចោរទាំងនោះឈ្មោះថាជាអ្នកច្បាំងចាញ់សឹកសត្រូវ (ទុច្ចរិត) ក្នុងខ្លួន នេះឈ្មោះថាធ្វើសង្គ្រាមក្នុងរបរចិញ្ចឹមជីវិត (អាជីវសង្គ្រាមោ) ។

មនុស្សគ្រប់រូប មិនរើសថាអ្នកមាន ឬអ្នកទាល់ក្រ អ្នកមានបណ្ដាស័ក្តិ ឬឥតបណ្ដាសក្តិឡើយ តែកើតមកជាមនុស្សហើយ តែងមានជម្ងឺឈឺចាប់ដូចគ្នា ប្លែកតែច្រើនតិចធ្ងន់ស្រាល នឹងមើលសះជា ឬមិនសះជាប៉ុណ្ណោះ ដែលថាឥតអ្នកណាឈឺសោះនោះ មិនធ្លាប់មានទេក្នុងលោកសព្វថ្ងៃនេះ ។ ជម្ងឺឈឺចាប់នេះជាសឹកសត្រូវមួយប្រភេទ មាន

ឫទ្ធានុភាពដ៏ខ្លាំងក្លាបំផុត មានរេហ៍ពលក៏ច្រើនណាស់ ទាល់តែគ្រូពេទ្យយ៉ាងស្ទាត់ជំនាញការឈ្មោះមិនអស់ ចំណាំមុខមិនបាន កងពលទាំងនោះ សុទ្ធតែជាអ្នកខ្លាំងពូកែមានថ្វីដៃយ៉ាងឆើត បេះកលយុទ្ធជ្រាលជ្រៅ គ្រូពេទ្យបេះដឹងស្មើៗ ដេញកេតុតក៏មិនទាន់ទេ ។ ជម្ងឺឈឺចាប់នេះក៏តែងលើកកងទ័ពរុករានទន្ទ្រានលុកលុយក្នុងនគរកាយ នៃបណ្ដាជនប្រុសស្រីក្មេងចាស់ទាំងអស់ឥតរើសមុខ គ្មានអ្នកណាម្នាក់អាចគេចវេះឲ្យផុតពីមុខទ័ពវាទេ វានៅស្ទាក់គ្រប់ផ្លូវច្រកល្ហក គ្រប់ពេលវេលា ។ បើអ្នកណាមានមាសប្រាក់ច្រើន ឬមានចំណេះវិជ្ជាច្រើន អ្នកនោះអាចទប់ទល់នឹងវាបានខ្លះដែរ ឆាប់ដឹងឈ្នះចាញ់ភ្លាមៗ ។ បើអ្នកទាល់ក្រ ឬល្ងង់ខ្លៅវិញ ច្បាំងមិនសូវឈ្នះវាទេ ច្រើនតែចាញ់ថ្វីដៃវា បើមិនឆាប់ក៏យូរដែរ ។ លោកអ្នកទាំងពួងដែលរស់នៅតាំងពីក្មេងរហូតដល់ចាស់នោះ ធ្លាប់ឈឺចាប់ផ្ទាល់ខ្លួនស្រាប់មកហើយ បើមិនធ្ងន់ក៏ស្រាលៗដែរ គង់ប្រាបឥទ្ធិពលរបស់ជម្ងឺនោះថាមានទំហំប៉ុណ្ណា ? លោកអ្នកចំណាយធនធានបាត់ការតតាំងច្បាំងនឹងជម្ងឺនោះអស់ប៉ុន្មានៗ សូមប្រាប់តាមធ្លាប់ចូលប្រយុទ្ធក្នុងសមរភូមិនោះចុះ នេះឈ្មោះថាធ្វើសង្គ្រាមនឹងជម្ងឺឈឺចាប់ (រោគសង្គាមោ) ។

នៅមានសង្គ្រាមមួយប្រភេទទៀត ដែលមានតេជានុភាពយ៉ាងពន្លឹក គួរឲ្យស្ញប់ស្ញែងជាទីបំផុតមានឫទ្ធិអំណាចខ្លាំងពូកែលើសសង្គ្រាមទាំងអស់ដែលបានរៀបរាប់ខាងដើមនោះ ឈ្មោះថាមរណសង្គ្រាមជាសង្គ្រាមគ្រាទីបំផុតក្នុងជីវិតរបស់មនុស្សគ្រប់រូប ។

សេចក្ដីស្លាប់ចាត់ជាមរណសង្គ្រាម ។ នេះពួកមនុស្សបុថុជ្ជនដូចគ្នា គ្មានអ្នកណាម្នាក់ច្បាំងឈ្នះទេ ទឹងបាច់និយាយថ្វីដល់មនុស្សសាមញ្ញ សូម្បីព្រះបាទសម្ដេចព្រះបរមចក្រពត្រាធិរាជ ដែលព្រះអង្គមានឫទ្ធានុភាពគ្របទៅលើសកលលោក មានសេនាយោធាពលមិនអស់មើលក៏នៅតែព្រះអង្គចាញ់ថ្វីដៃមរណសង្គ្រាមដែរ គឺព្រះអង្គទ្រង់ទិវង្គតអស់ព្រះជន្ម ដូចជាមនុស្សសាមញ្ញ ។ រឿងស្លាប់នេះ ខ្ញុំមិនបាច់សរសេរឲ្យវែងឆ្ងាយទេ ព្រោះអស់លោកអ្នកធ្លាប់ជ្រាបស្រាប់ហើយថា គ្មានមនុស្សណាចាស់សកឡើយ សុទ្ធតែស្លាប់ទាំងអស់គ្នា ប្លែកតែមុនក្រោយ យូរឆាប់ប៉ុណ្ណោះ ។

ពួកមនុស្សបុថុជ្ជនគ្រប់រូប ទោះបីលោកអ្នកមានឫទ្ធានុភាពច្រើនយ៉ាងណាក្ដី មានរេហ៍ពលច្រើនរាប់មិនអស់ក្ដី មានគ្រឿងយុទ្ធោបករណ៍សព្វគ្រប់ឥតខ្វះក្ដី មានចំណេះចេះមន្តវិជ្ជាការខុមអាមអាគមយន្តគាថាកាប់មិនមុតដុតមិនឆេះ ឬក៏ចេះមន្តប្រស់មនុស្សស្លាប់ហើយឲ្យរស់ឡើងវិញក្ដី ទឹងចេះក្បួនពេទ្យល្អិតល្អន់ស្ទាត់ជំនាញយ៉ាងណាក្ដី ក៏នៅតែច្បាំងចាញ់ស្ដេចមច្ចុរាជគឺសេចក្ដីស្លាប់នេះដែរ មិនដែលឃើញមានលោកអ្នកណាច្បាំងឈ្នះដល់ម្នាក់ឡើយ ។ ប្រសិនបើមាន មុខជាព្រះបាទធម្មាសោកគង់ព្រះជន្មនៅរហូតមកដល់សព្វថ្ងៃនេះទៅហើយ ។ ចុះហេតុអ្វីបានជាពួកបុថុជ្ជនសុទ្ធតែច្បាំងចាញ់ស្ដេចមច្ចុ (សេចក្ដីស្លាប់)? ហេតុថា ពួកនេះស្លាប់ហើយកើត ៗ ហើយស្លាប់ ផ្លាស់ប្ដូរគ្នាមិនចេះចប់ ទោះទៅកើតជាអ្វីក៏ដោយ ក៏នៅតែស្លាប់មិនខាន ។ មានតែព្រះអរិយៈ

ជាម្ចាស់មួយពួកប៉ុណ្ណោះទេ ដែលលោកច្បាំងឈ្នះស្តេចមច្ចុ ។ ចុះព្រះអរិយៈលោកក្ស័យព្រះជន្មដែរឬទេ? លោកក្ស័យដែរ ។ ចុះបើលោកក្ស័យដែរម៉េចក៏ថាលោកច្បាំងឈ្នះស្តេចមច្ចុ? បានជាថាយ៉ាងនោះ ព្រោះលោកក្ស័យព្រះជន្មហើយ លោកលែងកើតទៅទៀត ដែលហៅថាលោកចូលនិព្វាន ។ បើទុកជាមានព្រះអរិយៈអង្គខ្លះត្រូវកើតទៀត ក៏កើតតែត្រឹម ៧ ជាតិប៉ុណ្ណោះជាយ៉ាងច្រើនបំផុត ។

បើពួកមនុស្សបុថុជ្ជនចង់ច្បាំងឲ្យឈ្នះស្តេចមច្ចុនោះត្រូវតែខំប្រតិបត្តិធម៌តាមលំអានលោកជាព្រះអរិយៈ គឺត្រូវព្យាយាមលះបង់ចិត្តអាក្រក់ អំពើទុច្ចរិតទាំងពួងឲ្យរលោះស្រាលស្តើងបន្តិច ៗ ម្តង ទាល់តែជ្រះស្រឡះផុតអស់ពីសន្តានចិត្ត ទើបឈ្មោះថាច្បាំងឈ្នះស្តេចមច្ចុ ដូចពួកព្រះអរិយៈមិនខាន ។ ឯឈ្មោះព្រះអរិយៈនេះ មិនមែនកើតមកពីទីណាទេ ប្រាកដជាកើតមកពីខ្លួនជាបុថុជ្ជននោះឯង ដូចជាព្រះអង្គុលិមាលត្ថេរ កាលលោកកំពុងធ្វើជាមេចោរសម្លាប់អ្នកស្រុកនោះ ខ្លួនលោកនៅជាបុថុជ្ជនដែរ លុះលោកបានជួបនឹងព្រះពុទ្ធអង្គ បានស្តាប់ធម៌ទេសនាយល់ផ្លូវខុសត្រូវហើយ លោកផ្លាស់ចិត្តចោរកំណាចនោះចេញបានពេលណា ពេលនោះហើយខ្លួនលោកបានព្រះនាមថ្មីថា ព្រះអរិយៈ គឺព្រះអរហន្ត ។

សង្គ្រាមកំបាំង សង្ខេបប៉ុណ្ណោះ ។

# សាលារៀននៅប្រទេសជប៉ុន

## អ្នកស្រី ពេជ្រ-សល់ ហៅ សារិះយ៉ាង

### ប្រែរៀបរៀង

---

នៅប្រទេសជប៉ុន ទោះជាអ្នកទេសចរមានចិត្តពាយមាយមិនសូវយកចិត្តទុកដាក់នឹងពិនិត្យការផ្សេងៗក៏ដោយ ក៏គង់តែជៀសមិនរួចអំពីការប្រស្រ័យទាក់ទងផ្ទាល់នឹងសាលារៀនជប៉ុនដែរ ព្រោះសាលារៀននៅស្រុកជប៉ុន គេសង់ជាប់នឹងផ្លូវដើរតែម្តង ៗ ហើយអ្នកដំណើរតែងប្រទះឃើញសាលារៀននៅតាមផ្លូវ តាំងតែពីតំបន់ធំៗ រហូតដល់ទៅកន្លែងតៀនកោះ ក្នុងជនបទផ្សេងៗ តាមដំណាក់របស់ទេសចរ ដូចជានៅក្នុងតំបន់យ៉ាម៉ាតូ នៅក្នុងវិហារពុទ្ធសាសនាយ៉ាងចាស់នៃបូរណខេត្តមួយ ៗ

ចូរអ្នកដើរទៅតាមផ្លូវកាត់ភូមិតម្រង់ទៅសួនណាក៏ ដែលជាទីអស្ចារ្យមួយ សំបូរណ៍ដោយសត្វប្រើសនិងថ្ម ដែលគេតែងរាប់អានបូជា គឺនៅទីកន្លែងនេះហើយ ដែលលេចអណ្តែតឡើងនូវអតិចរិយានិងសេចក្តីក្សេមក្សាន្ត ៗ នៅពីមុខអ្នក សុទ្ធតែពួកសិស្សតូចៗ ដើរជាពីរជួរ ប្រមាណប្រហែលជាងរយនាក់ លោតរត់លេងហុយធូលីទ្រលោម ៗ គ្រូបង្រៀនពីរនាក់ដើរអមសិស្ស ហើយជួនកាលគេនាំគ្នាឈប់នៅមុខផ្ទះលក់របស់ក្មេងលេង ឬនាំគ្នាឈប់សម្រាកនៅរបៀងភោជនីយដ្ឋាន ៗ មួយសន្ទុះក្រោយមកគេនាំគ្នាចេញដំណើរតទៅទៀតយ៉ាងស្វាហាប់, ក្នុងចំណោមនេះ សិស្សស្រីនិងសិស្សប្រុសសឹងស្មើភាគគ្នា ស្លៀកពាក់ជាឯកសណ្ឋានតាមរបៀបស្រីប្រុស ៗ

មានសិស្សជាច្រើននាក់នាំគ្នាទឹកស្តាយកូយ៉ា-សាន ដែលអន្តាយ ដោយអគ្គិភ័យ ៗ កូយ៉ា សាននេះ ជាវិហារចាស់មួយនៃព្រះពុទ្ធសាសនា ដែលកូនក្មេងទាំងនោះតែងនាំគ្នាមកពីទីដទៃ តាំងពីចម្ងាយ ១៥០ ឬ ២០០ គីឡូម៉ែត្រ ដើម្បីមកឡើងលេង ៗ គេធ្លាប់ឃើញក្មេងទាំងហ្វូងៗ ចុះឡើងលេងលើព្រះវិហារ កាម៉ាគុរ៉ា ដែលមានរូបអាទិទេពក្វានុនសុទ្ធសឹងចិបដោយទឹកមាស ឈរលើផ្ទាំងសិលាដែលមានសណ្ឋានដូចជាក្បាលទូក លេចលយចេញគុគអំពីស្ទឹកលើទឹកសន្ទុះរលកទឹក ៗ ដូនកាលពេលល្ងាចទៅហើយ គេឃើញក្មេងខ្លះទៀត ទើបទឹងត្រឡប់មកពីធ្វើដំណើរប្រឡាក់សុទ្ធតែធូលី ដើរបណ្ដើរ ច្រៀងបណ្ដើរ តាមផ្លូវមួយចាស់នៅក្រុងតូក្យូ ហើយក្មេងដែលដើរជាជួរនោះមានគោមធ្វើអំពីក្រដាសរបនាអក្សរពណ៌ក្រហមបំភ្លឺផ្លូវមើលទៅគួរឲ្យសប្បាយណាស់ ៗ ហេតុដូច្នេះហើយ បានជាពួកជនទេសចរតែងយល់ថា ពួកសិស្សានុសិស្សជប៉ុនទោះមានវ័យក្មេង ក៏គង់មានមនោសញ្ចេតនាចំពោះធម្មជាតិ ដែលក្មេងនៅស្រុកឯទៀតពុំសូវរបេះផង ៗ នៅក្នុងសួនណាក៏ទឹងនៅលើឆ្នាខ្សាច់មីយ៉ាស៊ីម៉ា គេតែងប្រទះឃើញក្មេងអង្គុយនៅកន្លែងមួយយ៉ាងស្រួលមានប្រដាប់សំរាប់គូរមួយសំបៀតតូច ៗ ការព្រាងលើផ្ទាំងក្រដាសពុំសូវល្អប៉ុន្មានទេ ប៉ុន្តែការជ្រើសលំនាំនឹងគូរនោះងាយស្រួល ហើយច្បាស់ណាស់ ដូចជាដើមស្រល់មួយដុះរមួលលើផ្ទាំងសិលា, សិលាមួយដុំនៅក្បែរគល់ឈើមួយ ដោយមានទឹកសមុទ្រសស្អាប់ជាផ្ទៃនៃគំនូរនោះ ៗ ទម្លាប់ឲ្យក្មេងដើរមើលទេសភាពដែលគេបានដៅទុក ទម្លាប់

ឲ្យដើរហាលថ្ងៃក្រោមម្លប់ឈើ តាំងតែពីតូចបែបនេះ នាំឲ្យយុវជនជប៉ុនស្គាល់ដម្លៃធម្មជាតិ បេះស្រឡាញ់ប្រទេសជាតិ ហើយបេះមានមនោសញ្ចេតនាដ៏ក្លៀវក្លាមួយយ៉ាងពិសេសប្រពៃចំពោះជាតិ ។

ប៉ុន្តែបើគ្រាន់តែបាននាំសិស្សមើលរបៀបអនាម័យ ខាងការលំអរសប្បាយប៉ុណ្ណោះក៏គេពុំទាន់ពេញចិត្តដែរ ។ គេថែមទាំងនាំសិស្សទៅមើលរោងចក្រគ្រប់បែបជាញយៗទៀត ទៅមើលឃ្លាំងទុកទំនិញ មើលកំពង់ជំនួញ ហើយការបង្រៀនវត្ថុស្វាធ្យាយ ច្រើនធ្វើចំពោះវត្ថុតែម្តង ។ ភ្នាក់ងារក្រុមហ៊ុននាវាចម្នាក់ នៅយោកូហាម៉ាបាននិយាយថា មានគ្រូបង្រៀនជប៉ុនជាច្រើនរូប មកសុំច្បាប់គាត់ឲ្យសិស្សឡើងមើលកប៉ាល់ដែលគេបញ្ចូលមកក្នុងព្រែកដឹក ។ ព្រះអង្គម្ចាស់ គីគូជី (Kikuchi) អតីតរដ្ឋមន្ត្រីក្រសួងសិក្សាធិការ ក្នុងសន្និសីទមួយ ដែលទ្រង់បានថ្លែងនៅក្រុងឡុង កាលពី គ. ស. ១៩០៧ បានថ្លែងថា:

« ទម្លាប់នេះសឹងជាទម្លាប់សាកលទៅហើយ ដែលគេទម្លាប់ឲ្យនាំសិស្សធ្វើដំណើរទៅមើលទីផ្សេងៗ ឬធ្វើដំណើរទៅស្រុកឆ្ងាយតែម្តង ។ របៀបទាំងពីរយ៉ាងនេះសឹងស្របគ្នា ឬថាធ្វើដូចគ្នាបាន ។ របៀបមួយគឺធ្វើដំណើរក្នុងពេលវិស្សមកាលដើម្បីកំសាន្ត ឬដើម្បីហាត់ប្រាណ; របៀបមួយទៀត គឺរៀនដោយវិធីដើរទៅមើលដល់ទីកន្លែងដែលមានប្រយោជន៍ខាងសាវតារក្តី ខាងភូមិសាស្ត្រក្តី ឬខាងការប្រតិបត្តិក្តី ។ ទោះជានៅសាលាបឋមសិក្សាក៏ដោយ ក៏ត្រូវធ្វើដំណើរទៅមើលកន្លែងផ្សេងៗដែរ ។ នៅសាលាមធ្យមសិក្សា ពួកយុវជនធ្វើដំណើរទៅបួន ឬ ប្រាំថ្ងៃ ទើប

ត្រឡប់មកវិញ ។ នៅសាលាមធ្យមសិក្សាជាន់ខ្ពស់ដែលមានបន្ថែមវិជ្ជាខាងទាហានផងនោះ សិស្សរេចញទៅរៀនបាញ់យូរ ៗ ម្តង ។ ការម្ចណ៍កងការត្រួតត្រាឲ្យបានល្អ នាំឲ្យលោកខឹកកកកិច្ចការការពារណាដែលមានប្រយោជន៍ទុកជាមុន ។ ប៉ុន្តែដើម្បីនឹងបង្រៀនអំពីជីវភាពដល់ក្មេង ឬដើម្បីនឹងញ៉ាំងក្មេងទាំងនោះឲ្យស្គាល់នូវដម្លៃជាតិរបស់ខ្លួន, ការដែលនាំសិស្សានុសិស្សដើរមើលកន្លែងផ្សេង ៗ ដូចជាកប៉ាល់ធំមកពីប្រទេសអឺរុប ព្រះវិហារដែលគេតែងគោរពបូជា កាំភ្លើងធំ សំណល់កប៉ាល់ចម្បាំងរុស្ស៊ី ឬសំណល់កប៉ាល់ចម្បាំងជប៉ុន ដែលពោលនៅក្នុងព្រៃជាអនុស្សាវរីយ៍នៃជ័យជំនះ នោះជាការចាំបាច់មួយមានប្រយោជន៍ហើយគេពុំដំពាស់ទេ ។

ម្យ៉ាងទៀត របៀបបង្រៀនអំពីច្បាប់ពលរដ្ឋ នឹងច្បាប់មាតុប្រទេសមិនមែនជាការឥតប្រយោជន៍ទេ ។ នៅពេលថ្មី ៗ នេះ គេបានឃើញគ្រូបង្រៀននាំសិស្សដើរមើលកន្លែងចម្បាំងនៅគូរ៉េ ។ កាលពីខែកញ្ញាឆ្នាំមុន គេបានធ្វើពិធីរណ៍កាណាទិគមនៅក្រុងតូក្យូ ។ ពិធីនេះធ្វើនៅមុខផ្កាឈូក នៃបឹងស៊ីណូបាស៊ុយ ក្នុងគេហស្ថានមួយ ធ្វើអំពីថ្មសក្បូរនៅកណ្តាលថៃ្ង មើលទៅដូចជាកំពង់ហោហ្វាយក្រុងក្នុងកាណាទិគមណាមួយនៅស្រុកក្តៅ ។ នៅមុខទ្វារចូល មានទង់ជាតិពីរធ្វើអំពីស្ពានសំពត់សហើយមានរូបព្រះអាទិត្យពីរធំ ។ ក្រហមរន្ទាលផុះចេញអំពីស្ពានសំពត់ពណ៌សនោះ ។ ទង់ជាតិនោះដាក់ខ្វែងគ្នាតែមានសំពត់ខ្មៅស្តើងរុំពីក្រៅជាមរណសញ្ញាចំពោះព្រះអធិកជម៉ុជី (Meiji) ។ មានបណ្តាជនជាច្រើន

ប្រជៀតចូលទៅស្តាប់ក្មេងក្នុងតូបមួយតូប ដែលអ្នកលេងគាត់បោះតែលេងហាក់ដូចជាមិនចេះហត់; អ្នកស្តាប់ ស្តាប់ទាល់តែពួកអ្នកក្មេងលេង "បទលា" ទើបដើរចេញ ។

គេបានផ្សាយតាមវិទ្យុយ៉ាងខ្ទរខ្ទារណាស់ អំពីពិព័រណ៍អាណានិគមដែលកើតឡើងយ៉ាងរុងរឿងដោយមានការជប់លៀងអាហារ និងការថ្លែងសុន្ទរកថាផង ។ គេបាននាំយកមកតាំងនូវសត្វ រុក្ខជាតិ ហើយនិងផលិតផលផ្សេង ៗ ក្នុងព្រះរាជអាណាចក្រតាំងពីហ្វ័រម៉ូស រហូតដល់សាក្ខាលីន ។ គេបានទាំងនាំពួកញូណូស ដែលមានសក់ក្រញាញ់ក្រាបជាប់នឹងក្បាលស្លៀកពាក់ខោអាវពណ៌ឆើត ៗ យកមកឲ្យឈរនៅពីមុខខ្ទមរបស់ខ្លួនផង ដើម្បីជាភស្តុតាងអតីតកាលដែលមានជីវភាពទៅតាមប្រជាជាតិដាន់ដើម ។ នៅក្បែរនោះមានពួកជននៅកោះហ្វ័រម៉ូសដែលសប្បាយចិត្តនឹងឃើញគេទៅចោមរោមមើលខ្លួន គេឃើញជនទាំងនេះដើរទៅមើលរហូតដល់ថែវមន្ទីរមហោស្រពនៃព្រះអធិរាជ ដែលគេនាំទៅឲ្យមើល ដើម្បីឲ្យកោតសរសើរតែខ្លាំងទៅទៀត និងដើម្បីញ៉ាំងជនទាំងនោះឲ្យមានមនោសញ្ចេតនា កតញ្ញូ ដែលត្រូវប្រព្រឹត្តចំពោះអ្នកត្រួតត្រាផង ។ នៅក្នុងរបងពិព័រណ៍ មានបញ្ចាំងខ្សែភាពយន្តផ្សាយអំពីតេជានុភាពនៃប្រទេសជប៉ុន ហាក់ដូចជារូបរស់មែន ។

ការនេះមិនមែនធ្វើគ្រាន់តែជាការសម្តែងឲ្យសប្បាយ ដល់ភ្នែកអ្នកមើលនឹងជាការបំភ្លឺសតិបញ្ញានោះទេ គឺជាការបង្ហាញផ្លូវការ ១ អំពីអានុភាពអារ្យធម៌ផង ជាការបង្ហាញនូវគុណសម្បត្តិនៃរាជរដ្ឋាភិបាល

ផង ៗ តាមមតិរបស់អ្នកផ្ដើមបុណ្យ ពិធីនេះជាការប្រៀនប្រដៅមួយ
យ៉ាងខ្ពង់ខ្ពស់នៃព្រះអធិកជ ៗ

យុវជនជប៉ុនជាជនត្រូវបានមើលពិធីនេះមុនគេបង្អស់ ៗ មួយថ្ងៃៗ គេឃើញតែក្មេងដើរហូរហែទាំងហ្វូងៗ តាំងពីក្មេងតូចរហូតដល់ក្មេងជំទង់ មានសិស្សានុសិស្សធំៗ ដែលចូលទៅមើលទូរពិព័រណ៍នេះ យ៉ាងរីករាយ ដោយមានរបៀបរៀបរយល្អ ក្នុងទីនោះគេឮស្នូរតែសន្ទឹកស្បែកជើង ៗ យុវជនទាំងនោះដើរពាសពេញតែក្រោមម្លប់អ៊ុយអេណូ ដែលដុះនៅមាត់បឹងហើយនាំគ្នាចុះតាមជណ្ដើរមួយធំធ្វើអំពីថ្ម ដែលមានពណ៌ចំរុះគ្នាគ្រប់យ៉ាងដូចជាពណ៌មេអំបៅ រួចទើបនាំគ្នាទៅមើលអ័កទ់ដែលគេដាក់តាំងក្នុងទូកញ្ចក់ទៅប្រជ្រៀតក្នុងចំណោមមនុស្សច្រើន ៗ យុវជនខ្លះមានពាក់រូបផ្កាឈូករត្នលឿង រូបផ្កាអ៊ូឯទៀត ឬក៏រូបអ្វីផ្សេងជាគ្រឿងសំគាល់ ៗ ក្មេងៗទាំងនោះសុទ្ធតែចុះអំពីរថភ្លើងដែលគេបម្រុងទុកឲ្យ ដោយមានដំណើរលឿនរហ័ស ៗ តែគួរឲ្យអស្ចារ្យណាស់ គេឃើញមានយុវជនមកតាំងតែពីស្រុកឆ្ងាយ ៗ ដោយមានគ្រូបង្រៀនមកជាមួយផង ដើម្បីមើលការខុសត្រូវ ណែនាំក្នុងការធ្វើដំណើរនោះ ៗ មានយុវជនពួកខ្លះធ្វើដំណើរដោយជើង ចូលទៅសំណាក់ក្នុងភោជនីយដ្ឋាន ដែលជួបនៅតាមផ្លូវ ហើយអ្នកម្ចាស់ផ្ទះទាញជញ្ជាំងចេញដើម្បីឲ្យមានកន្លែងអាស្រ័យដំណេកគ្រប់គ្រាន់ ៗ យុវជនបែបនេះច្រើនតែមានគ្នាច្រើន ៗ ហើយហាក់ដូចជាគ្មានការបង្ខំឲ្យប្រព្រឹត្តតាមវិន័យសោះ តែហាក់ដូចជាចេះធ្វើឲ្យមានរបៀបរៀបរយដោយខ្លួនឯងតែម្ដង ៗ ក្មេង

ទាំងនោះ ហាក់ដូចជាមានចិត្តគិតចង់ក្រេបតែសេចក្តីសប្បាយក្នុងការរស់នៅ និងចង់ឃើញចង់ស្គាល់តែប៉ុណ្ណោះ ។ ការពិតគឺក្មេងទាំងមុនទាំងសែននាក់នោះនាំគ្នាមកពីគ្រប់ដំបន់ ដើម្បីកោតសរសើរដល់មាតុភូមិថ្មីរបស់ខ្លួន ដែលជាមហាអំណាចមួយយ៉ាងធំ ហើយដែលពេជការបំរុងនឹងច្បាប់រៀងនេះ ដល់ក្មេងប្រកបដោយចិត្តលោភចង់ដឹងនឹងចង់មើល ។

កម្មវិធីផ្សេង ៗ ដែលគ្រូបង្រៀនជប៉ុនព្រាងទុកក្នុងការនាំសិស្សដើរជាការសិក្សានោះ គឺអនាម័យចំពោះរាងកាយ អនាម័យខាងផ្លូវចិត្ត អនាម័យខាងធ្វើរាងកាយឲ្យល្អ (ព្រោះគេយល់ថាខ្លួនយើងតែងមានសុខភាពដោយចំណង់ ហើយដោយអាងទៅលើកំឡាំងផ្ទាល់នឹងធម្មជាតិតែម្តង) ការបង្រៀនខាងចំណេះវិជ្ជាបច្ចេកទេស និងការរៀនខាងប្រតិបត្តិការ ការហាត់ហ្វឹកហ្វឺនខាងកីឡា និងខាងការហាត់ទាហាន ការបណ្តុះបញ្ញា និងវីរភាពដែលមានន័យស្របគ្នា ។

ប៉ុន្តែយើងត្រូវយល់ថា របៀបបង្ហាត់បង្រៀនយ៉ាងសប្បាយរីករាយបែបនេះ គឺមកអំពីបណ្តាជនជប៉ុនមានបទបញ្ញត្តិពិសេសដោយឡែកសំរាប់ការសិក្សា ។ បើទោះជានៅប្រទេសឯទៀតដែលមានរបៀបរៀបរយល្អជាងប្រទេសជប៉ុន ក៏គ្មានរាស្ត្រដែលមានសន្តានចិត្តសប្បាយរីករាយ និងដើរលេងដូចប្រជាជនជប៉ុនដែរ ។ ដើម្បីជាឧទាហរណ៍ យើងគ្រាន់តែលើកយករឿងបួនទីទេស ដែលពួកអ្នកក្រីក្រនាំគ្នាធ្វើដំណើរទៅដោយដើងយ៉ាងសប្បាយឆ្ពោះទៅកាន់ក្អួនស៊ូ ដូចជាក្នុងណោនតៃ-សាន ឬ

ទៅកាន់ទីកសន្ទៈដែលនៅក្បែរមាត់សមុទ្រ ដូចជាអ៊ីសេជាដើម . . . ។ ប៉ុន្តែជនជាតិជប៉ុន មិនចាំបាច់តែមានការប្តូកទើបបានទៅទេ គឺជាជប៉ុនចូលចិត្តដើរទៅមើលកន្លែងផ្សេងៗ ក្នុងស្រុកខ្លួនឲ្យស្គាល់ ដូចជាពួកទេសចរបរទេសដែរ ។ គេចូលចិត្តឡើងទៅលើកំពូលភ្នំខ្ពស់ៗ ដើម្បីមើលទេសភាពដ៏ល្អ ។ នៅតាមផ្លូវឡើងភ្នំ មានជំរំតូចៗជាច្រើនដែលពួកអ្នកដំណើរជប៉ុនចូលចិត្តឈប់សំរាក ដេកតែមួយពេល - ពីរពេលរួចទើបបន្តដំណើរទៅទៀត ។

ជនជាតិជប៉ុនក្នុងវ័យកណ្តាលមានចិត្តចង់ដឹង ចង់ឮ ចង់ឃើញចង់ស្គាល់មិនចេះផុត មិនចេះអស់វិស័យដូចកូនក្មេង ។ នេះហើយជាទម្លាប់មួយ ឬជាលក្ខណៈជាតិមួយដ៏ពិតប្រាកដ ដែលជាសេចក្តីពន្យល់ជាការទ្រទ្រង់នូវគតុកោសល នៃការដើរមើលទីកន្លែងផ្សេងៗ ។

ម្យ៉ាងទៀត ប្រទេសជប៉ុន ដែលចែកបដោយភ្នំតូចធំស្រស់ញញឹមដោយកន្លែងមានទឹកធ្លាក់ ដោយគោជនាគារយ៉ាងរុងរឿង ដោយផ្លូវដើងតូចៗ សំរាប់អ្នកថ្មើរជើង ហាក់ដូចជាទាញចិត្តមនុស្សឲ្យដើរលេងឲ្យដើរទៅមើលកន្លែងផ្សេងៗដោយទ្រាំពុំបាន ។ ប៉ុន្តែរថយន្តវិញមិនអាចនឹងបើកទៅតាមនោះបានទេ បើទោះជាទៅបានក៏គេមិនសប្បាយចិត្តនឹងទទួលដែរ គឺជាវិធីសំរាប់តែអ្នកដើរលេងនឹងសំរាប់ក្មេង តែរទេះគោរទេះសេះក៏ពុំសូវមានដែរ ។ ផ្ទះជប៉ុនក៏ធ្វើអំពីឈើនឹងក្រដាស ហើយមានកងដូចជាចំហរទៅរកផ្លូវទាំងអស់ ថែមទាំងមានលក្ខណៈមិនជាប់លាប់មិនប្រាកដ ដែលគេតែងប្រាប់ទៅលើជនជាតិជប៉ុនតែម្តង ផ្ទះនោះ

ហាក់ដូចជាហៅអ្នកនៅឲ្យចេញទៅក្រៅ ។ ហេតុដូចនេះបានជាយើងមិនគួរឆ្ងល់ នឹងអ្នកនិពន្ធ រុស្ស៊ី ដែលបានសរសេរថា "ជីវភាពគ្មានទីកំណត់ ជាជីវភាពដែលខ្ញុំត្រូវការ ។ ការធ្វើដំណើរដោយជើងដោយឥតប្រញាប់នៅពេលត្រជាក់ល្អ ទៅក្នុងស្រុកមួយប្លែកដោយទេសភាពស្រស់ញញឹម ដើម្បីនឹងទៅមើលវត្ថុអ្វីមួយយ៉ាងល្អ នេះហើយដែលជាការរស់នៅយ៉ាងពេញលេញ ដែលខ្ញុំចូលចិត្តជាទីបំផុត ។ ជីវភាពគ្មានទីកំណត់នេះហើយដែលជាឧត្តមគតិរបស់ជប៉ុន ដែលចាប់កំណើតឡើងក្នុងផ្ទៃស្រុក ហើយអ្នកដើរលេងត្រូវតែឃើញវត្ថុអ្វីមួយល្អនៅទីបំផុតនៃការដើរនោះ" ព្រោះអ្នកនិពន្ធជាប់ជាតិជប៉ុន ។

ក្រោយមកទៀត នៅពេលដែលពួកបច្ចិមប្រទេស និងពួកអាមេរិកាំងនាំនាវាធំៗ គ្រឿងស្លៀកពាក់ និងឧស្សាហកម្មចូលមកដោយខ្លួនឯង ជនទាំងនេះបានពង្រីកនូវធម្មជាតិឈ្លបចង់ដឹងចង់ឃើញថែមទៀត ។ ដូច្នេះ ប្រជាជាតិនេះមានឯកសិទ្ធិទៅនឹងបានឃើញច្បាស់នឹងភ្នែកនូវបុរាណវត្ថុតែមួយ នៃអារ្យធម៌នៅចុងបូព៌ាប្រទេស ហើយនឹងវឌ្ឍធម៌យ៉ាងឆើត ដែលឧស្សាហកម្មយ៉ាងទំនើបបំផុតនិយមធ្វើបានប្រាកដ ។ ពួកសិស្សដែលដែលបានទៅទស្សនាវិហារណារ៉ា ហើយបានឃើញកន្លែងមួយដូចជាជ្រកនេះ គឺជាឃ្លាំងចាស់របស់ព្រះអធិរាជ សូស៊ូ·អ៊ុន ។ ក្រោយពីបានមើលវត្ថុទាំងនោះប៉ុន្មានម៉ោងមកទៀត ពួកសិស្សទៅមើលកំពង់ផែកូបេ ទៅមើលគ្រឿងទូរសព្ទនៅលើនាវាមួយធំឈ្មោះ "គូយ៉ូគីសេនកៃសា" ។ ពួកសិស្សនឹងមានអនុស្សាវរីយ៍

អំពីអារ្យធម៌សាកលលោកតាំងពីបុរាណកាលផង អំពីផលនៃអារ្យធម៌ដែលថ្មីបំផុតផង ។ គ្មានៈឃើញអ្វីចម្លែកក្រៅអំពីការមើលដោយមានចិត្តចង់សប្បាយក្នុងល្បែងនោះ ហើយការដែលចង់ឃើញនោះទៀត ទោះជាមានមនសិការច្រើនក្តីតិចក្តី ក៏គង់តែធ្វើឲ្យកើតកម្លាំងថ្មីដ៏កាច ។

សតិសម្បជញ្ញៈរបស់ប្រជាជនជប៉ុនញ៉ាំងឲ្យឃើញច្បាស់ថា ការសិក្សាដោយដើរមើល ទីងដោយធ្វើដំណើរទៅស្រុកជប៉ុន គេទុកដូចទម្លាប់ទំនៀម ជាអត្តភាពទូទៅ ទីង ជាការចាំបាច់ ។ ក្នុងកិច្ចនេះ សតិសម្បជញ្ញៈមានលក្ខណៈ តែតាមស្នាក់ធម្មតា គ្មានការបង្គាប់បង្ខំអ្វីដែលតាំងជាកម្មវិធីហើយស្រេចនោះទេ ។ សតិសម្បជញ្ញៈនេះ ចងភ្ជាប់មជ្ឈស្ថានសិក្សាទៅនឹងជីវភាពធម្មតានៅក្រៅសាលា គឺថាជាកំយុវជនទាំងនោះចំពោះអនាគតដែលនៅរង់ចាំខ្លួនទៅថ្ងៃក្រោយ ។ ទាំងនេះបង្ហាញឲ្យឃើញថា បើសិនជាគេអាចបង្កើនការដើរលេងរបៀបសាសន៍ជប៉ុននេះ ឲ្យកាន់តែបានច្រើនឡើង ហើយញ៉ាំងការដើរលេងនេះកុំឲ្យមានរបៀបជាការសិក្សាពេក តែឲ្យមានន័យច្បាស់លាស់; ម្យ៉ាងទៀតបើគេចង់ធ្វើការពិនិត្យឲ្យបានហ្មត់ចត់ខូវបុរាណវិហារ ឬវិមានណាមួយដែលជាកន្លែងបូជនិយេសនោ ។ ការដើរលេងឃើញថា មានប្រយោជន៍យ៉ាងសម្បើមដល់សាលារៀន ឬវិទ្យាល័យ ដូច្នេះក្នុងការដើរលេងនេះមានការសិក្សា ( ការអប់រំ ) មួយយ៉ាងប្រសើរ នៃការចង់ដឹងចង់ស្គាល់ ។ ចំណែកខ្ញុំ ៗ ក៏បានធ្វើល្បងបង្ហាញរួចហើយថា តើគេត្រូវធ្វើរបៀបណា ដើម្បីឲ្យការដើរលេងនេះ មានអានុភាពទៅលើប្រជាជន ដែលបានយក

មធ្យោបាយនេះទៅប្រើជាច្រើនរួចទៅហើយ ប៉ុន្តែប្រជាជននោះក៏បានយករបៀបនេះទៅកែប្រែទៀតជាច្រើនដែរ ៗ មួយវិញទៀត បើសិនជាចង់ឲ្យការដើរលំហែ និងការធ្វើដំណើរទាំងនោះប្រព្រឹត្តទៅតាមក្បួនខ្នាតពិតប្រាកដ ឲ្យសមតាមគំនិតរបស់ព្រះអង្គម្ចាស់ គីគូជី (Kikuchi) នោះ ៗ ត្រូវមានគ្រូបង្ហាត់ គ្រូបង្រៀន ឬសាស្ត្រាចារ្យជាអ្នកដឹកនាំ ហើយអ្នកដឹកនាំទាំងនោះត្រូវមានចិត្តចេះចង់សួរ ចេះចង់ស្គាល់របស់ដែលជួបប្រទះនៅតាមផ្លូវផង ត្រូវចេះធ្វើឲ្យមានបរិយាកាសយ៉ាងជិតស្និទ្ធរវាងសិស្សនិងគ្រូ ៗ ធ្វើដូច្នេះ ទើបខ្ញុំយល់ថាការសិក្សាដោយដើរមើលវត្ថុផ្សេង ៗ ប្រសើរជាងហើយគ្រាន់បើជាងការសិក្សា ដែលធ្វើនៅក្នុងសាលាដោយគ្មានសកម្មភាព គឺធ្វើនៅក្នុងសាលាធម្មតា ៗ

---

## ចាស់ទេតែទុកជានៅក្មេង

១— នរជនណាសូម្បីចាស់តែមានទ្រព្យច្រើន នរជននោះក៏ឈ្មោះថានៅកំលោះ; នរជនណាសូម្បីនៅក្មេងតែខ្សត់ទ្រព្យ នរជននោះក៏ឈ្មោះថាចាស់ជរា ៗ

ឧបាយនៃបុរសអ្នកស្វែងរកទ្រព្យ ដើម្បីកសាងខ្លួនជាអ្នកមានទ្រព្យ មាន ៦ ប្រការ គឺការសូមទានគេ ១, ធ្វើជាសេវកាមាត្យនៃព្រះនរបតី ១, ការធ្វើស្រែចំការ ១, ការបាននូវវិជ្ជា ១, ឲ្យការប្រាក់ (ធនាគារ) ១, និងពាណិជ្ជកម្ម ១ ។ បណ្ដាការងារទាំង ៦ ប្រការនេះ ឧបាយដ៏ប្រសើរដែលនាំឲ្យបានទ្រព្យច្រើននោះ គឺពាណិជ្ជកម្ម ។

បញ្ញត្រ្ត:

# រឿងសាមកុក

## ឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តមក)

---

រឿងសាមកុកទុកជាបរទូសាស្ត្រ
អ្នករាងវៃឆ្លាសបើបានអាន
នឹងបេះឧបាយកលបំណាន
ទាំងមានសន្តានស្នេហាជាតិ ។

### កណ្ឌទី ២៣

តាំងពីចូឆូនឹកតូចចិត្តដ្បិតបានទំនុកបំរុងគួនអ៊ូដល់ខ្នាត ហើយគួនអ៊ូមិនប្រែចិត្តពីឡៀពីសោះ រហូតដល់គួនអ៊ូបានទទួលសំបុត្រឡៀពីពីតាន់ជិនជាបំរើ ក្នុងសេចក្ដីសំបុត្រនោះនិយាយរំលឹកនឹងពីការអន់ចិត្តនឹងគួនអ៊ូ ។

---

*ចូឆូបានស្ដាប់ដូច្នោះក៏រឹតតែមានសេចក្ដីតូចចិត្ត ហើយគិតថា យើងបង់គំនិតដែលតាំងចិត្តទំនុកបំរុងគួនអ៊ូ ដោយយសស័ក្ដិស្រីស្គារបរិវារ គួនអ៊ូក៏នៅតែរលឹកអាល័យឡៀពីមិនភ្លេច ៗ គួនអ៊ូលាចូឆូទៅកាន់គេហដ្ឋាន ។ ចូឆូក៏សួរតៀវលៀវថា យើងបានចិញ្ចឹមរក្សាគួនអ៊ូក៏ដល់ខ្នាតប៉ុណ្ណោះហើយ គួនអ៊ូនៅតែមានចិត្តគិតអាឡោះអាល័យឡៀពីដរាបមិនភ្លេច យើងនឹងរិះគិតប្រការម្ដេចទើបគួនអ៊ូនឹងប្រែចិត្តចេញពីឡៀពី ? ។ តៀវលៀវឆ្លើយថា សុំឲ្យលោកបង្អង់ឈប់គិតការណ៍នេះ ១ ពេល*

២ ពេលសិនចុះ ចាំខ្ញុំបាទទៅល្បងនិយាយមើលគល់គួនអ៊ូឲ្យដឹងថា នឹងមានសុបរិតពិតត្រង់នឹងឡេពីទៀងទាត់ ឬគិតគេប្រែប្រការម្ដេចខ្លះ ។

លុះវេលាព្រឹកថ្ងៃ ១ គៀវលៀវទៅសួរគួនអ៊ូ អ្នកទាំង ២ ក៏គំនាប់គ្នាទៅវិញទៅមក គៀវលៀវនិយាយនឹងគួនអ៊ូថា តាំងពីមហាឧបាកជបាននាំមកទុកជាកំឡាំង លោកក៏មានសេចក្ដីសោមនស្សត្រេកអរបានទំនុកបំរុងអ្នកជាច្រើន ពីព្រោះមានមេត្តាដល់អ្នក ។ គួនអ៊ូក៏ថា សព្វថ្ងៃនេះមហាឧបាកជបានជប់លៀងខ្ញុំ បានជាខ្ញុំបានសេចក្ដីសុខដកបមក គុណមហាឧបាកជក៏មានលើខ្លួនខ្ញុំច្រើនណាស់ តែខ្ញុំនឹងបានក្បួចពីឡេពីក៏ទេ ។ គៀវលៀវតបថា ធម្មតាកើតមកជាប្រុសឲ្យដឹងច្បាស់ការធ្ងន់និងស្រាល បើអ្នកឯណាមិនដឹងមិនស្គាល់ហើយ មនុស្សទាំងពួងក៏រមែងត្រះតិះដៀលថា អ្នកនោះជាមនុស្សល្ងង់អប្បឥតប្រាជ្ញា ឯមហាឧបាកជនេះក៏មានចិត្តករុណាមេត្តាអ្នក បានទំនុកបំរុងលើសជាងឡេពីទៅទៀត ហេតុម្ដេចអ្នកក៏នៅតែគិតដល់ឡេពីមិនដាច់? ។

គួនអ៊ូឆ្លើយថា ដែលមហាឧបាកជមានព្រះគុណនឹងខ្ញុំនោះក៏មែនហើយ តែនឹងប្រៀបធៀបឲ្យស្មើឡេពីមិនបានទេ ព្រោះឡេពីមានគុណនឹងខ្ញុំមុន, ប្រការ ១ ខ្ញុំបានស្បថស្បាន់ទុកជាបន្ទាល់គឺយកគ្នាជាបងប្អូន បានជាខ្ញុំតាំងចិត្តរក្សាសេចក្ដីសត្យតញ្ញូនៅក្នុងចិត្តសព្វថ្ងៃ ខ្ញុំក៏មានគិតតបគុណមហាឧបាកជសិនទើបបានចេញទៅ ដើម្បីទុកកេរ្តិ៍ឈ្មោះជាមនុស្សកតវេទី ។ គៀវលៀវបានស្ដាប់ដូច្នោះក៏សួរគួនអ៊ូថា បើឡេពីដល់នៅសេចក្ដីមរណភាពហើយ អ្នកនឹងនៅជាប់នឹងមហាឧបាកជ ឬ ។

នឹងគិតប្រការម្ដេច ? ។ គួនអ៊ូតបថា ខ្ញុំកើតមកជាប្រុសរក្សាសេចក្ដីសត្យពិតត្រង់មិនឲ្យបង់ពាក្យ ប្រសិនបើឡៅពីក្ស័យជន្មាមែន ខ្ញុំក៏ត្រូវស្លាប់តាមគ្នាដោយពាក្យដែលបានស្បថស្បាន់ទុកនោះជាប្រាកដ ។

តៀវលៀវឃើញគួនអ៊ូមានសេចក្ដីសត្យពិតត្រង់ នឹងឡៅពីពិតប្រាកដដូច្នោះក៏លាចុះទៅវិញ ទើបនាំយកសេចក្ដីទាំងពួងថ្វាយឲ្យចូចូស្ដាប់គ្រប់ប្រការ ។ ចូចូបានស្ដាប់ហើយក៏ដកដង្ហើមធំមានតែសេចក្ដីវិតក្ក ព្រោះនឹងយកគួនអ៊ូទុកឲ្យដាច់ពីឡៅពីមិនបានដូចប្រាថ្នា ហើយសរសើរគួនអ៊ូថាជាមនុស្សមានសេចក្ដីសត្យពិតត្រង់ល្អមែន ។ ស៊ុនហុកជំពបចូចូថា ឯគំនិតនឹងចិត្តគួនអ៊ូនោះ ប្រុងនឹងតបស្នងសងគុណមហាឧបរាជឲ្យរួចទើបត្រឡប់ទៅវិញ បើដូច្នោះកាលណាមានសឹកសង្គ្រាមក៏កុំអាលឲ្យគួនអ៊ូចេញយកអាសា បើគួនអ៊ូមិនទាន់ធ្វើការឲ្យមានបំណាច់គាប់ប្រសើរទេ ក៏គង់នឹងនៅដោយសារមហាឧបរាជតទៅទៀត ។ ចូចូបានស្ដាប់ ក៏ជាប់ចិត្តគិតយល់ឃើញត្រូវផង ។

ឯឡៅពីនោះ កាលទៅនៅអាស្រ័យក្នុងស្រុកគីជីវនោះ ក៏ចេះតែគិតនឹករលឹកដល់គួនអ៊ូតៀវហ៊ុយ នឹងគ្រប់គ្រួដែលខ្ចាត់ក្ចាត់ព្រាត់ពីគ្នាមិនបានដឹងថាជារស់ ឬ ស្លាប់ប្រការម្ដេច តែងតែជាទុក្ខពុំសុខសប្បាយ មានកាយនោះស្គមថមថយកំឡាំង ទាំងបរិភោគអាហារនឹងនិទ្រាក៏ពុំស្រួលបានដូចប្រក្រតី ។ អ៊ូនសៀវឃើញមុខឡៅពីសៅហ្មងក៏សួរថា អ្នកមានបើព្រួយទុក្ខវិតក្កពីរឿងអ្វី ។ ឡៅពីឆ្លើយតបថា ខ្ញុំបាទបែកមកនៅនឹងលោក បានទីពឹងលោកក៏ផុតអំពីភ័យអស់ហើយ តែនៅគិត

ដល់បុត្រភរិយានឹងប្អូនទាំង ២ ដែលព្រាត់និរាសគ្នាទៅនោះ មិនបានដឹងដំណឹងថាជារស់ ឬ ស្លាប់ប្រការម្ដេច ប្រការ ១ ខ្ញុំបានកើតមកជាកូនប្រុស ហើយគិតនឹងជួយទំនុកបំរុងផែនដីឲ្យបានសេចក្ដីសុខ ការដែលគិតទុកនោះក៏មិនបានសម្រេច ព្រួយនឹងការកើតមកបានធ្វើជាខ្ញុំស្ដេចហើយ តែឥតប្រយោជន៍នឹងផែនដីសោះ ហេតុដូច្នោះបានជាខ្ញុំបាទមិនសប្បាយ ។

អ្នកសៀវបានស្ដាប់ដូច្នោះក៏ឆ្លើយថា បួនធ្វើការទុច្ចរិតអាក្រក់នឹងផែនដី យើងលើកកងទ័ពទៅដល់ដំបន់លីយ៉ុងប៉ងនឹងកំចាត់បួនចេញទទួលទេសៈកាលៈនោះ បានជាឲ្យឆាន់លៀងនាំពលទាហានទៅតាំងបន្ទាយនៅចុងដែនស្រុកហ៊ូគោ ខ្ញុំក៏លើកកងទ័ពត្រឡប់មកវិញ គ្រានេះជារដូវក្ដៅហើយ អ្នកកុំបរិតក្កឡើយ យើងនឹងលើកកងទ័ពទៅច្បាំងម្ដងទៀត វាយយកស្រុកហ៊ូគោឲ្យបាន ឯភរិយាបុត្រនឹងប្អូនអ្នកទាំង ២ នោះ ទោះបីស្លាប់រស់ប្រការម្ដេចក៏គង់តែដឹងដំណឹងពុំខាន ។

ទៀនហងបានឮអ្នកសៀវថាដូច្នោះក៏ថា កាលបួនលើកទ័ពទៅវាយស្រុកឈីជីវនោះ ខ្ញុំបាទបានដំរាបលោកឲ្យលើកកងទ័ពទៅវាយស្រុកហ៊ូគោ លោកមិនយល់ព្រមសោះ ឥឡូវនេះ បួនបានស្រុកឈីជីវហើយក៏លើកកងទ័ពត្រឡប់ទៅរក្សាស្រុកហ៊ូគោវិញ ដែលលោកនឹងលើកទ័ពទៅកំចាត់បួនគ្រានេះ ខ្ញុំបាទយល់ថាមុខជាមិនបាន ព្រោះសេនាទាហានរបស់គេព្រមមូលទាំងអស់ សុំឲ្យលោកពិគ្រោះរង់ស្ដាប់ដំណឹងសិន បើឮថាបួនលើកទ័ពទៅញីញក់ស្រុកណា សឹមយើងលើកទ័ពទៅខ្ទប់វាយយកស្រុកហ៊ូគោឲ្យបានដោយងាយ ។

អ៊ួនសៀវបានស្ដាប់គំនិយាយនឹងទៀតថា ពាក្យទៀនហានខ្ញាស់ឃាត់ទុកដូច្នេះ អ្នកនឹងយល់ឃើញប្រការម្ដេច? ។ ទៀវតបថា ប្អូនធ្វើការទុច្ចរិតអាក្រក់មិនមានគោតខ្លាច អំណាចព្រះបេស្ដាព្រះចៅហៀន-តេសោះ បណ្ដាមនុស្សក្នុងស្រុកហ៊ូគោ នឹងអាណាខែត្រក្រៅក៏បានសេចក្ដីឈឺក្ដៅពន់ប្រមាណ បណ្ដាពស្ដ្រសត្វទីហានក៏បានដឹងថា លោកមានសេចក្ដីសត្យកតញ្ញូនឹងផែនដី វេលានេះលោកក៏បានជ្រាបសេចក្ដីអស់ហើយ នឹងនៅព្រងើយកន្តើយមិនគិតកំចាត់អាសត្រូវពេជសម្បត្តិជាប្រញាប់ចេញនោះមិនគួរសោះ ប្រការ ១ ទៀត ប្អូននោះក៏មានចិត្តគុំគួនក្មាឡើង ព្រះចៅហៀនតេក៏បានសេចក្ដីព្រួយព្រះទ័យណាស់ សុំឲ្យលោកត្រិះរិះមើលតាមការគួរ ។ អ៊ួនសៀវបានស្ដាប់ទៀវក៏យល់ឃើញតាម ទើបឲ្យត្រៀមអាហារទុកព្រម បើបានឫក្សជោគជ័យវេលាណានឹងលើកពលយោធាចេញទៅ ។ ទៀនហានក៏ហាមឃាត់អ៊ួនសៀវទៀតថា គ្រានេះលោកកុំអាលលើកទៅ លោកចូរស្ដាប់ពាក្យខ្ញុំបាទចុះ ។

អ៊ួនសៀវបានឮដូច្នោះក៏ខឹងណាស់ ឆ្លើយតបទៅទៀនហានថា យើងគិតនឹងទំនុកបំរុងផែនដី ហេតុម្ដេចខ្លួនមកហាមឃាត់យើងដូច្នេះ ឬខ្លួននឹងចង់ឲ្យព្រះចៅហៀនតេបានសេចក្ដីអន្តរាយ ។ ទៀនហានឃើញអ៊ួនសៀវខឹងក៏តាំងតែកិតភ័យ ទើបលុតជង្គង់ចុះហើយជំរាបថា ខ្ញុំបាទឃាត់ហាមលោកដោយគំនិតយល់ឃើញតាមសុចរិត មិនមែននឹងគិតឲ្យអន្តរាយដល់ព្រះចៅហៀនតេទេ បើលោកខំមានះលើកកងទ័ពទៅ មុខជានឹងចោះការដោយដៃប្អូនជាប្រាកដ ។ អ៊ួនសៀវបានឮទៀនហានថែម

ថាដូច្នោះ  ក៏រិតតែខឹងខ្លាំងឡើង  ស្ទុះទាញក្របីចេញទៅប្រុងនឹងកាប់ទៀនហាង ។  ឡៅពីក៏ឃាត់ហាមអ៊ួនសៀវថា  លោកនឹងលើកកងទ័ពទៅធ្វើការរណរង្គសង្គ្រាម  នឹងមកធ្វើអន្តរាយទីប្រឹក្សាចេញនោះមិនគួរ ។  អ៊ួនសៀវក៏ស្រាកខឹងព្រោះស្តាប់ឡៅពី  ទើបឲ្យយកខ្លួនទៀនហាងទៅដាក់គុកទុក ។

បស៊ីវឃើញអ៊ួនសៀវយកទៀនហាងទៅដាក់គុកដូច្នោះ  ក៏នឹកតូចចិត្តពន់ពេក  ទើបយកទ្រព្យរបស់ទាំងពួងដែលជារបស់ខ្លួន  ចែកដល់បុត្រភរិយាញាតិកាបងប្អូនអស់  ហើយថា  អ៊ួនសៀវនឹងលើកទ័ពទៅគ្រានេះ  ទោះបីមានជ័យជំនះក៏មិនមែននឹងឲ្យបំណាច់រង្វាន់ដល់យើងឡើយ  បើទៅធ្វើការសង្គ្រាមនោះថោះការនឹងខូច  ឃើញថាជីវិតយើងនឹងមិនរួចវិលមកវិញបាន  អ្នកទាំងឡាយចូរនៅឲ្យសុខសប្បាយចុះ ។  ភរិយានឹងគណៈញាតិបងប្អូនឮដូច្នោះ  ក៏មានចិត្តគិតអាឡោះអាល័យបស៊ីវពន់ប្រមាណ ។

អ៊ួនសៀវមានសំបុត្រទៅដល់ង៉ាន់លៀង  ដែលតាំងទ័ពនៅតំបន់លីយ៉ុងនោះឲ្យលើកជាកងហ្លួងខាងមុខ  លើកចូលទៅលុកស្រុកហ៊្វូតោ ។  បស៊ីវក៏ឃាត់ហាមអ៊ួនសៀវថា  ដែលលោកចង់ឲ្យង៉ាន់លៀងលើកទាហានជាកងមុខទៅតែម្នាក់ឯងនោះ  ខ្ញុំបាទឃើញថាមិនគួរសោះ  ព្រោះង៉ាន់លៀងជាមនុស្សម្លោមម្លុះមិនបានដឹងច្បាស់ទីបង់ទីបាន ។  អ៊ួនសៀវឮដូច្នោះក៏ខឹងណាស់  ឆ្លើយតបទៅបស៊ីវថា  ង៉ាន់លៀងនោះជាសេនាឯករបស់យើង  ហេតុម្តេចអ្នកឯងមកជំនៀលដូច្នេះ ។  បស៊ីវមិនឆ្លើយ

តបសោះ   អ៊ួនសៀវក៏ចាត់បំរើសេះឲ្យយកសំបុត្រទៅឲ្យឆាន់លៀងៗ ទទួលមើលដឹងការណ៍ហើយ  ក៏លើកទ័ពរត់យកខ្លួនចូលទៅក្នុងដែនស្រុកហ៊្វូតោ  ដល់តំបន់ប៉ែះប៉ៃក៏ឲ្យតាំងបន្ទាយនៅទីនោះ ។  អ៊ួនសៀវក៏នាំឡៅពីលើកទាហានណ្សូនទៅទៀត ។

ខណៈនោះ  ឡេវអៀនចៅហ្វាយស្រុកគៈងគុន  ដឹងថាកងទ័ពអ៊ួនសៀវលើកមកដល់តំបន់ប៉ែះប៉ៃ   ក៏ធ្វើសំបុត្រចាត់បំរើឲ្យនាំចូលទៅជំកបប្បួ ។ ដឹងសេចក្តីក៏ឃាត់ខ្លួនឲ្យលើកទាហានចេញទៅ ។  គួនអ៊ូព្ភជំណឹងក៏ចូលទៅជួបនឹងប្បួហើយថា   គ្រានេះលោកនឹងលើកទ័ពទៅច្បាំងនឹងអ៊ួនសៀវ  ខ្ញុំបាទនឹងសុំកាសាលើកទាហានទៅជាទ័ពស្មច ។  ប្បួថា   ការសឹកបន្តិចបន្តួចប៉ុណ្ណោះមិនល្មមនឹងក្តៅដល់អ្នកទេ   បើសិនណាយើងទៅធ្វើសង្គ្រាមនឹងអ៊ួនសៀវហើយទុញទាល់ប្រការម្តេច សិមឲ្យមកអញ្ជើញនាក់ទៅជួយជាក្រោយ ។  គួនអ៊ូបានព្ភជ្ហូបោះក៏លាប្បួត្រឡប់មកផ្ទះវិញ ។

ប្បួចាត់ការឲ្យប្រមូលកេណ្ឌទាហានបាន ១៥ ម៉ឺន ញែកចេញជា ៣ កង  ហើយលើកចេញចាកក្រុងហ៊្វូតោ   ទៅដល់កណ្តាលផ្លូវទទួលបំរើសេះនាំពត៌មានមកប្រាប់ថា  ឥឡូវកងទ័ពមុខអ៊ួនសៀវលើកចូលមកដល់តំបន់ប៉ែះប៉ៃហើយ ។  ប្បួព្ភជ្ហូបោះក៏បង្គាប់ទ័ព ២ កងនោះថា  ឲ្យស្រូតកាត់ត្រមង់ផ្លូវលើកចុះទៅតទល់នឹងទ័ពអ៊ួនសៀវទុកកុំឲ្យលើកឆ្លងចូលមកទៀត  យើងនឹងលើកទ័ពណ្សូនទៅតទល់ជាក្រោយ   ហើយប្បួក៏លើកពលទាហាន ៥ ម៉ឺនស្រូតរូតទៅដល់តំបន់ប៉ែះប៉ៃ   ក៏តាំងបន្ទាយព័ទ្ធជុំវិញ

ផាប់ជិតនឹងកងទ័ពឆាន់លៀងចម្ងាយពីគ្នាប្រហែល ៥០ សិន (២ គ.ម.) រួចប៉ូចក៏ឡើងទៅលើភ្នំសំឡឹងមើលទៅឃើញទាហានឆាន់លៀង ប្រហែល ១០ ម៉ឺនប្រាយតាំងបន្ទាយជាយ៉ាងមាំ ប៉ូចនិយាយនឹងស៊ុងហៀនថា កាលអ្នកឯងនៅជាមួយនឹងលីប៉ោនោះ យើងបានឮដំណឹងថ្វីដៃខ្លាំងពូកែណាស់ ឥឡូវត្រូវអ្នកឯងលើកទាហានទៅប្រាំងនឹងឆាន់លៀង ។

ស៊ុងហៀនក៏ទទួលបង្គាប់ប៉ូចឡើងសេះកាន់ទួន លើកទាហានចុះទៅដល់មុខបន្ទាយឆាន់លៀង ។ ក្រឡេកឃើញ ក៏លើកទាហានចេញមកតប្រាំងនឹងស៊ុងហៀនបាន ៣ ក្បួន ឆាន់លៀងយកដាវកាប់ស៊ុងហៀនធ្លាក់ពីលើសេះ ។ ប៉ូចឃើញដូច្នោះក៏ភ័យណាស់ថា សេនាក្ដុងសៀវម្នាក់នេះមានថ្វីដៃខ្លាំងពូកែមែន ។ ង៉ុយសុកឆ្លើយថា ឆាន់លៀងសម្លាប់សំឡាញ់ខ្ញុំបាទស្លាប់ហើយ ខ្ញុំបាទសុំយកអាសាលោកទៅសម្លាប់ឆាន់លៀងឲ្យបានវិញទើបអស់កំហឹង ។ ប៉ូចក៏យល់ព្រមប្រគល់ទាហានឲ្យង៉ុយសុក លើកចេញទៅតនឹងឆាន់លៀង បាន ១ ស្របក់ ឆាន់លៀង យកដាវកាប់ង៉ុយសុកដាច់ពាក់កណ្ដាលខ្លួនជា ២ កំណាត់ស្លាប់ ។ ទាហានង៉ុយសុកក៏បែកខ្ញាត់ខ្ញាយរត់ត្រឡប់មកវិញ ។ ប៉ូចឃើញសេនាទាហានរបស់ខ្លួនបរាជ័យទាំង ២ លើកក៏នឹកតូចចិត្តណាស់ ទើបត្រាស់នឹងនាយកងនាយទ័ពថាឆាន់លៀងនេះ មានថ្វីដៃក្លាហានខ្លាំងពូកែណាស់ សម្លាប់ស៊ុងហៀននឹងង៉ុយសុកស្លាប់ហើយ នរណានឹងយកអាសាទៅចាប់ខ្លួនឆាន់លៀងបាន ។

(មានត)

# លោក ផេង-ជ្រើវ សាស្ត្រាចារ្យនៅសាលាគរុវិជ្ជាភ្នំពេញ

ប្រែពីភាសាបារាំងមកជាភាសាខ្មែរ

(តមក)

---

បន្ទាយកស្យ្រាមុិត នៅឆ្ងាយពីភូមិកាសិ កាព-ប៊ូលីណាស់ ហើយអ៊ីស្កាអ៊ីលមិនស្គាល់ផ្លូវផង តាមប្រកបដ្អៀត លើកលផ្លូវខ្សាច់នឹងលើខ្នងភ្នំ ៗ ស្បៀងអាហារនិងស្មៅសម្រាប់សត្វអូដ្ឋយកទៅបំរុងតែត្រឹមបួនថ្ងៃ ។ ម្យ៉ាងទៀត គឺសត្វអូដ្ឋយកបានតែចំនួនប៉ុណ្ណឹង ។ អ៊ីស្កាអ៊ីលប្រយ័ត្នមិនហ៊ានឲ្យឃ្លាតពីត្រីវិស័យទេ, វត្ថុបនេះ ជាប្រដាប់មួយយ៉ាងឯកសម្រាប់ជួយសង្គ្រោះក្នុងទីរហោស្ថាន គឺជាទីដែលជាតិអាក៉ប់នៅក្បែរច្រាំងសមុទ្រមិនហ៊ានលូកជើងចូលមក ។

ខ្នងភ្នំស្ងួតតែដុំថ្មប្រង គួរឲ្យស្ញើប ។ ខ្នងភ្នំនេះលាតសន្ធឹងជាបន្ទោះភ្នំពីរ គឺភ្នំ អ៊ូអាឌី-បេទី-អ៊ូលិជ និងភ្នំអ៊ូអាឌី-សែមសែម ។ ផុតពីខ្នងភ្នំនេះទៅ ទើបគេបានដល់បន្ទាយកស្យ្រាមុិត បន្ទាយនេះនៅជាប់ប៉ែកទិសខាងកើតនៃទំនួលដីប្រទេសទ្រីប៉ូលីតែន ដីកន្លែងនេះស្រុតចុះទៅក្នុងសមុទ្រជាទាបតូច ៗ នៅបណ្តាថ្មុកអន្ទង់ម៉ាកឈ្មោះតាអាឃា សព្វថ្ងៃទៅជាដីគោកស្រឡះហើយ ។

ពួកសេះនិងអូដ្ឋដែលជំពប់នឹងដុំថ្មធំ ៗ ដួលមុតរបួសជាធម្មតា ។ ជួនពួកអ្នកជិះ តោងតែចុះដើរជើងទទេ ព្រោះផ្លូវនៅក្បែរមាត់ជ្រោះ

ពេក ខ្លះចក្រែងវិលមុខ ។ ផ្លូវអាក្រក់សម្បើមជាងគេ ត្រង់ប្រកក្នុ អាក្រីម៉ា អាគេរូ ឆ្ងាស់ទុយឡា គឺជាផ្លូវឡើងចុះ ។ ម្ល៉ោះហើយគេគោង តែបន្តិចរើអីកាំនចុះ បន្តិចផ្ទុកឡើងលើខ្នងអូដូវិញ ។ ព្យុះខ្យល់បក់កណ្ដាល កន្ទារៈឈ្មោះតាឡា យុំយ៉ាំងអ្នកដំណើរអស់ដប់ម៉ោង ។

សេចក្ដីទុក្ខថប់ចូលមកទៀត គឺផុតស្បៀង ។ អ៊ីស្លាអ៊ីលទឹកថាខ្លួន គេ ព្រមទាំងកូនចៅហានទៀងជាដាច់ពោះស្លាប់មុនដល់បន្ទាយមិនខាន ។ ប៉ុន្តែនៅវេលាល្ងាចថ្ងៃទីប្រាំមួយ គេស្រាប់តែឃើញបន្ទាយលេចឡើង លឹម ។ ឯជើងមេឃ ។

ប្រាសាទបុរាណទាំងឡាយនៅទីក្រុងកស្យាមុិត ជាប្រាសាទល្អ ដាច់គេនៅទ្រីប៉ូលីតែន ។

មុនដំបូង អ៊ីស្លាអ៊ីលភ្ញាក់ផ្អើលឃើញសុទ្ធកំពែងធំៗ ។ គ្រឹះស្ថាន នេះមានកំពស់ពីប្រាំមួយទៅដប់ម៉ែត្រ សង់សុទ្ធតែអំពីថ្មបួនជ្រុងតូចៗ រៀបជាជួរយ៉ាងត្រឹមត្រូវ ។ មានគ្រឹះស្ថានធំសម្បើមចំនួនម្ភៃសង់នៅ តាមត្រើយខាងត្បូងនៃទន្លេអ៊ូអាឌីកស្យាមុិត ចម្ងាយប្រហែលបីរយម៉ែត្រ ពីមាត់ពាម ក្នុងទន្លេសិមសែម ។

ផ្ទះទាំងនោះមានថ្នាក់យ៉ាងតិចត្រឹមពីរជាន់ សុទ្ធតែមានកំពែងព័ទ្ធ ជុំវិញ ។ មានផ្ទះខ្លះ មានប៉មយ៉ាងជាប់មាំមួននៅក្បែរខាង ។

នៅកស្យាមុិត ទីក្រុងកសាងយ៉ាងមាំជាប់លាប់ តែគ្មានគ្រឿង លំអអ្វីឡើយ ។ បន្ទាយនេះ គេសង់ឲ្យតែជាប់ស្រួលប៉ុណ្ណោះ ។ គឺ ជាបន្ទាយលេចឡើងនាកណ្ដាលវាលសុទ្ធតែថ្មភ្នំក្រឡូម ដូចជាកំពូល

បពិត ។ កម្រាស់កំពែងទីងគួរដែលធ្វើនៅនាទីធ្លាខាងក្នុង ទុកជាផ្លូវឲ្យពួកទ័ពអាចតស៊ូទីងបច្ចាមិត្របានយូរ ។ ហេតុដូច្នេះ ទីនេះនៅឆ្ងាយពីច្រាំងសមុទ្រចំនួនមួយរយហាសិបគីឡូម៉ែត្រ បានជាទ័ពរ៉ូម៉ាំងចំណាយបន្ទាយនេះណាស់ ព្រោះគេអាចលៃពេលដើម្បីបញ្ជូនទ័ពពីទីក្រុងមួយជួយទាន់ ដ្បិតតាំងពីកាលណាមក បន្ទាយកស្សាម៉ុត គេទុកជាកន្លែងគទ័ពឈប់សំរាកលេខមួយ ។ ដោយអាស្រ័យរឿងនេះទើបពួកសាសន៍តួរគីមកតាំងទ័ពនៅទីនេះ ។

ម្យ៉ាងទៀត នៅទ្រីប៉ូលីតែន គេទុកបន្ទាយកស្សាម៉ុតជាស្ថានតាំងទ័ពប្រកបដោយសេចក្តីទុកព្រួយជាងបន្ទាយឯទៀតៗ របស់តួរគី ។ រដ្ឋាភិបាលកុងស្តង់ទីណុបតែងបញ្ជូននាយទាហាន ទីងទាហានណាដែលមានចរិតរឹងរូសមិនប្រព្រឹត្តតាមច្បាប់ព្រះចៅស៊ុលតង់ ទៅឯបន្ទាយកស្សាម៉ុតជាធម្មតា ។

តាំងពីពេលកើតសង្គ្រាមមក គេនិយាយថា មានទាហានជាចំនួនច្រើនត្រូវអាជ្ញាសិទ្ធិពីកុងស្តង់ទីណុប បង្គាប់ឲ្យនាយទាហានសម្លាប់ចោលក្នុងស្នាមគ្រោះជាច្រើនដងរួចមកហើយ ។ គេបានឲ្យឈ្មោះបន្ទាយកស្សាម៉ុតថា "យមបន្ទាប" បើអ្នកណាចូលក្នុងបន្ទាយនេះហើយ ត្រូវគាវនាធមិឲ្យហើយទៅ មុខជាអស់សង្ឃឹមហើយ ។

អ៊ីស្មាអ៊ីលគ្មានដឹងរឿងនេះសោះ ។ គេចូលក្នុងបន្ទាយដោយទាំងស្រមោលរូបនាងឡូឡាទៅផង ហើយមានការទុកចិត្តយ៉ាងមាំថា ថ្ងៃណាមួយមិនយូរពីឆាប់ គេនឹងត្រឡប់បានជួបមុខគូសង្សារវិញមិនខាន ។

ទេ! គួរអនិច្ចាពេក! គេមិនបាត់ការស្រមាក់ស្រមៃនូវរូបនាងឡូឡាពីក្អកសោះ ។

នាយទាហានអែបរបស់លោកមេទ័ពមកទទួលអ៊ីស្មាអ៊ីល ។ នាយទាហាននេះជាមនុស្សកំឡោះ មានអាយុស្របស្របាលនឹងអ៊ីស្មាអ៊ីលដែរ ។ ដោយទម្លាប់តរុណភាពតែងធ្វើមនុស្សជាតិផ្សេងសាសន៍ពីគ្នាឲ្យមានសេចក្ដីមេត្រីកគ្នាទៅវិញទៅមក ។

នាយទាហានតួរគីនេះ គេធ្លាប់បានឃើញអាការដ៏ស្ងប់ស្ងៀមយង់ឃ្លង់នឹងក្អកជាច្រើនលើកមកហើយ ហាក់ដូចជាគិតទុកជាមុនអំពីវាសនាដែលរង់ចាំអ៊ីស្មាអ៊ីល ។ កាលដែលលោកនេះមកទទួលលោកអនុសេនីយ៍ឯក មានវាចាសួរថា.

— លោកអនុសេនីយ៍ឯក! ពួកទ័ពធ្វើប្រតិបត្តិការ លើកសំដៅទៅសមុទ្រហើយ ហេតុម្ដេចក៏លោកអញ្ជើញមកខាងឯណេះវិញ?

អ៊ីស្មាអ៊ីលឆ្លើយប្រាប់ថា:

គឺជាបទបញ្ជា..ខ្ញុំត្រូវតែធ្វើតាម!

ខណៈនោះ នាយទាហានតួរគីសួរដោយមានទឹកចិត្តអាណិតយ៉ាងខ្លាំងថា:

លោកមិនដឹងទេឬ ការណ៍ដែលរង់ចាំលោកនៅឯកស្សាម៉ិត?

មុនដែលអ៊ីស្មាអ៊ីលនឹងឆ្លើយតបទៅវិញ នាយទាហានបើកទ្វារសម្ងាត់ហើយនាំអ៊ីស្មាអ៊ីលចូលក្នុងកន្លែងមួយពងក្រឡូម ដែលមានសពមនុស្សម្នាក់ស្លៀកពាក់អស្សេរកសណ្ឋានចង្ហូរនៅទីនោះ ។ រួចលោកប្រាប់ថា:

ហ្នឹងហើយ ឃើញឬទេ?

ក្នុងពេលនោះ អ៊ុស្មាអ៊ីលចូលចិត្ត អំពីនយោបាយរបស់លោកមេ-ទ័ពនៅក្រុងកាសិ - កាពប៊ូលីក្វាម គឺលោកមេទ័ពនេះមិនហ៊ានធ្វើបាបនូវកូនរបស់លោកការ៉ុដ លោកប្រើកលរបៀបបង្វែងជាន ដើម្បីឲ្យបានសម្រេចការណ៍ដូចគ្នា ។

អ៊ីស្មាអ៊ីលសំឡឹងខ្មោចបងកសព្វៗ រួចសំឡឹងមកលោកនាយទា-ហានទើបនិយាយដោយពាក្យឥតរន្ធត់ថា:

សូមការស្ម័គ្រនៃព្រះអាឡស់សម្រេចចុះ!

វេលានោះ លោកមេទ័ពមានបំរើឲ្យមកហៅគេចូល ។

*

* *

លោកវរសេនីយ៍ឯក ហ្វារេនឌីន - ប៉ី មេទ័ពប្រចាំបន្ទាយកស្បាម៉ុត ជាមនុស្សបំណាស់មួយក្នុងការសង្គ្រាម ហើយគេស្គាល់លោកច្បាស់អំពីគំនិតមារយាទ ក្នុងកិច្ចចាត់ចែងបទបញ្ជា ។

ត្រូវទទួលភារៈជាអ្នកបង្ក្រាបចំណែកភូមិភាគមួយ ក្នុងទ្រីប៉ូលីតែនដែលមានគូបិទ្ធុះបះបោរ មិនព្រមបង់ពន្ធ បែរជារកពាយតមកវិញ ហើយដើរឃោសនាឲ្យកើតចលាចលពាសពេញទាំងស្រុក លោកមេទ័ពប្រើមហាមធ្យោបាយដោយគ្មានរួញរា គឺលោកផ្តើមឲ្យចាប់សម្លាប់អ្នកស្រុកជាច្រើន ។

មាននាយទាហានរបស់លោកម្នាក់ ត្រូវគេសម្លាប់ ជាប្រផ្ទុលនៃការបះបោរ ។ ដើម្បីសងសឹក វេលាណាមានពិធីបុណ្យគាព៉ប់ គឺជាថ្ងៃ

បុណ្យរៀបជូនដំណើរដល់បូជនិយដ្ឋាយិក ដើម្បីទៅកាន់ព្រះវិហារម៉ែតប្ក ជាថ្ងៃបុណ្យដែលបូជនិយដ្ឋាយិកវិលត្រឡប់មកវិញ នោះលោកចាត់ឲ្យពួកទាហានបាញ់កាំភ្លើងធំចេញពីបន្ទាយ តាមទំនៀមទម្លាប់ ទោះបីកាំ-ភ្លើងបាញ់តែម្សៅទទេ ក៏គង់មានមនុស្សស្លាប់ជាច្រើន ព្រោះម្សៅដែលចេញទៅលាយទឹងគ្រាប់ប្រាយដែលដាក់ដុំក្រួសចំនួស ។

រដ្ឋាភិបាល កុងស្តង់ទីណុប ក៏មិនហាមឃាត់លោកមេទ័ព អំពីបទកំហុសនេះ ព្រោះរាជការគួរតែគិតថា មានតែឧបាយមួយនេះទេ ដែលប្រើសម្រាប់ត្រួតស្រុកៈ គឺឧបាយយង់ឃ្នង ។ ជាតិអង់គ្លេសក៏ប្រើនយោបាយដូច្នេះដែរ ។ ចំណែកពួកបារាំងសែសប្រើនយោបាយផ្ទុយពីសាសន៍ខាងលើនេះ ។ ទឹកឡើងគួរឲ្យស្រងេះស្រងោចអំពីទុច្ចរិតកម្មដែលលោកមេទ័ពនៅ ( កូតឌីវ៉រ ) បានធ្វើ គឺដុតភូមិចោលទាំងមូល ។

ដោយហេតុតែចិត្តគ្មានមេត្តាដូច្នេះ បានជាព្រះចៅ ស៊ុលតង់ តាំងនាយទាហាននេះជាវរសេនីយឯក ហើយបញ្ជូនមកបន្ទាយជាប់តែឯងកណ្តាលកន្តារៈ ប្រកបដោយប្រាសាទបុរាណសុទ្ធតែពស់ ក្អែប ព្រមទាំងអ្នកស្រុកក៏ច្រើនតែចិត្តរឹងរូសជាជាងមនុស្សក្នុងភូមិធំៗ ។ លោកមេទ័ពនេះមកនៅបន្ទាយកស្សាម៉ិតមិនទាន់បានមួយសប្តាហៈផង ស្រាប់តែមានគេបញ្ជូននាយទាហានចិត្តរឹងរូសមកកាន់ទីនេះភ្លាម ។ ពួកនាយទាហានដែលគេបញ្ជូនមកនេះ រស់នៅមិនបានយូរឡើយ គេសម្រេចកិច្ចឲ្យឆាប់រួសរាន់ណាស់ ។ ទាហានណាដែលគេបញ្ជូនទៅកស្សាម៉ិតហើយ គឺគេបញ្ជូនទៅរកសេចក្តីស្លាប់ ។

លោកវរសេនីយ៍ឯកអគ្គីយលើកៅអីវេង់ចាំអ៊ីស្មាអ៊ីល ។ គឺជាមនុស្ស អាយុប្រហែលហុកសិបឆ្នាំ សម្បុរក្រហមអុចៗ ពោះកំប៉ោងពុកមាត់ ទ្រុបសស្គុះ មានអាការផុយគ្នានឹងមុខក្រហមទុំដូចសំបកក្ដាមស្ងោរ ។

លោកស្លៀកពាក់ឯកសណ្ឋានតាមសម័យបុរាណ អាវខ្មៅត្រឹមតែ លើខោសំពត់ចែតង ស្បែកជើងរុំជិតទាំងកំភួនជើង ដែលធ្វើឲ្យជើង មានសភាពតូចមូល មិនដូចជាពេលកាលមិនទាន់ពាក់ ។

ក្អែកខៀវល្អក់ ព្រយខ្ញុំចុះកង់រទេះ ចំពោះមុខក្រាស់ហើយសព្រោងៗ លោកមេទ័ពមានភាពជាអ្នកលក់ក្រមាលត្ថុ ក្លែងគេទ ។ បើនៅឯប្រទេសបារាំងវិសេសវិញ គេអាចប្រដូចលោកនេះទៅនឹងនាយទាហាន ចាស់ជាន់ខ្ពស់មុនសង្គ្រាម ។

អ៊ីស្មាអ៊ីលចូលទៅបង្ហាញខ្លួននៅចំពោះមុខលោកមេទ័ពនេះ ។ លោកសំឡឹងខ្លួនលោកតាកាអ៊ីដតាំងពីក្បាលចុះមកដល់ជើង ។ លោក បានទទួលដំណឹងសព្វគ្រប់ដែលរ៉ាយរ៉ាប់អំពីលោកអនុសេនីយ៍ឯកកំឡោះ តាមសំបុត្រមួយដោយឡែកតែឯង ។

អ៊ីស្មាអ៊ីលឈរត្រង់ខ្លួនក្រអឺតក្រទមឯកសណ្ឋាន ដាក់ជើងត្រឹមគ្នាៗ លោកវរសេនីយ៍ឯកស្រែកបង្គាប់ដោយសំដីទ្រគោះថា:

– សម្រាក !

រួចបើកប្រអប់បារី លោកដកយកមួយហុចឲ្យមកលោកអនុសេនីយ៍ ឯកដោយទឹកមុខពេញញញឹមប្រាយ ។

អ៊ីស្មាអ៊ីលឆ្លើយថា:

— អរគុណ !

ខណៈនោះ នាយទាហានជាន់ខ្ពស់សើចញ៉ឹមៗរើសយកបារីមួយយ៉ាងខ្លាំង យ៉ាងក្រអូប គូសឈើគូសផុតដោយអាការមិនប្រញាប់បណ្ដោយឲ្យឆេះយ៉ាងស្រួល រួចក៏ទំលាក់ខ្លួនដេកទៅលើកៅអីវិញហើយសួរថាៈ

— អើ យើងឥឡូវនៅក្នុងកសក្រាមុតហើយ មែនឬទេ លោកអនុសេនីយ៍ឯក? ។ ហើយពួកមនុស្សទាំងប៉ុន្មានដែលមកជាមួយនឹងលោកក៏មកជួបជុំគ្នាអស់ហើយ ។

លោកមេទ័ពមានអាការដូចជាតុកចិត្តសុចរិត រួចស្រាប់តែផ្លាស់សំដីភ្លាម ហើយស្រែកដោយសំរែកដូចគេកាច់ថាៈ

— លោកអនុសេនីយ៍ឯក លោកនិយាយច្រើនពេក! យើងបានសម្លាប់ចោលនាយទាហានជាច្រើនណាស់ហើយ ដែលនិយាយតិចជាងលោកទៅទៀត ។

អ៊ីស្មាអ៊ីលឆ្លើយដោយសំដីឥតរំភើបថាៈ

— ខ្ញុំបាទដឹងហើយ! ខ្ញុំបាទឃើញប្រដាប់សម្លាប់ចងកហើយ! ។

លោកវរសេនីយ៍ឯកក្អក បឺតបារីមួយក្បឹតវែង ហើយនិយាយទៀតថាៈ

— លោកដូចជាមានសមានចិត្តចំពោះពួកទ្មិល ។

(មានត)

# រឿងបល័ង្កទិព្យ សាមសិបពីររឿង

រឿងព្រេងឥណ្ឌា

## លោកសមិន ម្ចូឡុនជិមៈ តែង
## លោកវ៉ាយ-ប៊ុក ក្រមការ ប្រែរៀបរៀង

(តមក)

---

## និទាននៃរូបទេពនិម្មិតទី ១៨

កាលណោះព្រះបាទភោជៈទ្រង់យាងចូលជិតបល្ល័ង្កទិព្វ ដើម្បីនឹងបាត់ឲ្យធ្វើពិធីមុទ្ធាភិសេកចំពោះព្រះអង្គ ៗ រូបទេពនិម្មិតទី ១៨ ក្រាបបង្គំទូលព្រះបាទភោជៈថាៈ

"សូមព្រះអង្គទ្រង់ព្រះសណ្ដាប់, ព្រះមហាក្សត្រិយ៍វិក្រមាទិត្យទ្រង់សោយរាជសម្បត្តិនៅនគរអវន្តី ៗ ទ្រង់មានកល្យាណមិត្តម្នាក់ឈ្មោះ សុមិត្រ (Sumitra) ដែលបានចេញពីគេហដ្ឋានរបស់ខ្លួនដើម្បីធ្វើដំណើរទៅកាន់ស្រះពិសិដ្ឋ ៗ ក្រោយដែលបានទស្សនាការនូវស្រះទាំងនោះ, សុមិត្របានចូលទៅជិតស្រះមួយឈ្មោះ សក្រាវតារ (çakravatâr) ដែលជារបស់នាងទេវធីតាមួយរូបព្រះនាមនាង យុគាទិទេវា (Yugâdidevâ ), ក្រោយដែលបានធ្វើសក្ការៈបូជា សូត្រសេចក្ដីសរសើរចំពោះព្រះនាង, លោកក៏បានចូលទៅក្នុងនគរមួយ, នៅទីនោះលោកបានឃើញជិតព្រះវិហារគាទិទេពមួយ នូវឆ្នាំងខ្ទះមួយពេញទៅដោយប្រេងក្ដៅនៅលើជើងចង្ក្រាន្ត មានភ្លើងឆេះខ្លាំង ៗ លោកបានសាកសួរ

មនុស្សនៅទីនោះ ៗ គេឆ្លើយថា: នៅទីនេះមាននារីម្នាក់ មានអាយុ: ដើនវៃមានសម្ផស្សជាទីត្រូវ នាមព្រះនាង មទនសញ្ជីវនី (Madanasanjivani) ជាព្រះរាជធីតានៃប្រទេសនេះ, ផ្ទាំងខ្ទះនេះជារបស់ព្រះនាង ៗ បុរសណាអាចចូលទៅក្នុងផ្ទាំងខ្ទះដែលពេញដោយប្រេង ហើយមិនស្លាប់ បុរសនោះជាស្វាមីរបស់ព្រះនាង ៗ

ដល់បានដំណឹងនេះហើយ សុមិត្របានឃើញព្រះនាងមទនសញ្ជីវនី, លោកបានពិចារណាទ្រង់ត្រាយ, កំពស់, លំអ, សុភាវម្មណ៍ ហើយទៅជាធ្លាក់ដោយចិត្តស្នេហាជាយ៉ាងក្រៃលែងចំពោះព្រះនាង ៗ ដល់វិលត្រឡប់ទៅកាន់នគរអវន្តីវិញ; លោកបានយករឿងនេះទៅក្រាបបង្គំទូលព្រះបាទវិក្រមាទិត្យ ៗ ក្រោយដែលទ្រង់ព្រះសណ្ដាប់នូវរឿងនៃសុមិត្រ ព្រះរាជាទ្រង់មានបំណងចង់ឃើញព្រះនាង, ទ្រង់ស្ដេចយាងទៅជិតផ្ទាំងខ្ទះដែលពេញទៅដោយប្រេងក្ដៅ ហើយក៏លោតទៅក្នុងប្រេងនោះ ៗ ព្រះនាងក៏ទ្រង់ជ្រាបនូវព្រឹត្តិការណ៍នោះទ្រង់យាងមកដល់, កាលណាព្រះនាងទ្រង់បានទតឃើញនូវមហារាជវិក្រមាទិត្យ, ទ្រង់យកទឹកអម្រឹតមកប្រោះព្រំ, ព្រះរូបមហារាជដែលរលាយដោយភ្លើងក៏ជាសះស្បើយដូចដើម, គ្មានស្នាមរលាក, គ្មានឈឺចាប់អ្វីឡើយ ៗ ព្រះនាងក្រាបបង្គំទូលព្រះនរបតីថា: បពិតមហារាជ ព្រះអង្គមានគុណសម្បត្តិដ៏ឆ្នើមចំពោះមហាក្សត្រិយ៍ ដែលទ្រង់បេះទទួលនូវសេចក្ដីទុក្ខឈឺចាប់គ្រប់យ៉ាង តើទុក្ខឈឺចាប់ណាដែលស្មើនឹងទុក្ខឈឺចាប់ ដែលត្រូវលោតចូលទៅក្នុងផ្ទាំងខ្ទះពេញទៅដោយប្រេងក្ដៅយ៉ាងនេះ? គឺដើម្បីនឹងបញ្ជាក់

នូវព្រះរាជចរិយាពេញជាមនុស្សធម៌ បានជាខ្ញុំម្ចាស់នេះយកផ្ទាំងខ្ទះនេះ មកដម្កល់នៅទីនេះ ខ្ញុំម្ចាស់យល់ថា: សភាពជាមនុស្សធម៌របស់ព្រះអង្គនេះ មានអានុភាពសម្បើមអស្ចារ្យណាស់ ។ ព្រោះហេតុនេះ ខ្ញុំម្ចាស់សប្បាយចិត្តនឹងព្រះអង្គពន់ពេក ។ សូមព្រះអង្គគង់នៅនឹងខ្ញុំម្ចាស់ទុកព្រះអង្គជាព្រះមហាក្សត្រិយ៍នៃប្រទេសរតនវតី (Ratnavati) ។

ក្រោយដែលព្រះនាងបានប្រើនូវមធ្យោបាយគ្រប់យ៉ាង ដើម្បីឲ្យព្រះមហាក្សត្រិយ៍គង់នៅទីនោះ ដោយប្រើវិធីក្រាបបង្គំទូលដោយសំដីដ៏ពីរោះអស្ចារ្យ, ព្រះនាងក្រាបបង្គំទូលព្រះបក្រីតទៅទៀតថា: "បពិត្រមហារាជ, ទ្រង់មានព្រះរាជទ្រព្យច្រើននៅក្នុងសង្សារនេះ; ព្រោះទ្រង់បេះរក្សាទុកនូវព្រះរាជហឫទ័យឲ្យស្ថិតនៅឆ្ងាយពីវិសមលោភ, ចំពោះនារីដែលមានលំអដូចខ្ញុំម្ចាស់ ព្រមទាំងមានពូជជាព្រះរាជវង្សានុវង្សផង ។

ក្នុងពេលនោះ, ព្រះមហាក្សត្រិយ៍ ទ្រង់ក៏បានព្រះរាជទានដល់កល្យាណមិត្រឈ្មោះសុមិត្រ នូវរាជសម្បត្តិនៃប្រទេសនេះ ព្រមទាំងព្រះនាងមទនសញ្ជីវនី, រួចទ្រង់ស្តេចយាងវិលត្រឡប់ទៅកាន់ព្រះរាជធានីវិញ ។

រូបទេពនិម្មិតទី ១៤ ក្រោយដែលបានថ្លែងនូវរឿងរ៉ាវនេះថ្វាយចំពោះព្រះបាទភោជ: បានក្រាបបង្គំទូលទ្រង់តទៅទៀតថា បើទ្រង់មានព្រះរាជចរិយាបែបនេះ ទ្រង់អាចគង់នៅលើបល្ល័ង្កទិព្វនេះបាន ។

ព្រះបាទភោជ: ទ្រង់បានស្តាប់នូវពាក្យនៃរូបទេពនិម្មិតទី ១៤, ក៏យាងចេញពីទីនេះក្នុងថ្ងៃនោះ ។

# និទាននៃរូបទេពនិម្មិតទី ១៥

មានកាលមួយថ្ងៃព្រះបាទភោជៈ ទ្រង់យាងចូលទៅជិតបល្ល័ង្កទិព្វ ដើម្បីនឹងបាត់ពិធីរាជាភិសេក ។ រូបទេពនិម្មិតទី ១៥ ដល់បានឃើញព្រះអង្គទ្រង់យាងមកដល់ ក៏ក្រាបបង្គំទូលថា៖

"ឱ! ព្រះបាទភោជៈ, សូមទ្រង់ព្រះសណ្ដាប់, តើមានលក្ខណៈយ៉ាងណា អ្នកដែលមានសិទ្ធិអាចគង់លើបល្ល័ង្កទិព្វនេះបាន?" ។

ព្រះមហាក្សត្រិយ៍ ទ្រង់មានព្រះបន្ទូលទៅកាន់រូបទេពនិម្មិតទី ១៥ ថា៖ "ចូរអ្នកពណ៌នាអំពីលក្ខណៈនោះមកមើល!" ។ រូបទេពនិម្មិតក៏ក្រាបបង្គំទូលព្រះបាទភោជៈថា៖

"មហារាជាវិក្រមាទិត្យ ក្រោយដែលទ្រង់ប្រមូលកងទ័ពមានបួនកង គឺកងហត្ថី, កងពាជី, កងព្រះទីនាំងរថ, កងពលថ្មើរជើង ទ្រង់បានវាយតយុទ្ធភូមិភាគទាំងអស់, ហើយទ្រង់ធ្វើឲ្យស្ដេចទាំងប៉ុន្មានស្ថិតនៅក្រោមបង្គាប់បញ្ជាព្រះអង្គ ។ មានសម័យថ្ងៃមួយ ទ្រង់ស្ដេចយាងទៅជាព្រះរាជាធិបតីភាពក្នុងមហាសន្និបាតគណៈរដ្ឋមន្ត្រី ជាមួយនឹងពួករាជទីប្រឹក្សាខាងធម្មសាស្ត្រ, ពួកភ្នាក់ងារក្រោមព្រះរាជបញ្ជា, ពួកវិញ្ញូជន និងឥស្សរជនឯទៀតជាច្រើន ។ ក្នុងពេលនោះ នាយឧយ្យានបាលចូលមកគាល់ព្រះអង្គ, ថ្វាយបង្គំអញ្ជលីរួចក្រាបបង្គំទូលទ្រង់ថា៖ "បពិត្រមហារាជ, ព្រះអង្គទ្រង់ជាព្រះមហារាជគ្រប់រដូវ, និទាឃៈរដូវ (រដូវក្ដៅ) បានចូលមកស្ថិតនៅក្នុងគុម្ពោតឈើ ដូចជាល្មោនពំសប្បាយពន់ពេក ។

គុម្ពោតក្រោនឹងផ្កាវល្លិ, ព្រៃក្បាលមានត្រយពន្លក. មានផ្លែផ្កាក្លែងពាំងគួរឲ្យមនោរម្យ ៗ នៅត្រពាំងទាំងអស់មានផលជាតិដុះចេញក្លិនស្អាងសែង; ពួកឃ្មុំជួបកងផ្កា, ស្រវឹងដោយទឹករបស់ខ្លួន, បានបញ្ចេញសូរសៀងដ៏ពីរោះ, បក្សាកោកិល (Kokila តាវ៉ៅ) យំដោយសម្លេងស្រទន់ជិតគ្នា ៗ

ដោយនាយទ្វារពានបាលក្រាបបង្គំទូលទ្រង់យ៉ាងនេះ, ទ្រង់ក៏បានស្ដេចយាងទៅកាន់រាជឧទ្យាននោះជាមួយនឹងព្រះរាជបរិពារ ទ្រង់បានកំសាន្តព្រះរាជហឫទ័យជាច្រើនបែបច្រើនយ៉ាង ៗ

នៅកណ្ដាលព្រៃ, កណ្ដាលទេវប្ជនីយស្ថាន ទ្រង់ក៏បានគង់លើបល្ល័ង្កមាសមួយ មានរំលេចដោយត្បូង ជាមួយនឹងព្រះរាជបណ្ឌិត, ហើយទ្រង់ក៏សិក្សាអំពីសស្ត្រ: ៗ ក្នុងពេលនោះ មានរាជបណ្ឌិតម្នាក់ជាចៅក្រំ បានពិនិត្យនូវសស្ត្រ:មួយកន្ទេង ហើយក្រាបបង្គំទូលថា: "បពិត្រមហារាជ សូមទ្រង់ព្រះមេត្តាប្រោស, ទូលបង្គំនឹងក្រាបបង្គំទូលថា: "សេចក្ដីសប្បាយក្នុងរាជសម្បត្តិ, ក្នុងវេលា, ក្នុងតំបន់ណាក៏ដោយ មិនប្រែកបដោយស្ថិរវន្តទេ; រូបកាយនេះមានឈាម, សាច់, លាមក, បស្សាវៈ, តែទ្រុឌទ្រោមពិការមិនប្រែកបដោយស្ថិរវន្តដែរ; ដូចជាបុត្រា, មិត្រ, ភរិយាទាំងអស់ ក៏មិនស្ថិតស្ថេរចិរកាល តែងតាំងនៅក្នុងអនិច្ចធម៌ ៗ ព្រោះហេតុដូចនេះ សេចក្ដីស្រឡាញ់ហួសប្រមាណមិនសមដល់ពួកបណ្ឌិតទេ ដូចជាសេចក្ដីស្រឡាញ់នាំឲ្យសប្បាយច្រើន, កាលណាប្រាសចាកសត្វនឹងសង្ខារ, សេចក្ដីស្រឡាញ់នោះនាំមកនូវទុក្ខធំ ៗ

ដោយហេតុនេះហើយ បានជាពួកបណ្ឌិតត្រូវអនុវត្តចិត្តឲ្យពិចារណាចំពោះជីវភាពជាអនន្តរកាល ។

តែគ្មានជីវភាពជាអនន្តរកាល ក្រៅពីបុរសឧត្តម(១) ដែលជាទម្រង់ដ៏ប្រសើរទេ ។ បើមនោមានសភាពទន់ជ្រងចំពោះចំណុចនេះ មនោនេះតែងប្រាសចាកពីគុកសង្សារបាន ។ កាលណាបៅក្រមបានក្រាបបង្គំទូលដូចនេះ មហាកជទ្រង់គង់ជ្រមៈមួយស្របក់, ហើយមានព្រះបន្ទូលថា "បើកាលណាខ្យល់អស្សាសៈ បស្សាសៈ ស្ថិតនៅក្នុងរូបកាយដែលមានទ្វារជាច្រើន គឺជាជីវភាពនៃបុគ្គលដែលរស់នៅសព្វថ្ងៃ; កាលណាខ្យល់អស្សាសៈបស្សាសៈចេញអស់ពីរូបកាយ គឺសេចក្ដីស្លាប់នៃបុគ្គលដែលរស់, ព្រោះហេតុនេះ ជីវិតជាអច្ឆរិយវត្ថុ ។ អ្វីទាំងអស់ដែលស្ថិតនៅក្នុងសង្សារវដ្ដ ត្រូវតែកើតស្លាប់ ហើយអាចគង់វង់បាន លុះតែវត្ថុធាតុមានសភាពគួរខ្ពឹម ឬជីវិតស្ថិតនៅ ។ ក្រោយសេចក្ដីស្លាប់, ការទាក់ទង (ដែលមានបច្ច័យតាក់តែងទាំងអស់) គ្មាន ។ អ្នកណាមួយដឹងវត្ថុធាតុទាំងអស់នេះដូចជាបានឃើញចំពោះភ្នែក, តែនៅស្រវឹងត្រេកត្រអាលក្នុងវត្ថុកាម និងកិលេសកាម, អ្នកនោះស្ថិតនៅក្នុងស្ថានភាពជាអ្នកល្ងង់ខ្លៅពិតប្រាកដ; ព្រោះហេតុថា ពិតមែនតែចំណេះមិនបានវិនាស ចំពោះបុគ្គលនោះ ។ មិនមានហេតុបច្ច័យទាក់ទងនឹង "បុគ្គលជាអនន្តរកាល" ។ អ្នកណាដែលទុកជា

---

១ បរមៈបុរុស – Parama-Purusha ប្រែថា "បុរសឧត្តម" នៅទីនេះត្រូវរក្សាទុកពាក្យអាំងឌីយាងថាបុរស ដែលប្រែថា «ប្រុស» ព្រោះបុរសជាពាក្យខាងទស្សនវិជ្ជាដ៏សុខុម ។

បុរស គឺអ្នកដែលព្យាយាមបំបាត់អវិជ្ជាឲ្យចេញចាកសន្តាន អ្នកនោះឯងជាឧត្តមបុរសមែនពិត ។

ក្រោយដែលបានធ្វើព្រះរាជសន្ធនាការអំពីវិជ្ជា ព្រះបាទវិក្រមាទិត្យមានព្រះរាជហឫទ័យសោមនស្សពន់ពេក និងចៅក្រមរបស់ព្រះអង្គ. ទ្រង់បានព្រះរាជទាននូវអំណោយមាស ៨ លក្ស (Lacks) ។

ព្រះបាទភោជ: កាលទ្រង់ព្រះសណ្ដាប់នូវសេចក្ដីពណ៌នានៃរូបទេពនិម្មិតទី ១៥ យ៉ាងនេះហើយ ទ្រង់ក៏មិនបានធ្វើជាភិសេកក្នុងថ្ងៃនោះ ។ (មានត)

## ពាណិជ្ជកម្មជាអំពើឲ្យបានជាសេដ្ឋី

១២ — សេចក្ដីពិត បណ្ដាឧបាយរកទ្រព្យទាំងអស់ មានតែឧបាយមួយទេ ដែលអាចកពូនទ្រព្យសម្បត្តិ គេសរសើរក្នុងលោកនេះគឺពាណិជ្ជកម្ម, ឧបាយរកទ្រព្យឯទៀតមិនទៀងទាត់ទេ ។

ពាណិជ្ជកម្ម ដើម្បីកសាងខ្លួនជាសេដ្ឋី មានវិធី ៧ យ៉ាង គឺជំនួញគ្រឿងក្រអូប ១ បញ្ចូលទំនិញទុកក្នុងឃ្លាំង ១ សមាគមជាមួយអ្នកជំនួញ ១ ការចូលមកច្រើននៃអ្នកទិញផ្ដាប់ទិញ ១ ការប្រាប់ដំឡៃលក់ខុស ១ ការលក់ដោយត្រាជូកោង ១ និងការដឹកទំនិញពីប្រទេសក្រៅចូលមក ១ ។

បញ្ចតន្ត្រ:

# កំណត់នឹងប្រវត្តិការណ៍

## ពិធីបំបួសកុលបុត្រជាតិបារាំងសែសម្នាក់

## នៅវត្តឧណ្ណាលោម

*របស់ពុទ្ធសាសនបណ្ឌិត្យ*

---

កាលពីថ្ងៃអាទិត្យទី ១៦ តុលា ១៩៥៥ វេលាម៉ោង ៣ កន្លះរសៀល នៅព្រះវិហារវត្តឧណ្ណាលោម សង្កាត់លេខ ៣ ក្រុងភ្នំពេញ មានពិធីបុណ្យបំបួសកុលបុត្រម្នាក់ជាតិបារាំងសែស ឈ្មោះ ឡូរ៉េង់ ប៉ូតែល អាយុ ២៥ ឆ្នាំ បួសជាសាមណេរ ដោយមានសម្តេចព្រះមហាសុមេធាធិបតី ជួន ណាត សង្ឃនាយកគណៈមហានិកាយជាព្រះឧបជ្ឈាយ៍ នាកណ្តាលជំនុំព្រះភិក្ខុសង្ឃពជាគណៈបានាមុក្រមជាច្រើនរូប មានព្រះតេជព្រះគុណព្រះពោធិវង្សចាងហ្វាងពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត នឹងព្រះតេជព្រះគុណព្រះសាសនមុនីជាចៅអធិការវត្តពិកទ្រវង្សជាដើម ។ សាមណេរនេះមានពុទ្ធិកនាមថា អានន្ទ ។

ពិធីបុណ្យនេះ ក្នុងវេលាមុនម៉ោង ១៦ គេសង្កេតឃើញពួកមន្ត្រីបរទេសទាំងឡាយគឺលោកវេជ្ជបណ្ឌិតប៉ិកកូត ( Pegcot ) ជាពុទ្ធជនដែលជាពុំនឹងរបស់សាមណេរនោះ, លោកបារតេស ( Barthes ) ទីប្រឹក្សានៅក្រសួងឃោសនាការជាតិ នឹងអស់លោកជាអគ្គទូតបរទេសប្រចាំប្រទេសកម្ពុជា លោកអូវែរតុន (Overtoon) នឹងលោក ម៉ារតាំងហារ្យ (NartinHary)

នៅស្ថានឯកអគ្គរដ្ឋទូតអាមេរិកាំង, លោកលេខាធិការទីអនុពន្ធនៃឯកអគ្គរាជទូតជប៉ុន, លោកកុងស៊ុលនៃប្រទេសចិន, លោកស្រីរ៉ាម (Shri-Ram) នាយកទាហានអនុពន្ធនៃគណៈកម្មាធិការអន្តរជាតិប្រទេសឥណ្ឌា ជាដើម ព្រមទាំងមន្ត្រីនិងឥស្សរជនជាតិខ្មែរទាំងឡាយមានលោកស៊ុន-ហ៊ន់ ក្រុមប្រឹក្សាព្រះរាជអាណាចក្រ, លោកសឺន-សាច់ អតីតចៅ-ហ្វាយខេត្ត, លោកវិសេសកោគា (ទា-ជាវលី) និងលោកគហបតី ថេ-យាន ជាដើម មួយអន្លើដោយលោកអ្នកពុទ្ធបរិស័ទជាតិវៀតណាម និងជាតិខ្មែរជាច្រើនទៀត ដែលយើងសូមអភ័យទោសដោយមិនបានរាប់នាមឲ្យសព្វគ្រប់ក្នុងទីនេះ សឹងបានអញ្ជើញមកដល់មហាកុដិនៃសម្តេចសង្ឃនាយកមហានិកាយ និយាយដោយរួបរួមគឺថាមានបណ្ដាជនច្រើនកុះករប្រជ្រៀតគ្នាទាំងក្នុងព្រះវិហារទាំងខាងក្រៅព្រះវិហារ ដោយចង់ដឹងចង់ឃើញកុលបុត្រជាតិឧរូប ដែលចូលមកសូមផ្នួសក្នុងព្រះពុទ្ធសាសនាជាលើកដំបូងបង្អស់នៅប្រទេសយើង ។

បន្ទាប់មក សម្ដេចសង្ឃនាយក ជួន-ណាត បានអញ្ជើញឥស្សរៈជនទាំងនោះឲ្យកាន់គ្រឿងបរិក្ខារសំខាន់ៗ-ម្នាក់មួយមុខៗ ដើរតម្រង់ទៅប្រទក្សិណជុំវិញព្រះវិហារ ។ លុះចូលទៅក្នុងព្រះវិហារហើយ ឧបា-សកបាននមស្ការព្រះរតនត្រ័យ ។ រួចពីនោះ នាគក៏បានសូត្របាលីសុំផ្នួសហើយប្រគេនទូវត្រៃចីវរទៅឧបជ្ឈាយ៍ ដើម្បីឲ្យលោកបំពាក់មកខ្លួនវិញ ។

សម្តេចសង្ឃនាយកដែលត្រូវជាគ្រូក៏បានទទួលត្រៃចីវរនោះ, ហើយបំពាក់អង្សកនៅកនាគរូប ប្រគល់ស្បង់ចីពរទាំងអស់ឲ្យយកទៅស្លៀកពាក់ នៅទីកន្លែងកំបាំងក្នុងព្រះវិហារ ហើយត្រឡប់មកថ្វាយបង្គំព្រះបាទឧបជ្ឈាយ៍វិញ ។ រួចអំពីកិច្ចខាងលើនេះហើយ ឧបជ្ឈាយ៍ក៏សូត្រសិក្ខាបទទាំង១០ប្រការ ឲ្យនាគសូត្រតាមលុះត្រាតែចប់ ។

កិច្ចខាងលើដែលបានធ្វើរួចស្រេចហើយនេះ ទុកជាកិច្ចបញ្ចប់ពិធីបុណ្យបំបួសនៅឱកាសនេះ ។ ព្រះពុទ្ធសាសនាក្នុងប្រទេសយើងក៏បានបព្វជិតជាតិអឺរ៉ុបមួយរូប ។

សាមណេរ ឡូរ៉ង់ប៉ូតែល លុះបានទទួលបព្វជ្ជារួចហើយ បានសូត្រសុន្ទរកថាជាភាសាបារាំង ថ្លែងអំណរគុណចំពោះគណៈសង្ឃមានសម្តេចព្រះសង្ឃនាយកជាប្រធានដែលបានទទួលភារៈនៃកិច្ចបព្វជ្ជា ព្រមទាំងចំពោះពុទ្ធមាមកជននិងមិត្តនៃពុទ្ធសាសនាទាំងអស់ ដែលបានអញ្ជើញមកជួយអបអរសាទរបំពេញកិត្តិយសជាភ្ញៀវ ក្នុងពិធីបព្វជានោះៗ បន្ទាប់មក, លោក ញ៉ង-សៀង លេខាធិការនៅក្រុមពុទ្ធសាសនបណ្ឌិត្យ បានថ្លែងសុន្ទរកថាដដែលនោះជាភាសាខ្មែរ ដែលលោកគ្រូព្រះគ្រូសង្ឃសត្ថា ប៉ុណ្ណ-សម្ភាជ បានប្រែសម្រួលមកពីភាសាបារាំង ។

លុះរួចកិច្ចនេះសព្វគ្រប់ហើយ មានការជប់លៀងភេសជ្ជៈចំពោះភ្ញៀវជាបព្វជិតនិងគ្រហស្ថ នៅទីលានខាងមុខព្រះវិហារជាកិច្ចបង្ហើយបុណ្យ ។

ឯសុន្ទរកថា ដែលប្រែមកជាភាសាខ្មែរនោះ យើងសូមយកមក ចុះផ្សាយជូនដូចតទៅនេះ ៖

## សុន្ទរកថាប្រែសម្រួលសេចក្ដីពីបារាំងមកជាខ្មែរ

ខ្ញុំព្រះករុណា, អាត្មាភាព សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ សម្ដេចជាសង្ឃនាយកគណៈមហានិកាយ និងព្រះថេរានុត្ថេរៈគ្រប់អង្គ, ទ្រង់, ឯកឧត្ដមរដ្ឋមន្ត្រីនៃព្រះរាជរដ្ឋាភិបាល ឯកឧត្ដមសមាជិកនៃអង្គទូត ព្រមទាំងអស់លោក អស់អ្នក ជាឥស្សរជនជាតិខ្មែរនិងបរទេស ដោយ រួបរួមគឺ ចំពោះពុទ្ធមាមកជន និងមិត្តនៃព្រះពុទ្ធសាសនា ដែលមានមេត្តា បំពេញកិត្តិយសដ៏ប្រសើរ ដល់ខ្ញុំព្រះករុណា, អាត្មាភាពក្នុងពិធីនេះ ។

ខ្ញុំព្រះករុណា, អាត្មាភាព សូមពុំប្រើវោហារលៃបខាយយកមក អធិប្បាយហេតុផលប្រគេន-ថ្វាយ-ជូនក្នុងទីនេះទេ ។ ហេតុនៃផលនេះ មានតែម្យ៉ាង ហើយជាសេចក្ដីពិតឥតបំផ្លើស ដែលបើកបង្ហាញនូវ ចិត្តគំនិតរបស់ខ្ញុំព្រះករុណា, អាត្មាភាព ប្រគេន-ថ្វាយ-ជូនឲ្យបានជ្រាប ច្បាស់ដូចតទៅនេះ ៖

ខ្ញុំព្រះករុណា, អាត្មាភាពមានកំណើតនៅប្រទេសបារាំង បានចំរើន វ័យវឌ្ឍនៈធំឡើងក្នុងមជ្ឈដ្ឋានកម្មករថ្នាក់មធ្យម, មាតាបិតាពុំមែនជាអ្នក កាន់សាសនាគ្រិស្ដទេ ជាមជ្ឈត្តបុគ្គលសុទ្ធសាធ គឺជាអ្នកឥតប្រកាន់ សាសនាណាមួយឡើយ ។ អាស្រ័យហេតុនេះ, បឋមវ័យរបស់ខ្ញុំព្រះ ករុណា, អាត្មាភាព ក៏បានកន្លងទៅក្នុងមជ្ឈដ្ឋានប្រាសចាកការប៉ះពាល់

ទីធ៍សាសនាណាមួយដោយពិត ៗ ខ្ញុំព្រះករុណា, អាត្មាភាពពុំមានទោមនស្សទេ ព្រោះការណ៍នេះបែរជានាំឲ្យមានទស្សនៈយ៉ាងបរិសុទ្ធក្នុងជីវភាព ដ៏ប្រាសស្រឡះចាកការស្រពក់ស្រព័ណ្ណក័ន្តច្រឡំគ្រប់យ៉ាង ៗ

ចាប់តាំងពីអាយុគំរប់ ២០ ឆ្នាំ គឺបន្ទាប់អំពីពេលឈប់សិក្សាមក, ខ្ញុំព្រះករុណា, អាត្មាភាព ក៏បានហាត់រៀនសង្កេតត្រួស ៗ នូវសាសនាធំៗ ហើយបានទាក់ជាប់ចិត្តនៅចុងក្រោយបំផុត ដែលឃើញមានតែមួយគត់ បើនិយាយដោយចំពោះគឺ ព្រះពុទ្ធសាសនា ។

ព្រះពុទ្ធសាសនាពុំមែនដូចជាសាសនាដទៃ ដែលច្រើនតែជាលទ្ធិប្រើអាការបង្ខំនោះទេ ទាំងពុំមែនជាជំនឿឥតហេតុផលផង គឺពេញទីជា ឥបជមិ, តាមសេចក្តីយល់របស់ខ្ញុំព្រះករុណា, អាត្មាភាព គឺជារបៀបនៃការសិក្សាដែលមានទំនងដូចជាវិទ្យាសាស្ត្រសម្រាប់ដុសខាត់ចិត្តឲ្យបរិសុទ្ធផូរផង់ ។

ហេតុតែមួយយ៉ាងនេះឯងហើយ ដែលនាំឲ្យខ្ញុំព្រះករុណា, អាត្មាភាព មិនជ្រើសយកជំនឿនឹងលទ្ធិដទៃ ត្រឡប់មកជឿកាន់ព្រះពុទ្ធសាសនាយ៉ាងខ្ជាប់ ៗ ខ្ញុំព្រះករុណា, អាត្មាភាព បានរាវរកមើលសៀវភៅក្បួនច្បាប់ពុទ្ធសាសនាជាច្រើន ទើបកើតគំនិតយ៉ាងខ្ជាប់ខ្ជួនមួយឡើងថា ត្រូវចេញមកកាន់បូព៌ាទិស រស់នៅក្នុងទីនេះ ព្រមទាំងសង្កេតមើលនូវជីវភាពរបស់ប្រជាជនពុទ្ធសាសនិក ដើម្បីនឹងយកជាបែបផែនសិក្សា ព្រមទាំងប្រតិបត្តិតាមវិធីនៃប្រជាជនទាំងនេះ ដ៏ជាការស្រាវជ្រាវរកផ្លូវ

បេះដូង ប្រយោជន៍នឹងបណ្តុះបញ្ញាឲ្យបានសម្រេចផល ដើម្បីនឹងផ្សាយនូវសុភមង្គលចំពោះសព្វសត្វទាំងអស់ ។

នេះពុំមែនជាការដើរផ្សងព្រេងដ៏អស្ចារ្យមួយឬ? ចំពោះអ្នកដែលធុញទ្រាន់នឹងជីវភាពខាងសម្ភារនិយម នឹងជំនឿបន្ទុំដែលឥតផលប្រយោជន៍ ហើយខំស្រាវជ្រាវរកទៅក៏ឃើញជាក់ថា មានតែវិបស្សនាកម្មដ្ឋានក្នុងព្រះពុទ្ធសាសនាប៉ុណ្ណោះទេ ដែលប្រកបដោយតម្លៃពិតប្រាកដ ។

គឺហេតុតែមួយយ៉ាងហ្នឹងឯង ដែលបណ្តុះបំណងឲ្យខ្ញុំព្រះករុណា, អាត្មាភាពចង់ស្លៀកដណ្តប់កាសាវពស្ត្រ ដែលជាមធ្យោបាយដ៏ល្អតែមួយក្នុងការប្រតិបត្តិ នឹងការសម្រេចខាងផ្លូវវិបស្សនាកម្មដ្ឋាន ដើម្បីឲ្យបានទៅជាបុគ្គលមួយរូប ដែលឥតទ្រព្យសម្បត្តិ ឥតមានឋានៈវិជ្ជាខ្ពង់ខ្ពស់ ក៏អាច ទៅជាសុខស្រួល បាន ។

ខ្ញុំព្រះករុណា, អាត្មាភាព សូមបញ្ចប់សេចក្តីនេះ, ដោយសូមថ្លែងអំណរគុណចំពោះអស់លោកអ្នករាជការ នៃព្រះរាជអាណាចក្រខ្មែរឯករាជ្យ ដែលបានអនុញ្ញាតឲ្យខ្ញុំព្រះករុណា, អាត្មាភាពបានសម្រេចផ្នួសដោយងាយ ហើយដែលជាហេតុឲ្យមានពិធីបុណ្យនេះឡើង ។ ខ្ញុំព្រះករុណា, អាត្មាភាពសូមថ្លែងអំណរគុណក្នុងទីនេះ ចំពោះលោកវេជ្ជបណ្ឌិតប៊ុអ្សូត៍ ដែលសមានទេសិក (ជាតិបារាំងដូចគ្នា), លោកស៊ីនួរ-វ័ណ្ណ សមាជិកក្រុមប្រឹក្សាព្រះរាជអាណាចក្រ នឹងលោក សឺន-សាប់ អតីតចៅហ្វាយខែត្រ ទាំងជាអតីតគូឈួយរដ្ឋមន្ត្រីក្រសួងសិក្សាធិការជាដើម ដែលបានជួយរៀបចំចាត់ចែងពិធីបុណ្យបួសដ៏ឧឡារិកនេះ ។

ខ្ញុំព្រះករុណា, អាត្មាភាពមានអំណរណាស់ ដោយបានសង្កេតឃើញៈលោកម៉ាតាំង ហ៊ែរ្ស រដ្ឋទូត នៅស្ថានឯកអគ្គរដ្ឋទូតអាមេរិក, ដែលជាអ្នកមានសេចក្ដីខ្នះខ្នែងក្នុងការស្ថាបនាមេត្រីភាព រវាងអ្នកកាន់ព្រះពុទ្ធ-សាសនានៃប្រទេសកម្ពុជានិងសហរដ្ឋអាមេរិក បានអញ្ជើញមកក្នុងពិធីនេះផង ។

នៅទីបំផុត ខ្ញុំព្រះករុណា, អាត្មាភាព សូមប្រគេន-ថ្វាយ-ជូន នូវពរតាមគន្លងព្រះពុទ្ធសាសនា, ដ៏ស្មោះចំពោះពីដួងហទយវត្ថុថា:

សូមសម្ដេច, ព្រះថេពន្ទុត្តរៈ, ទ្រង់, ឯកឧត្តម និងអស់លោកអ្នកគ្រប់រូប បានប្រកបដោយ សុខភាព និង សន្តិភាព អស់កាលជាអង្វែងរៀងទៅ !

ឡ្យូរ៉ង់-ប៊ូតែល
មានពុទ្ធិកនាមថា អាឈ្នៈ
ប្រែដោយព្រះគ្រូសង្ឃសត្ថា
ប៉. ស. ធម្មាភម